ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា

# ភាសាខ្មែរ




នាយកដ្ឋានអប់រំកុមារតូច ព.ស ២៥៦៦ គ.ស ២០២២

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា

# ភាសាខ្មែរ

នាយកដ្ឋានអប់រំកុមារតូច

ឆ្នាំ ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ១០៩៨ អយក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សព្វផ្សាយ សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា
## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញប្រកាសលេខ ១១១៩ អយក.ប្រក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋានអប់រំ
- បានឃើញប្រកាសលេខ ៣០២ អយក.ប្រក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស
- តាមសំណើរបស់ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យបោះពុម្ព «**សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា**» ដែលរៀបចំដោយក្រុមការងារបច្ចេកទេស និងកែសម្រួលកម្មវិធីសិក្សា ដើម្បីប្រើប្រាស់ជាសាធារណៈ។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រៈ www.moeys.gov.kh

**ប្រការ២ .-**

សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះ មាន ៥(ប្រាំ) មុខវិជ្ជាគឺៈ

១- ចិត្តចលភាព

២- វិទ្យាសាស្ត្រ

៣- សិក្សាសង្គម

៤- បុរេគណិត

៥- ភាសាខ្មែរ

ខ្លឹមសារលម្អិតនៃសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៣ .-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានអប់រំកុមារតូច ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានធានាគុណភាពអប់រំ និងគ្រប់ប្រធានអង្គភាពដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៨រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ២០២២

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួលៈ**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រី ក្រសួង អយក

"ដើម្បីជូនជ្រាប"

- គ្រប់អង្គភាពក្រោមឱវាទក្រសួង អយក
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- ដូចប្រការ ៣

"ដើម្បីអនុវត្ត"

- ឯកសារ កាលប្បវត្តិ នា.អកត អ.យ.ក

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# សមាសភាពគណៈកម្មការ

## I.គណៈកម្មការគ្រប់គ្រង និងដឹកនាំ

១.ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២.លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

៣.លោកជំទាវ យុន រចនា អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

៤.ឯកឧត្តម ពុធ សាមិត្ថ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ

៥.ឯកឧត្តម ឡោ ឆវណ្ណា អគ្គនាយករងនៃអគ្គនាយកដ្ឋានអប់រំ

៦.ឯកឧត្តម ប្រាក់ កុសល ប្រធាននាយកដ្ឋានអប់រំកុមារតូច

## II.គណៈកម្មការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់

១. លោកស្រី ផ្លុង មុនីកុសល អនុប្រធាននាយកដ្ឋានអប់រំកុមារតូច

២.លោក ឈួន ប៊ុនឈឿន អនុប្រធាននាយកដ្ឋានអប់រំកុមារតូច

៣.លោក ឃិន ធី អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា

៤.លោកបណ្ឌិត ឈូក ច័ន្ទឆាយា អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ

៥.លោក ប៉ាត់ គឹមនីន នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យសិក្សាមជ្ឈឹម

៦.លោកស្រី សេង សុវណ្ណា នាយិការងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យសិក្សាមជ្ឈឹម

## III.គណៈកម្មការនិពន្ធខ្លឹមសារ និងរៀបរៀង

១- លោក ធន ឈាង ប្រធានការិយាល័យមត្តេយ្យសិក្សា

២- លោកស្រី វ៉ន វ៉ាន់ថា ប្រធានការិយាល័យសិក្សា(ស គ ម ម)

៣- លោកស្រី ថោង ច័ន្ទធដា អនុប្រធានការិយាល័យអប់រំកុមារតូច

៤- លោកស្រី ហៀង លក្ខិណា អនុប្រធានការិយាល័យមត្តេយ្យសិក្សា

៥- លោកស្រី គីវ សារៈ អនុប្រធានការិយាល័យពិនិត្យតាមដាន និងវាយតម្លៃ

៦- លោកស្រី ស៊ីន ចន្ទស្រីតូច មន្ត្រីការិយាល័យអប់រំកុមារតូច

៧- កញ្ញា ផែន ពិសី មន្ត្រីការិយាល័យមត្តេយ្យសិក្សា

៨- លោក ស៊ុំ សុភាព មន្ត្រីការិយាល័យផែននិងស្រាវជ្រាវ

៩- ក្រុមការងារបច្ចេកទេសមន្ទីរអប់រំ យុវជន និងកីឡាខេត្ត កំពង់ធំ

១០- ក្រុមការងារបច្ចេកទេសមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ព្រៃវែង

១១- ក្រុមការងារបច្ចេកទេសមន្ទីរអប់រំ យុវជន និងកីឡាខេត្ត ស្ទឹងត្រែង

១២- សមាគមបណ្តុះកុមារ

១៣- អង្គការសន្តិស្ម័គ្រចិត្ត

១៤- អង្គការRTI

១៥- អង្គការផ្លែនអន្តរជាតិ

## IV.គណៈកម្មការសម្របសម្រួល និងផ្គត់ផ្គង់

| | | | |
|---|---|---|---|
| ១.លោកស្រី | រ័ត្ន | ម៉ារិន | ប្រធានការិយាល័យរដ្ឋបាល |
| ២.លោក | ណាយ | សុចិត្រា | អនុប្រធានការិយាល័យរដ្ឋបាល |
| ៣.លោក | លី | ចាន់ថុល | អនុប្រធានការិយាល័យរដ្ឋបាល |
| ៤.លោក | ទៀង | សុភាព | អនុប្រធានការិយាល័យរដ្ឋបាល |
| ៥.លោក | យូ | តុនី | មន្ត្រីការិយាល័យរដ្ឋបាល |
| ៦.លោក | សៅ | ដារ៉ុដ | មន្ត្រីការិយាល័យរដ្ឋបាល |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការកែលម្អកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ស្របទៅនឹងក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស សំដៅពង្រឹងការកសាងធនធានមនុស្សប្រកបដោយសក្តានុពល ក្នុងគោលដៅឆ្ពោះទៅកាន់សង្គមពុទ្ធិ និងវិបុលភាព ជានាបាននូវកម្លាំងពលកម្ម ដែលមានចំណេះដឹង បំណិន ជំនាញវិជ្ជាជីវៈ មានវប្បធម៌ជ្រៅជ្រះ មានផលិតភាព និងភាពប្រកួតប្រជែងខ្ពស់ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសកលភាវូបនីយកម្ម ឆ្លើយតបយ៉ាងសមស្រប និងទាន់ពេលវេលាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងសេចក្តីត្រូវការរបស់ប្រទេសជាតិ ជាពិសេសក្នុងពេលដែលកម្ពុជាបានកំណត់ចក្ខុវិស័យប្រែក្លាយពីប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបនាបច្ចុប្បន្ន ទៅជាប្រទេសដែលមានប្រាក់ចំណូលកម្រិតមធ្យមនៅឆ្នាំ២០៣០ និងក្លាយទៅជាប្រទេសអភិវឌ្ឍន៍នៅឆ្នាំ២០៥០។

ផ្អែកលើមូលដ្ឋាននេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ជាយន្តការអនុវត្តកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ពង្រឹងនិងលើកកម្ពស់ការបង្រៀននិងរៀន ដើម្បីបណ្តុះសញ្ញាណ ឧបនិស្ស័យ បុគ្គលិកលក្ខណៈ និងបំណិនសតវត្សរ៍ទី២១ ដល់កុមារតូច ឱ្យប្រែក្លាយជាពលរដ្ឋពេញលេញនៅពេលអនាគត។

សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះ ត្រូវបានបញ្ចូលខ្លឹមសារសំខាន់ៗទាក់ទងនឹងគរុកោសល្យ ដើម្បីឆ្លើយតបសមភាពយេនឌ័ររវាងកុមារីនិងកុមារ ដែលមានទិដ្ឋភាពគ្រប់ដណ្តប់ទាំងផ្នែកទ្រឹស្តីនៃការអប់រំកុមារតូច និងវិធីសាស្ត្រអនុវត្តការបង្រៀននិងរៀននៅគ្រប់កម្រិតមត្តេយ្យសិក្សា ក្នុងន័យអភិវឌ្ឍសមត្ថភាពកុមារតូចលើផ្នែករាងកាយ និងសុខភាព ផ្នែកសីលធម៌ និងវប្បធម៌ ផ្នែកចិត្តសង្គម និងអារម្មណ៍ ផ្នែកពិចារណា និងការយល់ដឹង និងផ្នែកភាសា ដែលជាមូលដ្ឋានគ្រឹះក្នុងការជួយកុមារតូច ឆ្ពោះទៅបន្តការសិក្សា ប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិត។

ក្រសួងអប់រំ យុវជន និងកីឡា មានសុទិដ្ឋិនិយមថា គ្រប់អង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ នឹងចូលរួមសហការនិងគាំទ្រដល់ការអនុវត្តសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់កុមារតូចនៅកម្ពុជា ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា និងដៃគូអភិវឌ្ឍ ជាពិសេសអង្គការ **Plan International** ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួម និងដើរតួនាទីស្នូលក្នុងការសម្របសម្រួល ដឹកនាំរៀបចំតាក់តែងសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សានេះឱ្យសម្រេចជាផ្លែផ្កាឡើងនាខណៈនេះ។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើមូលដ្ឋានីយកម្មក្របខណ្ឌកម្មវិធិសិក្សាចាប់កម្រិតមត្តេយ្យសិក្សារហូតដល់មធ្យមសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស និងបានដាក់ចេញវិធានជាយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា សំដៅជានាប្រសិទ្ធភាព និងគុណភាពលទ្ធផលសិក្សានៅគ្រប់កម្រិត។

ទន្ទឹមនឹងនេះ សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ត្រូវបានក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា ដោយមានចូលរួមពីអង្គភាពថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសកិច្ចសហការគាំទ្រទាំងផ្នែកបច្ចេកទេស និងធនធានថវិកាពីអង្គការ **Plan International** រៀបចំឡើងក្នុងគោលដៅលើកកម្ពស់ស័ក្តសិទ្ធភាព នៃដំណើរការសកម្មភាពបង្រៀននិងរៀន ឱ្យមានភាពកាន់តែប្រសើរឡើងនៅកម្រិតមត្តេយ្យសិក្សា។

សៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា មាន ៥(ប្រាំ) មុខវិជ្ជាគឺ **មុខវិជ្ជាចិត្តចលភាព មុខវិជ្ជាវិទ្យាសាស្ត្រ មុខវិជ្ជាសិក្សាសង្គម មុខវិជ្ជាបុរេគណិត និងមុខវិជ្ជាភាសាខ្មែរ**។ ក្រុមការងារ បានសិក្សាប្រមូលដកស្រង់ខ្លឹមសារពីឯកសារពាក់ព័ន្ធចាំបាច់ក្នុងបរិបទប្រទេសកម្ពុជា ប្រៀបធៀបទៅនឹងបរិបទបណ្តាប្រទេសមួយចំនួនក្នុងតំបន់ ធ្វើការបន្សុំ និងសំយោគ ដើម្បីប្រែក្លាយពីទ្រឹស្តីនៃការអប់រំកុមារតូច ទៅជាវិធីសាស្ត្របង្រៀននិងរៀនជាក់ស្តែងនៅកម្រិតមត្តេយ្យសិក្សា។ សៀវភៅសិក្សាគោលនេះ បានបង្ហាញនិងលើកឡើងពីទស្សនាទានទូទៅនៃសកម្មភាពបង្រៀននិងរៀននៅកម្រិតមត្តេយ្យសិក្សា គោលដៅសិក្សាតាមមុខវិជ្ជានីមួយៗ វិធីសាស្ត្របង្រៀននិងរៀន ការរៀបចំបរិស្ថាន សាលា/ថ្នាក់មត្តេយ្យសិក្សា និងវង្វាយតម្លៃលទ្ធផលសិក្សារបស់កុមារ ព្រមទាំងគរុកោសល្យបង្រៀននិងរៀន ដើម្បីឆ្លើយតបសមភាពយេនឌ័ររវាងកុមារីនិងកុមារានៅមត្តេយ្យសិក្សា។

ក្នុងនាមក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា យើងខ្ញុំ សូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជូនចំពោះ**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដែលជាមគ្គុទេសក៍ដ៏ឆ្នើម ប្រកបដោយឆន្ទៈមុតស្រួចលើការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ និងដឹកនាំការអភិវឌ្ឍវិស័យអប់រំ ប្រកបដោយវឌ្ឍនភាពជាបន្តបន្ទាប់ក្នុងចក្ខុវិស័យវែងឆ្ងាយ។ ជាមួយនេះ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេសអង្គការ **Plan International** ដែលបានគាំទ្រ និងសម្របសម្រួលការរៀបចំតាក់តែង និងអភិវឌ្ឍសៀវភៅសិក្សាគោលសម្រាប់មត្តេយ្យសិក្សា ដ៏មានសារសំខាន់នេះ រហូតសម្រេចបានជាស្ថាពរ។

**ក្រុមការងារបច្ចេកទេសពិនិត្យឡើងវិញ**
**និងកែសម្រួលកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សា**

គឹម សេដ្ឋានី

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## មាតិកា


**ប្រកាស** .......... I

**សមាសភាពគណៈកម្មការ** .......... III

**បុព្វកថា** .......... V

**អារម្ភកថា** .......... VI

**មាតិកា** .......... VII

**បញ្ជីរូបភាព** .......... IX

**សន្ទានុក្រម** .......... X

**សេចក្តីផ្តើម** .......... 1

**ជំពូក១**

**ទស្សនាទាននៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរ**

១.១.ទស្សនាទានទូទៅ .......... 2

១.២. ការវិវឌ្ឍខួរក្បាលកុមារ .......... 2

១.៣. ទស្សនៈ និងរបកគំហើញក្នុងបរិបទថ្មី .......... 3

១.៤. អន្តរបញ្ញត្តិភាសាខ្មែរសម្រាប់កុមារ .......... 3

១.៥. អន្តរាគមន៍គ្រប់ជ្រុងជ្រោយសម្រាប់កុមារ .......... 4

**ជំពូក២**

**គោលដៅសិក្សានៃមុខវិជ្ជាភាសាខ្មែរ**

២.១. ក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពរបស់កុមារ .......... 6

២.២. ការផ្សារភ្ជាប់ទៅនឹងបរិបទវិទ្យាសាស្ត្រ និងជីវភាពរស់នៅ .......... 6

២.៣. ការបណ្តុះស្មារតីកុមារ .......... 7

**ជំពូក៣**

**វិធីសាស្ត្រអនុវត្តការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរ**

៣.១. សញ្ញាណភាសាខ្មែរនៅមត្តេយ្យសិក្សា .......... 8

៣.២. បញ្ញត្តិកម្មរបស់ភាសាខ្មែរនៅកម្រិតមត្តេយ្យសិក្សា .......... 8

៣.៣. វិធីសាស្ត្របង្រៀនភាសារខ្មែរនៅមត្តេយ្យសិក្សា .......... 11

**៣.៤.១ បុរេសំណេរ** .......... 11

**៣.៤.២ រឿងនិទាន** .......... 17

**៣.៤.៣ កំណាព្យ** .......... 30

**ជំពូក៤**

**ការរៀបចំបរិស្ថានសិក្សា នៃមុខវិជ្ជាភាសាខ្មែរ**

៤.១. យន្តការអនុវត្ត .......... 36

៤.២. តម្រូវការធនធានសម្ភាររូបវន្តសិក្សា .......... 36

៤.៣. គោលការណ៍ ឬបញ្ញត្តិប្រតិបត្តិ........................................................................ 37
៤.៤. ការស្វែងរកការគាំទ្រផ្សេងៗ ............................................................................ 37

## ជំពូក៥
## ការពិនិត្យតាមដាន និងវាយតម្លៃ

៥.១. ចំពោះគ្រូ .................................................................................................. 38
៥.២.ចំពោះកុមារ ................................................................................................ 38
**ឧបសម្ព័ន្ធទី ២ គរុកោសល្យរៀន និងបង្រៀន**............................................................78
**គន្លងនិទ្ទេស** ....................................................................................................90

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

# បញ្ជីរូបភាព

រូបភាពទី 1៖ ទឹកកកក្នុងកែវ ..... 13
រូបភាពទី 2៖ ការបង្រៀនល្បែងបុរសំណេរ ..... 15
រូបភាពទី 3៖ល្បែងឡុកឡាក់អំពី ស្រះ ..... 16
រូបភាពទី 4៖ ការនិទានរឿងដោយផ្ទាល់មាត់ ..... 21
រូបភាពទី 5៖ ការនិទានរឿងដោយប្រើសៀវភៅរូបភាព ..... 22
រូបភាពទី 6៖ ការនិទានរឿងដោយប្រើផ្ទាំងរូបភាព ..... 23
រូបភាពទី 7៖ ការនិទានរឿងដោយប្រើផ្ទាំងសំពត់សំឡី ឬអាវអៀម ..... 24
រូបភាពទី 8៖ ការនិទានរឿងដោយប្រើតុក្កតាឬអាយ៉ង ..... 24
រូបភាពទី 9៖ ការនិទានរឿងបណ្តើរគូររូបបណ្តើរ ..... 25
រូបភាពទី 10៖ ការសម្តែងតួតាមសាច់រឿង ..... 25
រូបភាពទី11 ៖ ក្រោយពេលនិទានរឿង ..... 28
រូបភាពទី 12៖ លំនាំនៃការបង្រៀននិងរៀនកំណាព្យ ..... 34

# សទ្ទានុក្រម

១.ឥន្ទ្រីយ៍ចលករ ៖ ការសម្ដែងចេញនូវចលនាជាសកម្មភាពមួយ ដែលសរីរាង្គវិញ្ញាណបានចាប់អារម្មណ៍។ ឧ៖ក្មេកមើលឃើញ និងនិយាយថាអាវក្រហម។

២.បុរេប្រតិបត្តិ ៖ ការចាប់ផ្ដើមអនុវត្តសកម្មភាពងាយៗដំបូងដែលជាមូលដ្ឋានគ្រឹះឈានទៅអនុវត្តសកម្មភាពរួមមួយ ។ឧ៖ល្បែង«យើងធ្វើផ្លូវដើរ» កុមារប្រើមេដៃ និងចង្អុលដៃចាប់គ្រាប់ក្រួសតម្រៀបលើផ្លូវដើរដើម្បីពង្រឹងចលនាម្រាមដៃមុននឹងចាប់កាន់ ខ្មៅដៃគូសគំនូរម្ចូដ្ឋាន។

៣.មជ្ឈត្តនិយម ៖ ការតាំងខ្លួនជាអ្នកមានឥទ្ធិពល ដែលមនុស្សជុំវិញខ្លួនត្រូវតែបំពេញតាមតម្រូវការរបស់ខ្លួនគ្រប់បែបយ៉ាង។

៤.អន្តរសកម្មសង្គម ៖ ការតាំងខ្លួនជាកណ្ដាលរវាងមនុស្សជុំវិញក្នុងការផ្ដល់ ទទួលព័ត៌មាន និងឆ្លើយតបសកម្មភាពចុះឡើងដើម្បីសម្រេចគោលដៅមួយ។

៥.ប្រតិបត្តិរៀបរយ ៖ ការអនុវត្តតាមលំដាប់លំដោយនៃសកម្មភាពមួយប្រកបដោយជោគជ័យ។

៦.ភ្លោច ៖ សំដៅដល់ប្រព័ន្ធប្រសាទទាំងមូលដែលប្រតិកម្មភ្លាមទៅរកទិសនៃរំញោច។

៧.អន្តរបញ្ញត្តិ ៖ សេចក្ដីដែលរៀបចំបានទ្រឹស្ដីមួយពោរពេញដោយខ្លឹមសារទំនាក់ទំនងគ្នារវាងខ្លឹមសារទៅខ្លឹមសារផ្សេងៗដែលអាចជួយឱ្យសម្រេចបានគោលដៅ។

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

# សេចក្តីផ្តើម

## គោលបំណងៈ

ដើម្បីធានាបានការអប់រំប្រកបដោយបរិយាបន្ន សមធម៌ យេនឌ័រ និងលើកកម្ពស់ ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ជាពិសេសគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កំណត់ថានៅឆ្នាំ ២០៣០ ធានាថាកុមារទាំងអស់ទទួលបានការអប់រំ កម្រិតមត្តេយ្យសិក្សា ការថែទាំ ការអភិវឌ្ឍកុមារតូចប្រកបដោយគុណភាព ដើម្បីបានត្រៀមខ្លួនជាស្រេចចូលរៀននៅកម្រិតបឋមសិក្សា និងធ្វើឱ្យសម្រេចបានតាមលទ្ធផលរំពឹងទុក នៅក្នុងកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សា ផ្នែកភាសាខ្មែរ។

## គោលដៅរួមនៃការសិក្សាៈ

កុមារមត្តេយ្យសិក្សា មានសមត្ថភាពប្រើប្រាស់ភាសាខ្មែរបានច្បាស់លាស់ត្រឹមត្រូវតាមកម្រិតវ័យរបស់ពួកគេ ក្នុងការប្រាស្រ័យទាក់ទងជាមួយអ្នកនៅជុំវិញខ្លួន និងការសិក្សារៀនសូត្រប្រកបដោយប្រសិទ្ធភាព។

កុមារទទួលបានបំណិននិយាយនិងស្តាប់ គឺផ្តើមចេញពីពាក្យពេចន៍ ឃ្លា ល្បះងាយៗ សម្រាប់ធ្វើការប្រាស្រ័យទាក់ទងជាមួយអ្នកនៅជុំវិញខ្លួន។ ចំណែកបំណិន អាននិងសរសេរ គឺផ្តើមចេញពីការស្គាល់ សំណេរក្នុងសៀវភៅ ទិសអំណាន ផ្នែករបស់សៀវភៅ និងការគូសគំនូសមូលដ្ឋាន ការគូរបំពេញចំណែកដែលបាត់ ការគូសតាមស្នាមចុច និងការសរសេរអក្សរដែលបានកំណត់ក្នុងកម្មវិធីសិក្សាលម្អិត។

ពេលកុមារបញ្ចប់ការរៀនភាសាខ្មែរនៅមត្តេយ្យសិក្សា ពួកគេនឹងមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ការសិក្សានៅកម្រិតសាលាបឋមសិក្សា និងកម្រិតថ្នាក់បន្តបន្ទាប់ទៀត។ ភាសាខ្មែរត្រូវបានប្រើប្រាស់សម្រាប់ការសិក្សា នៅគ្រប់ភូមិសិក្សាទាំងអស់។ ដូច្នេះវាពិតជាមានសារៈសំខាន់ណាស់ សម្រាប់កុមារគ្រប់រូបក្នុងការរៀនសូត្រចេះដឹងភាសាជាតិជាមុនដំបូងគេបង្អស់។

## សារៈប្រយោជន៍ៈ

ភាសាខ្មែរជាមរតកដ៏មានតម្លៃផ្នែកវប្បធម៌ ដែលបុព្វបុរសខ្មែរបានបង្កើតឡើង តាំងពីបូរាណកាលមក។ ជនជាតិខ្មែរបានប្រើភាសាខ្មែរក្នុងការកត់ត្រាៈ រឿងរ៉ាវប្រវត្តិសាស្ត្រ ក្បួនសិកសង្គ្រាម ក្បួនច្បាប់វេយ្យាករណ៍ អក្សរសិល្ប៍ ក្បួនហោរាសាស្ត្រ គម្ពីរសាសនា ច្បាប់ទូន្មានកូនចៅ ច្បាប់គ្រប់គ្រងរដ្ឋ និងហេតុការផ្សេងៗពីសង្គមរបស់ខ្លួនដើម្បីទុកឱ្យអ្នកជំនាន់ក្រោយបានយល់ដឹងនិងសិក្សារៀនសូត្របន្ត។

ភាសាខ្មែរឆ្លុះបញ្ចាំងពីអត្តសញ្ញាណជាតិខ្មែរ ហើយភាសាខ្មែរជាភាសាផ្លូវការ និងជាភាសាយានសម្រាប់ធ្វើការសិក្សារៀនសូត្រផងដែរ។

ភាសាខ្មែរ ជាមធ្យោបាយសម្រាប់ទំនាក់ទំនងរបស់ខេមរជន ដើម្បីផ្សព្វផ្សាយគំនិត ព័ត៌មានបទពិសោធ ឱ្យគ្នាទៅវិញទៅមក ព្រោះមនុស្សប្រើភាសាស្ទើរតែគ្រប់ពេលវេលាជាមួយនឹងអ្នកដទៃ។

## វិសាលភាពៈ

សៀវភៅនេះ មានវិសាលភាពគ្របដណ្តប់ លើគ្រប់ការផ្តល់សេវាមត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាឯកជន ឬទម្រង់មត្តេយ្យសិក្សាដទៃទៀត ដែលមាននៅក្នុង ព្រះរាជាណាចក្រកម្ពុជា។ សេវាទាំងអស់នោះ អាចយកទៅប្រើប្រាស់ដើម្បីបង្ហាត់បង្រៀននៅតាមថ្នាក់និងសាលាមត្តេយ្យសិក្សារបស់ខ្លួន សម្រាប់ជួយអប់រំបណ្តុះបណ្តាលដល់កុមារតូច ឱ្យមានការអភិវឌ្ឍបានគ្រប់ជ្រុងជ្រោយ។ ជាងនេះទៀត ក៏អាចយកទៅអនុវត្តនៅទីណា ដែលមានកុមារខ្មែរ ឬក៏កុមារជនជាតិបរទេសដែលចង់រៀនភាសាខ្មែរ អាស្រ័យតាមសភាពជាក់ស្តែង។

# ជំពូក១

# ទស្សនាទាននៃការបង្រៀន និងរៀន

# មុខវិជ្ជាភាសាខ្មែរ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

# ជំពូក១ ទស្សនាទាននៃការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរ

## ១.១.ទស្សនាទានទូទៅ

នៅក្នុងការសិក្សារៀនសូត្រ ពីកម្រិតមត្តេយ្យសិក្សារហូតដល់ឧត្តមសិក្សា មុខវិជ្ជាដែលសិស្សរៀនត្រូវបានបែងចែកជាច្រើនមុខវិជ្ជា គឺអាស្រ័យតាមសម័យកាល និងប្រព័ន្ធអប់រំរបស់ប្រទេសនីមួយៗ។ មុខវិជ្ជាមួយចំនួនក្នុងកម្មវិធីសិក្សា អាចផ្លាស់ប្តូរទៅតាមសម័យកាល ជួនកាលសម័យកាលខ្លះមាននិងសម័យកាលខ្លះទៀតបែរជាគ្មានវិញ តែចំពោះមុខវិជ្ជាភាសាខ្មែរ គឺមិនមានការផ្លាស់ប្តូរទេ ព្រោះថាមុខវិជ្ជាភាសាខ្មែរជាមុខវិជ្ជាសំខាន់ចម្បងទី១ ដែលមានតួនាទីបម្រើដល់គ្រប់មុខវិជ្ជាផ្សេងៗទៀតទាំងអស់ បើមិនមានមុខវិជ្ជានេះទេ មុខវិជ្ជាដទៃទៀតមិនអាចសិក្សាបានឡើយ។ ដូច្នេះមុខវិជ្ជាភាសាខ្មែរ មានសារៈសំខាន់ណាស់ ចំពោះកុមារមត្តេយ្យសិក្សាគ្រប់រូប ដោយហេតុថាវាជាមូលដ្ឋានគ្រឹះនៃការសិក្សាភាសា ក្នុងគ្រាដំបូងសម្រាប់ជីវិតរបស់ពួកគេម្នាក់ៗ ប្រកបដោយការជឿទុកចិត្ត។ ការនិយាយ ឬប្រើភាសានៅផ្ទះ ឬក្នុងសហគមន៍ ជាការប្រើប្រាស់តាមភាពសេរីមិនទាន់មានការរៀបរយទាំងស្រុងទេ តែការរៀនភាសានៅសាលា គឺជាការរៀនភាសាដែលមានការរៀបរយតាមក្បួនច្បាប់វេយ្យាករណ៍ច្បាស់លាស់។

សៀវភៅសិក្សាគោលភាសាខ្មែរសម្រាប់មត្តេយ្យសិក្សា រៀបចំឡើងដើម្បីជំនួយដល់គ្រូមត្តេយ្យសិក្សា ក្នុងការបង្រៀនភាសាខ្មែរ ដល់កុមារមត្តេយ្យសិក្សាផ្តោតលើ ការសម្គាល់តួអក្សរ ល្បែងបុរេសំណេរ (ឱ្យកុមារចាប់ផ្តើមការសរសេរ ដោយគូរតាម ដើម្បីឱ្យកុមារមានមូលដ្ឋានគ្រឹះមុននឹងរៀនថ្នាក់ទី១នៃសាលាបឋមសិក្សា) រឿងនិទាន អំណានរឿង និងកំណាព្យ ដែលផ្នែកនីមួយៗមានមេរៀនទាក់ទងនឹងប្រធានបទផ្សេងៗ។

ក្នុងកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ បានកំណត់រយៈពេលនៃការបង្រៀននិងរៀនចំនួន៣៥សប្តាហ៍ ក្នុងមួយឆ្នាំសិក្សា ចំនួន៥ថ្ងៃក្នុងមួយសប្តាហ៍ និងចំនួន៦ម៉ោងសិក្សាក្នុងមួយថ្ងៃ (៣០នាទីក្នុងមួយម៉ោងសិក្សា)។ ចំពោះម៉ោងបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរទាំងបីកម្រិត មានចំនួន៤ម៉ោងក្នុងមួយសប្តាហ៍ និង ម៉ោងសរុបប្រចាំឆ្នាំសិក្សា មានចំនួន១៤០ម៉ោងសិក្សា។

## ១.២. ការវិវឌ្ឍខួរក្បាលកុមារ

កុមារអាយុពី២-៣ឆ្នាំ អាចនិយាយក្នុងប្រយោគវែងនិងស្មុគស្មាញជាងមុន ហើយកាន់តែប្រសើរឡើងក្នុងការនិយាយពាក្យបានត្រឹមត្រូវ ហើយកុមារអាចលេងនិងនិយាយក្នុងពេលតែមួយ។

កុមារអាយុពី៣-៥ឆ្នាំ អាចរំពឹងថានឹងមានការសន្ទនាបានយូរ ជាងកាលពីពួកគេមានអាយុ ២ ឬ៣ឆ្នាំ។ ឧទាហរណ៍៖ កុមារអាចនិយាយដូចជា "ខ្ញុំនឹងលូតលាស់ទៅធំប៉ុនបងប្រុស ដោយសារខ្ញុំញ៉ាំអាហាររាល់ថ្ងៃ" កុមារក៏ប្រហែលជាចង់និយាយ អំពីប្រធានបទជាច្រើនដែរ ហើយវាក្យសព្ទនឹងកាន់តែរីកចម្រើន។ កុមារអាយុក្នុងវ័យនេះ អាចបង្ហាញការយល់ដឹងមូលដ្ឋានគ្រឹះអំពីវេយ្យាករណ៍ នៅពេលពួកគេបាននិយាយជាមួយប្រយោគស្មុគស្មាញ ដែលមានពាក្យដូចជា "ពីព្រោះ ប្រសិនបើ ដូច្នេះ ឬនៅពេលនោះ"។

កុមារអាយុពី៥-៨ឆ្នាំ ក្នុងងកំឡុងពេលសិក្សាដំបូង នឹងរៀនពាក្យកាន់តែច្រើន ហើយចាប់ផ្តើមយល់ពីសូរសំឡេងនៅក្នុងភាសា។ កុមារក៏នឹងអាចក្លាយជា អ្នកនិទានរឿងដ៏ល្អប្រសើរដែរ ដោយសារពួកគេរៀនផ្គុំពាក្យបញ្ចូលគ្នាតាមរបៀបនានា និងបង្កើតប្រយោគផ្សេងៗ ហើយក៏ធ្វើឱ្យកុមារអាចចែករំលែកគំនិតយោបល់ ឬអាចមានការសន្ទនាបានពេញលេញ ដូចមនុស្សពេញវ័យផងដែរ។

## ១.៣. ទស្សនៈ និងរបកគំហើញក្នុងបរិបទថ្មី

ការធ្វើសាកលភាវូបនីយកម្ម គឺបណ្តាប្រទេសនានាទាំងអស់ បានពួតដៃគ្នាធ្វើអ្វីៗឱ្យមានភាពស៊ីសង្វាក់គ្នា។ នោះបានសេចក្តីថា បញ្ហាចម្បងៗដែលត្រូវយកចិត្តទុកដាក់ និងត្រូវលើកយកមកដោះស្រាយសម្រាប់ប្រទេសនីមួយៗ គឺត្រូវមានឈ្មោះកញ្ចប់ឬចង្កោមបញ្ហាដូចគ្នា។ ពីព្រោះមានភាពងាយស្រួលក្នុងការចែករំលែក បទពិសោធឱ្យគ្នាទៅវិញទៅមក ងាយធ្វើការពិភាក្សាឱ្យបានស៊ីជម្រៅ ងាយស្រួលដល់ការជួយផ្តល់ការគាំទ្រ និងអាចស្វែងយល់បានពីឧបសគ្គរាំងស្ទះ ដែលកើតមានតាមលក្ខខណ្ឌដោយឡែក ឬលក្ខខណ្ឌរួមរបស់បណ្តាប្រទេសនីមួយៗ។ មនុស្សម្នាក់ៗ កើតមកហើយតែងតែភ្ជាប់នូវភាសាមកជាមួយចាប់តាំងពីពេលកើតមកម្លេះ ហើយភាសាលូតលាស់ទៅតាមវ័យរបស់គេ។ ដើម្បីឱ្យភាសាលូតលាស់កាន់តែប្រសើរឡើងសម្រាប់កុមារតូចនោះ ទើបនៅមត្តេយ្យសិក្សាបានបញ្ចូលមុខវិជ្ជាភាសាខ្មែរ នៅក្នុងកម្មវិធីសិក្សាដើម្បីត្រៀមលក្ខណៈចូលរៀនថ្នាក់ទី១ នៅសាលាបឋមសិក្សា។

ដើម្បីសម្រេចបានលទ្ធផលតាមគោលដៅ៤.២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ផ្នែកអប់រំកុមារតូច គឺទាមទារការពង្រឹងឱ្យបានខ្លាំងលើស្តង់ដាគ្រូបង្រៀន។ ម្យ៉ាងទៀត គ្រូត្រូវចងចាំ និងយល់ដឹង ឱ្យបានច្បាស់នូវបំណិនសតវត្សទី២១ ពីអ្វីដែលសិស្សត្រូវរៀនមាន៖

- **មូលដ្ឋានគ្រឹះអក្ខរកម្ម** (អក្ខរកម្ម នព្វន្ត វិទ្យាសាស្ត្រ ហិរញ្ញវត្ថុ វប្បធម៌ និងពលរដ្ឋ)
- **សមត្ថភាព** (ការគិតប្រកបដោយការត្រិះរិះ ការដោះស្រាយបញ្ហា ការច្នៃប្រឌិត ទំនាក់ទំនង និងកិច្ចសហការ)
- **លក្ខណៈបុគ្គលិក** (ការចង់ចេះចង់ដឹង ការផ្តួចផ្តើមគំនិត ភាពអំណត់ មានភាពបត់បែន ភាពជាអ្នកដឹកនាំ ការយល់ដឹងពីសង្គមនិងវប្បធម៌ )

កុមារអាយុ៣ឆ្នាំ ភាគច្រើនចេះប្រើពាក្យពេចន៍យ៉ាងសកម្ម និងអាចនិយាយប្រយោគ ដែលមាន៥ ឬ៦ពាក្យ ហើយអាចធ្វើត្រាប់តាម សូរសំឡេងនិយាយរបស់មនុស្សពេញវ័យ បានភាគច្រើន។ កុមារអាយុ៤ឆ្នាំអាចចាំសាច់រឿងបានច្រើន ដែលមានប្រយោគស្មុគស្មាញ។ ចំណែកកុមារដែលមានអាយុ៥ឆ្នាំ មានការចងចាំសាច់រឿង និងយល់ន័យបានស៊ីជម្រៅល្អប្រសើរជាងកុមារអាយុ៤ឆ្នាំ ហើយពួកគេជាអ្នកពូកែសួរផងដែរ។

ចំពោះការបង្រៀនមូលដ្ឋានគ្រឹះភាសាខ្មែរ ដល់កុមារមត្តេយ្យ ត្រូវចាប់ផ្តើមដោយផ្តោតលើសមត្ថភាពទាំង៤នៃភាសា គឺសមត្ថភាពនិយាយ សមត្ថភាពស្តាប់ សមត្ថភាពសរសេរ និងសមត្ថភាពអាន។ ការបង្រៀនត្រូវមានកិច្ចតែងការ សម្ភារឧបទេស និងវិធីសាស្ត្រដែលត្រូវបង្រៀន។

ដូច្នេះគ្រូបង្រៀនត្រូវប្រកាន់ខ្ជាប់នូវ ចិត្តគរុកោសល្យនិងវិធីសាស្ត្របង្រៀន សម្រាប់មត្តេយ្យសិក្សាដោយមិនធ្វើឱ្យប្រាស់ចាកពីគោលការណ៍បង្រៀននៅមត្តេយ្យសិក្សាឡើយ។

## ១.៤. អន្តរបញ្ញត្តិភាសាខ្មែរសម្រាប់កុមារ

ជាទូទៅការសិក្សាភាសាគឺ ផ្តោតលើសមត្ថភាពបួនរួមមាន៖ សមត្ថភាពស្តាប់ សមត្ថភាពនិយាយ សមត្ថភាពអាន និងសមត្ថភាពសរសេរ ហើយសមត្ថភាពទាំងបួននេះ មានទំនាក់ទំនងនឹងគ្នាយ៉ាងជិតស្និទ្ធ ដែលតែងតែបំពេញឱ្យគ្នាទៅវិញទៅមក តាមលក្ខខណ្ឌតម្រូវរបស់វា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

❖ **សមត្ថភាពស្តាប់** គឺជាការទទួលយកព័ត៌មានទាំងឡាយណាដោយសោតវិញ្ញាណ។ ការស្តាប់ដើម្បីយល់ដឹង គឺមានភាពជ្រាលជ្រៅជាងការឮអ្វីដែលគេបាននិយាយ ហើយការស្តាប់ដើម្បីយល់ដឹង វាជាសមត្ថភាពស្តាប់របស់កុមារ ក្នុងការយល់អត្ថន័យ នៃពាក្យដែលគេបានស្តាប់ពីនរណាម្នាក់ ឬតាមមធ្យោបាយផ្សេងៗ។ នៅពេលកុមារស្តាប់រឿងរ៉ាវ គឺគេស្តាប់ដើម្បីយល់ដឹងសាច់រឿង ចងចាំសាច់រឿង ហើយថែមទាំងនិយាយវាឡើងវិញផង។

❖ **សមត្ថភាពនិយាយ** គឺជាការបញ្ចេញគំនិតឬពណ៌នាអ្វីៗដោយប្រើប្រាស់ភាសា បានត្រឹមត្រូវច្បាស់លាស់និងស្ទាត់ជំនាញ ដោយប្រើពាក្យពេចន៍ ឃ្លា ល្បះ ផ្ទាល់របស់កុមារខ្លួន។ សមត្ថភាពនិយាយ បញ្ជាក់ពីភាពប៉ិនប្រសប់ក្នុងការនិយាយ តាមស្ថានភាពនីមួយៗ។ គ្រូឬអ្នកនៅជុំវិញកុមារ ត្រូវនិយាយទៅកាន់កុមារដោយផ្ទាល់នៅចំពោះមុខ ប្រើពាក្យពេចន៍ដែលសម្គាល់ឈ្មោះមនុស្សគឺមានម្ចាស់ឈ្មោះ និងឈ្មោះវត្ថុត្រូវមានវត្ថុបង្ហាញឱ្យកុមារឃើញ ព្រោះថាកុមារនិយាយតាមការឃើញនិងស្តាប់ឮ នូវពាក្យពេចន៍សម្គាល់ឈ្មោះមនុស្ស (ជាពិសេសឈ្មោះកុមារសំខាន់ណាស់) និងឈ្មោះវត្ថុ ដែលគេអាចនិយាយម្តងហើយម្តងទៀត ជាប្រយោគផ្សេងៗគ្នា និងធ្វើឱ្យគេចេះនិងយល់ន័យបានពាក្យច្រើន។ កុមារមាន សមត្ថភាពនិយាយពូកែ តែងតែទទួលបានការស្រឡាញ់រាប់អាន និងមានទំនាក់ទំនងល្អជាមិត្តភាព ជាមួយកុមារផ្សេងៗទៀត និងមនុស្សដែលនៅជុំវិញខ្លួន។

❖ **សមត្ថភាពអាន (បុរេអំណាន)**គឺជាបំណិនសំខាន់មួយសម្រាប់ការរៀនសូត្រ ដែលជួយកុមារមត្តេយ្យសិក្សាយល់ដឹងពីភាពខុសគ្នារវាងសូរនៃតួអក្សរ ដោយប្រើភ្នែកនិងត្រចៀក ធ្វើការកត់សម្គាល់និងការចងចាំតាមរយៈការសង្កេតមើលនិងការស្តាប់។ កុមារមត្តេយ្យសិក្សានឹងយល់ដឹងពី ការកាន់សៀវភៅ ការបើកសៀវភៅ និងទិសនៃអំណាន ភាសាខ្មែរ ដែលធ្វើឱ្យគេស្រឡាញ់ការអាន ព្រោះថាការអានទទ្ទឹមនឹងផ្តល់ចំណេះដឹង ក៏បានផ្តល់នូវភាពកំសាន្តពីក្នុងនោះដែរ ហើយថែមទាំងនាំឱ្យជីវិតអនាគតរបស់គេពោរពេញដោយអត្ថប្រយោជន៍ទៀតផង។

❖ **សមត្ថភាពសរសេរ(បុរេសំណេរ)**គឺជាបំណិនគ្រឹះដែលកុមារត្រូវការអភិវឌ្ឍ មុននឹងឈានទៅដល់អាចសរសេរបានពេញលេញ។ បំណិននេះផ្តល់ឱ្យកុមារមានសមត្ថភាណក្នុងការកាន់និងប្រើប្រាស់ខ្មៅដៃដើម្បីគូររូបភាពផ្សេងៗ ផាត់ពណ៌ សរសេរចម្លងតាមអក្សរ ពាក្យនានា ក្នុងភាសាខ្មែរបានច្បាស់លាស់។

### ១.៥. អន្តរាគមន៍គ្រប់ជ្រុងជ្រោយសម្រាប់កុមារ

ការសិក្សាភាសាខ្មែរ គឺទាមទារការចូលរួមគ្រប់អ្នកពាក់ព័ន្ធ ដែលនៅជុំវិញកុមារ ជួយផ្តល់ការគាំទ្រ និងលើកទឹកចិត្តកុមារ ឱ្យបញ្ចេញគំនិតយោបល់ តាមរយៈការនិយាយ ការធ្វើសកម្មភាពផ្សេងៗ ទាក់ទងនិងការអភិវឌ្ឍភាសា។ ដូចជា៖ និយាយប្រាប់ឈ្មោះមនុស្សជាសាច់ញាតិក្នុងគ្រួសារ ឬអ្នកជិតខាង ដែលកុមារតែងតែជួបមុខ និងវត្ថុនានា ធម្មជាតិ ជុំវិញខ្លួនកុមារ។ ម្យ៉ាងទៀតដើម្បីឆ្លើយតបសមភាពយេនឌ័រនៅក្នុងមុខវិជ្ជាភាសាខ្មែរ គ្រូមត្តេយ្យសិក្សា ត្រូវយកចិត្តទុកដាក់ ៖

- គ្រូដឹកនាំកុមារទាំងពីរភេទចូលរួមសកម្ម នៅក្នុងសម្មភាពនៃមុខវិជ្ជាភាសាខ្មែរ ដោយបរិយាកាសរីករាយដោយពន្យល់អំពី អត្ថប្រយោជន៍នៃការត្រៀមអាន ត្រៀមសរសេរ ការហាត់ស្តាប់សូរអក្សរ និងការនិយាយពាក្យឱ្យបានច្បាស់លាស់សម្រាប់កុមារទាំងពីរប្រភេទ។

- គ្រូត្រូវសង្កេត និងលើកទឹកចិត្តកុមារទាំងពីរភេទឱ្យសកម្ម ដូចគ្នាក្នុងគ្រប់ប្រភេទសម្មភាព ដោយរំឭកអំពីអត្ថប្រយោជន៍នៃការរៀនភាសាខ្មែរ សម្រាប់ពួកគាត់ទាំងពីរភេទ។
- ផ្ដល់ឱកាសឱ្យកុមារីកុមារា បានសូត្រកំណាព្យ និទានរឿង ច្រៀងរាំ និងធ្វើកាយវិការឱ្យបានស្ទាត់ដូចគ្នាជាពិសេសឱ្យកុមារាអាចធ្វើបានល្អដូច ដែលកុមារីអាចធ្វើបាន។
- សរសើរលើកទឹកចិត្តកុមារីកុមារា នៅពេលដែលពួកគេ អាចច្រៀងរាំ សូត្រកំណាព្យ និងនិទានរឿងបានល្អដូចគ្នា។
- ផ្ដល់ឱកាសឱ្យកុមារបានច្រៀង ឬសូត្រកំណាព្យឆ្លើយឆ្លងគ្នារវាងកុមារី និងកុមារា។
- លើកទឹកចិត្តកុមារី និងកុមារាដែល ធ្វើកិច្ចការមិនទាន់បានល្អ ឱ្យប្រឹងប្រែងបន្តទៀត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ជំពូក២

# គោលដៅសិក្សា នៃមុខវិជ្ជា

# ភាសាខ្មែរ

# ជំពូក២ គោលដៅសិក្សានៃមុខវិជ្ជាភាសាខ្មែរ

## ២.១. ក្របខ័ណ្ឌអភិវឌ្ឍសមត្ថភាពរបស់កុមារ

ការសិក្សារៀនសូត្ររបស់កុមារ គឺផ្ដើមចេញពីញាណលក្ខណៈ ដែលជាគ្រឿងសម្គាល់សេចក្ដីយល់ដឹងរបស់កុមារក៏ដូចជាមនុស្សធំគ្រប់ៗគ្នាដែរ។ បើនិយាយឱ្យចំទៅញាណលក្ខណៈនោះ គឺវិញ្ញាណទាំងប្រាំរបស់មនុស្សយើងនេះតែម្ដង រួមមាន៖ ភ្នែក ត្រចៀក ច្រមុះ អណ្ដាត និងរូបកាយ ដែលជាគ្រឿងបង្កើតឱ្យមានចំណេះដឹងគ្រប់បែបយ៉ាង សម្រាប់កុមារគ្រប់ៗរូប។ ការលេងនិងការធ្វើសកម្មភាពផ្សេងៗ ដោយផ្ទាល់របស់កុមារ នៅក្នុងបរិស្ថានធម្មជាតិ បរិស្ថានសង្គមវប្បធម៌ និងបរិស្ថានមនុស្ស ធ្វើឱ្យកុមារទទួលបាននូវការសិក្សារៀនសូត្រយ៉ាងសកម្ម ពីអ្វីៗច្រើនរាប់មិនអស់ឡើយ នៅក្នុងពិភពលោករបស់ពួកគេ។ តែទោះបីយ៉ាងដូច្នោះក៏ដោយ បើពុំមានរបៀបឬវិធីសាស្ត្រក្នុងការជួយភ្ញោច ឬអប់រំតាមលក្ខណៈវិទ្យាសាស្ត្រជឿនលឿនទេ កុមារនឹងមានការអភិវឌ្ឍមិនបានគាប់ប្រសើរគ្រប់ជ្រុងជ្រោយដែរ។ ហើយអ្វីដែលសំខាន់បំផុត សម្រាប់កុមារក្នុងការឈានទៅសិក្សារៀនសូត្រចំពោះផ្នែកដទៃៗទៀតនោះ គឺមុខវិជ្ជាភាសាខ្មែរ ដែលជាមធ្យោបាយតែមួយគត់ សម្រាប់កុមារយកទៅបម្រើឱ្យមុខវិជ្ជាផ្សេងៗទៀត។ បើកុមារមានសមត្ថភាពផ្នែកសាភាខ្មែរគ្រប់គ្រាន់សម្បូរបែប កុមារនឹងរៀនមុខវិជ្ជាដទៃទៀតបានល្អប្រសើរ។ ខាងក្រោមនេះជាបំណិនសំខាន់ៗមួយចំនួន សម្រាប់កុមារអាយុ៥ឆ្នាំ៖

- ស្ដាប់គេនិយាយនឹងមានសមត្ថភាពស្ដាប់ ដោយធ្វើតាមការណែនាំងាយៗ
- សន្ទនាដោយប្រើពាក្យឬឃ្លាសមស្របទៅតាមវ័យ(ភាសាបង្ហាញអារម្មណ៍និងមនោសញ្ចេតនា)
- ការយល់ពីវាក្យសព្ទ ឃ្លា និងល្បះ
- ទំនាក់ទំនងដោយប្រើកាយវិការ និងនិមិត្តសញ្ញា
- បង្ហាញការយល់ដឹងអំពីភាពខុសគ្នានៃសូរសំឡេង
- បង្ហាញការយល់ដឹងអំពីបញ្ញត្តិនៃសំណេរ
- បង្ហាញនូវការពេញចិត្តនិងភាពរីករាយជាមួយអំណានដំបូង
- គូសបំពេញរូបគំនូរដែលមានរាងងាយៗតាមស្នាមចុច
- ការយល់ដឹងពីភាសាដទៃ។

## ២.២. ការផ្សារភ្ជាប់ទៅនឹងបរិបទវិទ្យាសាស្ត្រ និងជីវភាពរស់នៅ

ភាសា គឺជាប្រព័ន្ធដ៏ទូលំទូលាយ នៃមធ្យោបាយទាក់ទងរបស់មនុស្សក្នុងសង្គម ហើយភាសាក៏ជាវិទ្យាសាស្ត្រមួយដែរ ដែលគេសិក្សាពីលក្ខណៈសង្គម មុខងាររបស់វា រចនាសម្ព័ន្ធ ដំណើរការអភិវឌ្ឍរបស់វាជាដើម។ ការលើកយកចំណុចទាំងនោះ មកសិក្សានេះហើយ គេឱ្យឈ្មោះថាវិទ្យាសាស្ត្រនៃភាសា ឬហៅថាភាសាវិទ្យា។ ការរៀនភាសាខ្មែររបស់កុមារ ក៏ត្រូវគោរពតាមរបក្បួនច្បាប់ ភាសាវិទ្យារបស់ខ្មែរ ដែលមានលក្ខណៈពិសេសរបស់ខ្លួនផងដែរ។ ទោះបីជាការសិក្សារៀនសូត្រនេះ ស្ថិតនៅក្នុងកម្រិតមត្តេយ្យសិក្សាក៏ដោយ តែការរៀនត្រូវតែគោរពតាមក្បួនច្បាប់វេយ្យាករណ៍ខ្មែរ ដែលផ្ដើមចេញពីពាក្យមួយជានាម សព្វនាម គុណនាម កិរិយាសព្ទ ឈ្នាប់ ធ្នាក់ បង្កើតជាកន្សោមពាក្យមួយ និងឈានទៅដល់ល្បះមួយពេញលេញ ស្ដាប់បាន និងមានន័យច្បាស់លាស់។

youtube.com/moeyscambodia
sala.moeys.gov.kh
t.me/moeysnews

- **នៅមត្តេយ្យសិក្សាកុមារនឹងរៀន៖**
  - ចូលរួមក្នុងការសន្ទនា ដែលអាចយល់បានត្រឹមប្រាំបីពាក្យ ក្នុងចំណោមដប់ពាក្យ
  - និយាយ និងយល់ ១,៥០០ពាក្យ ឬច្រើនជាងនេះ(នៅអាយុ ៤ឆ្នាំ)។ ទោះបីជាពាក្យពេចន៍របស់កុមារមត្តេយ្យសិក្សា អាចប្រែប្រួលយ៉ាងខ្លាំងក៏ដោយ។
  - បង្កើតបានជាប្រយោគនីមួយៗ ត្រឹមប្រាំមួយពាក្យ ឬច្រើនជាងនេះបន្តិចបន្តួច។
  - សួរសំណួរដោយប្រើពាក្យ " អ្នកណា អ្វី ទី/កន្លែង/ឯណា ហេតុអ្វី? " ។
  - យល់ដឹងនិងធ្វើតាមការណែនាំ ដូចជា "ដល់ម៉ោងឈប់លេងល្បែងផ្គុំរូបហើយ និងត្រូវទៅលេងនៅជ្រុងអំណានវិញ"។
  - ភ្ជាប់គំនិតពីរក្នុងប្រយោគមួយ។ ឧទាហរណ៍ "ខ្ញុំចង់ទៅខាងក្រៅ ព្រោះខ្ញុំអាចជិះកង់របស់ខ្ញុំនៅទីនោះបាន"។
  - និយាយប្រាប់រឿងសាមញ្ញមួយ បានពេញលេញ។ ឧទាហរណ៍៖ កុមារអាចប្រាប់មិត្តម្នាក់ថា "ខ្ញុំបានទៅផ្ទះយាយរបស់ខ្ញុំ កាលពីយប់មិញ។ គាត់មានរបស់លេងនៅផ្ទះគាត់។ ខ្ញុំចូលចិត្តរបស់លេងនៅផ្ទះយាយរបស់ខ្ញុំ"។
  - ច្រៀងចម្រៀង លេងហ្គេមពាក្យជូន និងលេង"ល្បែងម្រាមដៃ" ដូចជា ល្បែងជីបអំបិល ល្បែងធ្វើខ្ចី/ត្រួតម្រាមដៃប្រណាំងគ្នា ល្បែងផ្ទាត់កៅស៊ូ ល្បែង ល្បែក្រញ៉ាំខ្លាជាដើម។
  - យល់ដឹងពីបញ្ញត្តិនៃសំណេរ៖ សារអក្សរដែលផ្ទុកដោយគំនិតនៅក្នុងនោះ។ ឧទាហរណ៍៖ នាងកំពុងសរសេររឿងមួយ។
  - បង្ហាញការយល់ដឹងខ្លះ អំពីអក្ខរក្រមដោយអានឈ្មោះតួអក្សរនានា ដែលកុមារឃើញនៅលើស្លាកសញ្ញាឬក្នុងសៀវភៅ។
  - សរសេរតួអក្សរនិងពាក្យមួយចំនួន។
  - ប្រើពាក្យងាយៗ និងប្រយោគសាមញ្ញៗ ដើម្បីសាកសមនឹងបងប្អូនបង្កើត ឬមិត្តភ័ក្តិ។
  - និយាយឡើងវិញ ពីឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទ។
  - ពន្យល់ពីលំដាប់បួនឬប្រាំជំហាន។ ឧទាហរណ៍៖ "បន្ទាប់ពីខ្ញុំងូតទឹក ខ្ញុំជុសធ្មេញរបស់ខ្ញុំ ហើយស្លៀកពាក់ខោអាវ និងចុងក្រោយគឺចូលគេង"។

## ២.៣. ការបណ្ដុះស្មារតីកុមារ

ស្រឡាញ់ពេញចិត្តភាសាខ្មែរ ដោយសារពួកគេអាចសម្ដែង គំនិតយោបល់ មនោសញ្ចេតនា រវាងពួកគេក្មេងៗ និងអ្នកនៅជុំវិញ តាមរយៈការនិយាយ សូត្រកំណាព្យ ឬច្រៀង ដោយមាត់ទទេ ការពណ៌នាតាមរយៈរូបភាព តាមរយៈអ្វីៗដែលនៅជុំវិញខ្លួន។

# ជំពូក៣

# វិធីសាស្ត្រអនុវត្តការបង្រៀន និងរៀន

# មុខវិជ្ជាភាសាខ្មែរ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ជំពូក៣ វិធីសាស្ត្រអនុវត្តការបង្រៀន និងរៀនមុខវិជ្ជាភាសាខ្មែរ

### ៣.១. សញ្ញាណភាសាខ្មែរនៅមត្តេយ្យសិក្សា

ភាសាគឺជាពាក្យសម្ដី ដែលមនុស្សប្រើជាមធ្យោបាយ ក្នុងការទាក់ទងគ្នា ដើម្បីសន្ទនា ពិភាក្សា អំពីស្ថានភាពជីវិតរស់នៅប្រចាំថ្ងៃដូចជា មុខរបរចិញ្ចឹមជីវិត ការថែទាំសុខភាព ការសិក្សារៀនសូត្រ ការកំសាន្តសប្បាយ ជំនឿលើសាសនាជាដើម។ ជាងនេះទៀតភាសាមានតួនាទីសំខាន់ ក្នុងការ ផ្ដល់ចែកចាយព័ត៌មាន និងពន្យល់បកស្រាយនូវគំនិតយោបល់ ផ្នែកសាសនា វិទ្យាសាស្ត្រសង្គម និង វិទ្យាសាស្ត្រធម្មជាតិផងដែរ។ ភាសារួមមាន ភាសានិយាយ និងភាសាសរសេរ ហើយនៅក្នុងពិភពលោកយើងនេះ សម្រាប់ជនជាតិខ្លះមានតែភាសានិយាយទេ បញ្ហានេះភាគច្រើនកើតមានចំពោះជនជាតិភាគតិច ដោយសារជនជាតិមួយចំនួនទាំងនោះ មិនមានតួអក្សរសម្រាប់កត់ត្រាពាក្យពេចន៍ភាសារបស់ពួកខ្លួនឡើយ។ ដោយឡែកភាសាសរសេរ គឺកើតមានទៅបានលុះត្រាតែមានតួអក្សរសម្រាប់កត់ត្រា នូវពាក្យពេចន៍នៃភាសា តាមក្បួនច្បាប់វេយ្យាករណ៍យ៉ាងប្រាកដជាក់លាក់។ ទាំងភាសានិយាយនិងភាសាសរសេរ តែងតែមានពាក្យសំដីសាមញ្ញ(ភាសាសាមញ្ញ) និងពាក្យសំដីផ្លូវការ(ភាសាផ្លូវការ) បង្កប់នៅជាមួយ។ ចំពោះសាភាខ្មែរយើង គឺមានតួអក្សរសម្រាប់កត់ត្រា នូវអ្វីៗគ្រប់យ៉ាងបានច្បាស់លាស់ ដើម្បីបម្រើដល់ការរស់នៅរបស់ជាតិខ្មែរយើង ប្រកបដោយភាពពេញលេញបរិបូណ៌។ យ៉ាងដូច្នេះហើយ ទើបភាសាខ្មែរត្រូវបានឱ្យប្រើប្រាស់ជាភាសាផ្លូវការ សម្រាប់បម្រើឱ្យកិច្ចការរដ្ឋបាលរបស់សង្គមជាតិយើង ដែលមានចែងនៅមាត្រាទី៥ ក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សម្រាប់បម្រើឱ្យកិច្ចការរដ្ឋនិងការសិក្សា ចាប់ពី មត្តេយ្យសិក្សារហូតដល់ កម្រិតឧត្តមសិក្សានិងកម្រិតបន្តបន្ទាប់ទៀត ដែលបញ្ជាក់ថាភាសាខ្មែរមានសារៈសំខាន់ណាស់សម្រាប់អ្នកសិក្សាគ្រប់រូប។

ផ្អែកលើកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ និងស្តង់ដាសិក្សារបស់កុមារអាយុ៣ ៤ និង ៥ឆ្នាំ បានចង្អុលបង្ហាញថា ការសិក្សាភាសាខ្មែរនៅកម្រិតមត្តេយ្យសិក្សា គឺកុមារស្ដាប់គេនិយាយឬស្ដាប់ការណែនាំ ដោយប្រើឃ្លា ល្បះខ្លីៗ សាមញ្ញងាយៗ(ពង្រឹងនិងពង្រីកសមត្ថភាពស្ដាប់) និយាយ/សន្ទនាជាមួយអ្នកដទៃ ដោយប្រើឃ្លា ល្បះខ្លីៗ សាមញ្ញងាយៗ(ពង្រឹងនិងពង្រីកសមត្ថភាពនិយាយ) អានឈ្មោះរូបភាពឬតួព្យញ្ជនៈ ស្រៈ ដែលបានរៀន(ពង្រឹងនិងពង្រីកសមត្ថភាពអាន) និង គូស គូរ សរសេរ បំពេញតាមស្នាមចុចៗនានា(ពង្រឹងនិងពង្រីកសមត្ថភាពសរសេរ)។ អ្វីដែលត្រូវកត់សម្គាល់ជាពិសេស គឺសមត្ថភាពអាននិងសមត្ថភាពសរសេរ ដែលសិក្សានៅកម្រិតមត្តេយ្យសិក្សាមិនតម្រូវឱ្យកុមាររៀន ដើម្បីមានសមត្ថភាពអាន និងសមត្ថភាពសរសេរ ប្រកបឬផ្សំស្រៈឱ្យមានភាពស្ទាត់ជំនាញនោះទេ។ ប៉ុន្តែកុមាររៀនអានតាមរយៈរូបភាព អានពាក្យ ព្យញ្ជនៈ ស្រៈ និងរៀនសរសេរតាមរយៈការគូសតាមស្នាមចុចៗ ឬរៀនតាមរយៈការសរសេរចម្លងតាមតួអក្សរ ឬពាក្យដែលគ្រូបានដាក់ឱ្យ ឬនៅក្នុងសៀវភៅផ្សេងៗ។

### ៣.២. បញ្ញត្តិកម្មរបស់ភាសាខ្មែរនៅកម្រិតមត្តេយ្យសិក្សា

- **ចំពោះកុមារអាយុ ៣ឆ្នាំ**
  - ការស្ដាប់ (ស្ដាប់គេនិយាយ ធ្វើឱ្យមានសមត្ថភាពស្ដាប់ និងអាចធ្វើតាមការណែនាំងាយៗ)
  - ការសន្ទនា(ប្រើពាក្យឬឃ្លាល្បះស្របតាមវ័យ ដោយបង្ហាញពីអារម្មណ៍និងមនោសញ្ចេតនា)
  - ការប្រើពាក្យតាមវេយ្យាករណ៍(យល់ន័យពាក្យ ឃ្លា និងល្បះខ្លីៗ)

- ប្រើពាក្យសម្តី កាយវិការ និងនិមិត្តសញ្ញា ដើម្បីទំនាក់ទំនង(ប្រើពាក្យសម្តី ប្រើកាយវិការ និងនិមិត្តសញ្ញាតំណាងឱ្យសត្វឬវត្ថុនានា)
- ការស្គាល់តួអក្សរ(ប្រើវិញ្ញា៥របស់ខ្លួនដើម្បីសិក្សារៀនសូត្រ យល់ដឹងពីភាពខុសគ្នានៃសូរសំឡេង យល់ដឹងពីបញ្ញត្តិនៃសំណេរ យល់ដឹងពីការអាននិងការប្រើប្រាស់ឯកសារសំណេរ)
- សមត្ថភាពគូសនិងសរសេរអក្សរ(បំណិនសរសេរមានភាពកាន់តែប្រសើរឡើង)

- **ចំពោះកុមារអាយុ ៤ឆ្នាំ**
  - ការស្តាប់(ស្តាប់គេនិយាយ និងយល់ ១,៥០០ពាក្យ ឬ ច្រើនជាងនេះ ធ្វើឱ្យមានសមត្ថភាពស្តាប់ និងអាចធ្វើតាមការណែនាំងាយៗ គ្រាន់បើជាងកុមារអាយុ ៣ឆ្នាំដែរ)
  - ការសន្ទនា (ប្រើពាក្យឬឃ្លាល្បះស្របតាមវ័យ ដោយបង្ហាញពីអារម្មណ៍និងមនោសញ្ចេតនាមានលក្ខណៈប្រសើរជាងកុមារអាយុ ៣ឆ្នាំដែរ)
  - ការប្រើពាក្យតាមវេយ្យាករណ៍(យល់ន័យពាក្យ ឃ្លា និងល្បះខ្លីៗ ប្រសើរជាងកុមារអាយុ ៣ឆ្នាំ)
  - ប្រើពាក្យសម្តី កាយវិការ និងនិមិត្តសញ្ញា ដើម្បីទំនាក់ទំនង((ប្រើពាក្យសម្តី ប្រើកាយវិការ និងនិមិត្តសញ្ញាតំណាងឱ្យសត្វឬវត្ថុនានា)
  - ការស្គាល់តួអក្សរ(ប្រើវិញ្ញា៥របស់ខ្លួនដើម្បីសិក្សារៀនសូត្រ យល់ដឹងពីភាពខុសគ្នានៃសូរសំឡេង យល់ដឹងពីបញ្ញត្តិនៃសំណេរ យល់ដឹងពីការអាននិងការប្រើប្រាស់ឯកសារសំណេរមានលក្ខណៈប្រសើរជាងកុមារអាយុ ៣ឆ្នាំដែរ)
  - សមត្ថភាពគូសនិងសរសេរអក្សរ (បំណិនសរសេរមានភាពកាន់តែប្រសើរឡើង)
- **ចំពោះកុមារអាយុ ៥ឆ្នាំ**
  - ការស្តាប់ (ស្តាប់គេនិយាយ ធ្វើឱ្យមានសមត្ថភាពស្តាប់ និងអាចធ្វើតាមការណែនាំងាយៗ ដូចជា ធ្វើតាមបាន៤ដំណាក់កាល តាមការណែនាំ)
  - ការសន្ទនា(ប្រើពាក្យឬឃ្លាល្បះស្របតាមវ័យ ដោយបង្ហាញពីអារម្មណ៍និងមនោសញ្ចេតនា ដូចជា ប្រាប់បានពីព័ត៌មានផ្ទាល់ខ្លួន សួរឆ្លើយ និងទទួលព័ត៌មានត្រឡប់ពីអ្នកដទៃ)
  - ការប្រើពាក្យតាមវេយ្យាករណ៍(យល់ន័យពាក្យ ឃ្លា និងល្បះខ្លីៗ ដូចជា និយាយបានត្រឹមត្រូវមានឃ្លា ល្បះច្បាស់លាស់..)
  - ប្រើពាក្យសម្តី កាយវិការ និងនិមិត្តសញ្ញា ដើម្បីទំនាក់ទំនង(ប្រើពាក្យសម្តី ប្រើកាយវិការ និងនិមិត្តសញ្ញាតំណាងឱ្យសត្វឬវត្ថុនានា ដូចជា និទានរឿងឱ្យអ្នកដទៃស្តាប់ ប្រាប់បានពីនិមិត្តសញ្ញាសាធារណៈ បន្ទប់ទឹកប្រុស ឬស្រី..).
  - ការស្គាល់តួអក្សរ(ប្រើវិញ្ញា ៥របស់ខ្លួនដើម្បីសិក្សារៀនសូត្រ យល់ដឹងពីភាពខុសគ្នា នៃសូរសំឡេង យល់ដឹងពីបញ្ញត្តិ នៃសំណេរ យល់ដឹងពីការអាននិងការប្រើប្រាស់ឯកសារសំណេរ ដូចជាប្រាប់បានពីឈ្មោះតួអក្សរដែលរៀនរួចហើយប្រាប់បានពីរបៀបលេងល្បែងបុរេសំណេរ និងប្រាប់បានពីរបៀបកាន់និងបើកសៀវភៅអាន...)

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- សមត្ថភាពគូសនិងសរសេរអក្សរ(បំណិនសរសេរមានភាពកាន់តែប្រសើរឡើង)។ ដូចជា សរសេរ
- តួអក្សរនិងស្រៈបានតាមគំរូ ប្រាប់បាន ពីរបៀបសរសេរតួអក្សរនិងស្រៈដែលរៀនរួចហើយ)
- ការយល់ដឹងពីភាសាដទៃ(យល់ដឹងពីការប្រើភាសាខុសគ្នា សម្រាប់ប្រាស្រ័យទាក់ទង ក្រៅពីភាសាផ្ទាល់ខ្លួន)។

**បំណិនទាំង៤នៃភាសា**

- **ការស្តាប់**

រឿងដំបូងបំផុតដែលកុមារម្នាក់ត្រូវធ្វើ គឺការរៀនភាសាកំណើតរបស់គេ។ ការរៀននោះ គឺផ្តើមចេញពីការស្តាប់ នូវអ្វីៗដែលមនុស្សគ្រប់គ្នានិយាយទៅកាន់ខ្លួន។ ការហ្វឹកហាត់ស្តាប់ គឺដើម្បីអភិវឌ្ឍជំនាញស្តាប់របស់កុមារ។ កុមារមិនមានភាពគ្រប់គ្រាន់ទេ ក្នុងការរៀនជាមួយគ្រូ។ ដូច្នេះកុមារត្រូវតែហ្វឹកហាត់ស្តាប់សូរសំឡេងផ្សេងៗក្នុងបរិស្ថាន ស្តាប់តន្ត្រី ចម្រៀងជាដើម។ ដោយសារសព្វថ្ងៃនេះ បច្ចេកវិទ្យាមានកម្មវិធីជាច្រើនប្រភេទដែលកុមារអាចប្រើ ដើម្បីពង្រឹងការស្តាប់របស់កុមារ។

- **ការនិយាយ**

ជំហានទីពីរកុមារធ្វើត្រាប់តាមសំឡេងដែលកុមារបានឮពីមុនមក ហើយព្យាយាមនិយាយពាក្យនិយាយពាក្យពេចន៍ដែលបានឮទាំងនោះ។ នេះជាគន្លឹះក្នុងការធ្វើឱ្យរីកចម្រើន សម្រាប់ការនិយាយរបស់កុមារ។ កុមារព្យាយាមនិយាយជាមួយកុមារផ្សេងៗទៀត ដើម្បីយល់និងប្រើប្រាស់ភាសាកំណើតកាន់តែប្រសើរឡើង។ កុមារជឿជាក់លើខ្លួនឯង ក្នុងការនិយាយប្រាស្រ័យទាក់ទងគ្នា។ យុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពមួយទៀត គឺឱ្យកុមារនិយាយខ្លាំងៗ ដើម្បីអនុវត្តការបញ្ចេញសំឡេង។ លើសពីនេះ វាមានប្រយោជន៍ខ្លាំងណាស់ ក្នុងការកំណត់គោលដៅតូចៗជារៀងរាល់ថ្ងៃ ដូចជាការរៀននិយាយជាប្រយោគខ្លី មធ្យម ឬពាក្យថ្មី។

- **អំណាន**

រឿងទីបីកុមារអានរូបភាព និយាយឡើងវិញនូវស្រៈ និងអក្សរ។ ជាដំបូង កុមារត្រូវចាប់ផ្តើមអានពីរូបភាព អានចំណងជើងមេរៀនតាមទិសនៃសំណេរ ពីលើចុះក្រោម។ កុមារអានដោយស្ងៀមស្ងាត់ តាមការណែនាំរបស់គ្រូ ឬអានដោយបញ្ចេញសំឡេងឮៗ។ នៅចំណុចនេះ កុមារអានដោយយល់ន័យរបស់ពាក្យតាមរយៈរូបភាព សញ្ញា និមិត្តសញ្ញា ពាក្យ កន្សោមពាក្យ និងយល់ពីច្បាប់វេយ្យាករណ៍ភាសាខ្មែរ។

- **សំណេរ**

ជំហានទីបួនកុមាររៀនគូសវាស គូសតាមស្នាមចុច លើតួអក្សរ ហ្វឹកហាត់សរសេរ ពាក្យសាមញ្ញៗជាដើម។ ទោះជាយ៉ាងណាក៏ដោយ មុននឹងសរសេរ កុមារត្រូវគិតអំពីអ្វីដែលអាចសរសេរបាន។ នេះជាបំណិនចុងក្រោយ ដែលផ្តុំបំណិនទាំងបីខាងលើ កុមារត្រូវដឹងពីរបៀបសរសេរឱ្យបានត្រឹមត្រូវ។ ម្យ៉ាងវិញទៀតការសរសេរ គឺជួយពង្រឹងការយល់ដឹងរបស់កុមារលើក្បួនច្បាប់វេយ្យាករណ៍ខ្មែរកាន់តែប្រសើរឡើង។

**បំណិនទាំង៦នៃការសម្គាល់អក្សរនៅកម្រិតមត្តេយ្យសិក្សា៖**

- បំណិនស្ដាប់
- បំណិនសង្កេត
- បំណិននិយាយ
- បំណិនចលនា
- បំណិនលំហ
- បំណិនពេលវេលា

## ៣.៣. វិធីសាស្ត្របង្រៀនភាសាខ្មែរនៅមត្តេយ្យសិក្សា

ការអនុវត្តគោលវិធីនិងវិធីសាស្ត្របង្រៀន នៅកម្រិតមត្តេយ្យសិក្សា គឺប្រើគោលវិធីសិស្សមជ្ឈមណ្ឌល និងវិធីសាស្ត្របង្រៀនជាច្រើនទៀតរួមមាន៖ វិធីសាស្ត្របែបសហការ វិធីសាស្ត្របែបរុករក វិធីសាស្ត្រសង្កេត វិធីសាស្ត្រទស្សនាសង្កេត និងវិធីសាស្ត្របែបដោះស្រាយបញ្ហាជាដើម។

### ៣.៤.១ បុរេសំណេរ

#### ក. សារៈសំខាន់

បុរេសំណេរ គឺជារឿងចាំបាច់នៃដំណាក់កាលដំបូងក្នុងការសរសេរ ដែលកុមារត្រូវចាប់ផ្ដើមឡើងដោយខ្លួនរបស់ពួកគេផ្ទាល់ មានហេតុផលសំខាន់ៗជាច្រើនជាមួយបញ្ហានេះ។ គេអាចប្រៀបធៀបទៅនឹងកុមារ ត្រូវការចេះដើរមុនពេលពួកគេអាចធ្វើដំណើរដ៏វែងឆ្ងាយបាន ដូចគ្នានេះដែរកុមារត្រូវចេះជំនាញសរសេរជាដំបូងសិន មុនពេលពួកគេអាចសរសេរអក្សរបានពេញលេញ ប្រកបដោយប្រសិទ្ធភាព។ បំណិនបុរេសំណេរ ទាក់ទងនឹងការអនុវត្ត ការគូស គូរ សរសេររាងផ្សេងៗ ដែលជាការអភិវឌ្ឍជំនាញចលករតូច និងការសម្របសម្រួលទៅនឹងភ្នែករបស់កុមារម្នាក់ៗបានសមស្រប។ ដំបូងកុមារចេះចាប់កាន់ ដីស ខ្មៅដៃ គូសវាសគំនូសផ្សេងៗ ដោយសេរី លើក្រដាស ឬលើក្ដារឆ្នួន ឬលើអ្វីផ្សេងៗទៀត។ ជាពិសេសដើម្បីឱ្យកុមារមានការអនុវត្តបំណិននេះបានល្អប្រសើរ ចាំបាច់មានការចូលរួមជួយជ្រោមជ្រែងពីមនុស្សធំនៅជុំវិញខ្លួន។

ការស្គាល់តួអក្សរ គឺសកម្មភាពនាំកុមារឱ្យមានការសរសេរជាដំបូង ដោយចាប់ផ្ដើមពីការគូសវាសគំនូសមូលដ្ឋាន ឬគំនូសតាមទ្រង់ទ្រាយផ្សេងៗ និងឈានដល់ការសរសេរតួអក្សរ ដែលមានទិសនៃសំណេរច្បាស់លាស់ត្រឹមត្រូវ។ មិនត្រឹមតែប៉ុណ្ណោះកុមារអាចស្ដាប់ និងស្គាល់សូរនៃតួអក្សរនីមួយៗច្បាស់លាស់ដើម្បីឈានទៅរកការសរសេរ។ អក្សរខ្មែរមានរូបរាងស្រដៀងគ្នាមួយចំនួនខ្លះ និងមានលក្ខណៈប្លែកៗគ្នាក៏ច្រើនដែរ។ ចំពោះព្យញ្ជនៈមានតួខ្លួន សក់ និងជើង រីឯស្រៈវិញមានរូបរាងស្រដៀងគ្នាមួយចំនួនខ្លះ និងមានលក្ខណៈប្លែកផ្សេងៗគ្នាក៏ច្រើនដែរ ហើយការប្រើក្នុងការសរសេរមាននៅចំហៀង(មុខឬក្រោយ) លើ និងក្រោម ព្យញ្ជនៈ។

#### ខ. ការបង្រៀន និងរៀន

ការបង្រៀនមេរៀននីមួយៗ គ្រូត្រូវតែមានកម្មវិធីសិក្សាលម្អិត បំណែងចែកកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំខែ សប្ដាហ៍ ផែនការបង្រៀនប្រចាំថ្ងៃ កិច្ចតែងការបង្រៀន និងសម្ភារឧបទេស។ ការបង្រៀនត្រូវគោរពតាមជំហានទាំង៥ នៃដំណើរការបង្រៀន និងអនុវត្តតាមលំនាំបង្រៀននៃមុខវិជ្ជានីមួយៗ ដោយប្រើ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

គោលវិធីសិស្សមជ្ឈមណ្ឌល វិធីសាស្ត្រនានាសមស្រប និងល្បិចបង្រៀនផ្សេងៗទៀត ដែលគ្រូជាអ្នករៀបចំឡើងដោយខ្លួនឯងផ្ទាល់។

បុរេសំណេរជាសកម្មភាពផ្តោតលើ ការសរសេរតួអក្សរដែលទាមទារឱ្យកុមារមាន សមត្ថភាពលើការសង្កេត ការស្តាប់សូរសំឡេង ការចាប់កាន់(ដីស ខ្មៅដៃ) និងការធ្វើចលនាម្រាមដៃបានត្រឹមត្រូវតាមទិសនៃសំណេរអក្សរខ្មែរ (ពីឆ្វេងទៅស្តាំ ពីក្រោមឡើងលើ និងពីលើចុះក្រោម)។

**ខ.១ គំនូសនានានិងគំនូសមូលដ្ឋាន បង្កើតបានជាតួអក្សរ**

គំនូសដែលបង្កើតជាតួអក្សរខ្មែរ គឺផ្តើមចេញពីគំនូសនានាដែលកុមារគូសគ្មានរបៀបរៀបរយទាំងឡាយ និងពីគំនូសមូលដ្ឋានដែលមានការណែនាំច្បាស់លាស់។ គំនូសមូលដ្ឋានទាំងនោះ រួមមានៈ គំនូសត្រង់បញ្ឈរ គំនូសត្រង់ផ្តេក គំនូសត្រង់ទេរទៅស្តាំ គំនូសត្រង់ទេរទៅឆ្វេង គំនូសកោងផ្កាប់ គំនូសកោងផ្ងា និងគំនូសរង្វង់មូល។ ដំបូងត្រូវឱ្យកុមារ ហ្វឹកហាត់ធ្វើចលនាគូសវាសគំនូសផ្សេងៗ ស្រេចតែ នឹងចិត្តរបស់កុមារនិងបន្ទាប់មកកុមារត្រូវបានគ្រូ ណែនាំឱ្យគូសគំនូសមានទិសដៅជាក់លាក់ (គំនូស មូលដ្ឋាន) ដើម្បីធ្វើចលនាកដៃនិងម្រាមដៃ សម្របបានជាមួយភ្នែករបស់កុមារ ឱ្យបានស្ទាត់ជំនាញ ហើយពួកគេអាចគូសចំតាមគោលដៅបានត្រឹមត្រូវ។ ដោយផ្អែកលើបទពិសោធដែលកុមារមាន អំពីគំនូសនានានិងគំនូសមូលដ្ឋាន នៅក្នុងមុខវិជ្ជាសិក្សាសង្គម។ (មើលបន្ថែមក្នុងឧបសម្ព័ន្ធ)

**ខ.១.១ គំនូសអក្សរ**

ចំពោះការបង្រៀនការសម្គាល់តួអក្សរដល់កុមារ គ្រូត្រូវចាប់ផ្តើមយកគំនូសទាំងនោះ មកសរសេរផ្គុំបង្កើតជាតួអក្សរតែម្តង។ ហើយគ្រូត្រូវណែនាំកុមារឱ្យសរសេរតួអក្សរនោះ ដោយជ្រើសរើសយកតួអក្សរណាដែលងាយៗមកបង្រៀនមុន រួចហើយសឹមឈានទៅបង្រៀនសរសេរអក្សរណា ដែលមានការពិបាកបន្តិចម្តងៗ ទៅតាមការកំណត់នៅក្នុងកម្មវិធី។ ការបង្រៀនឱ្យកុមារសរសេរតួអក្សរនេះ គ្រូត្រូវយកចិត្តទុកដាក់នូវចំណុចមួយចំនួន រួមទាំងឥរិយាបថក្នុងការអង្គុយសរសេរអក្សររបស់កុមារដែរ។ គ្រូត្រូវពិនិត្យមើលថាតើ កុមារទាំងអស់មានតុកៅអី សន្លឹកក្រដាសឬសៀវភៅសរសេរ ខ្មៅដៃហើយ ឬនៅ! បើមិនទាន់មានគ្រប់គ្នាទេគ្រូត្រូវរកវិធីដោះស្រាយធ្វើយ៉ាងណាឱ្យកុមារមានសម្ភារទាំងនេះ ទាំងអស់គ្នាសិន។ រួចណែនាំកុមារឱ្យអង្គុយក្នុងឥរិយាបថមួយ ដែលសមស្រប ដូចជាជំហរដងខ្លួនក្នុងការអង្គុយ ការដាក់ដៃ ការដាក់ក្រដាសលើតុ និងរបៀបនៃកាន់ខ្មៅដៃ ដើម្បីសរសេរអក្សរទៅតាមទិសសំណេរ និងតាមដំណាក់នីមួយៗ ឱ្យបានច្បាស់លាស់។

ឧទាហរណ៍ៈ ការបង្រៀនការសរសេរតួអក្សរ "ក" មានពីរទម្រង់គឺទម្រង់ជ្រុងនិងទម្រង់មូល។ ដំបូងគ្រូត្រូវបង្រៀនកុមារឱ្យសរសេរតាមទម្រង់ជ្រុងសិន បន្ទាប់មកសឹមនាំកុមារឱ្យសរសេរតាមទម្រង់មូលជាក្រោយ។ ការអនុវត្តបែបនេះ នឹងធ្វើឱ្យកុមារសរសេរតួអក្សរបានត្រឹមត្រូវ និងសរសេរអក្សរបានស្អាតនិងច្បាស់ច្បាស់លាស់ល្អ។

**ទម្រង់ទី១៖** ការហាត់សរសេរអក្សរ “ ” **ក** ជាទម្រង់ជ្រុង គឺណែនាំកុមារឱ្យគូសឬសរសេរជាអក្សរមួយដំណាក់ម្តងៗ។



- ➢ គេទាញពីក្រោមឡើងទៅលើតាមក្រឡា ចលនាទី១
- ➢ គេទាញខាងលើពីឆ្វេងទៅស្តាំ ចលនាទី២
- ➢ គេទាញខាងស្តាំពីលើចុះក្រោម ចលនាទី៣
- ➢ គូសបន្ទាត់ត្រង់ពីឆ្វេងទៅស្តាំ ចលនាទី៤

**ទម្រង់ទី២៖** ហាត់សរសេរអក្សរ “ក” ជាទម្រង់មូល គឺណែនាំកុមារឱ្យគូសឬសរសេរជាអក្សរដោយមិនដកដៃ។

- ➢ **ដំណាក់កាលទី១** 
- ➢ **ដំណាក់កាលទី២** ក

❖ **របៀបនៃការបង្រៀនសម្គាល់តួអក្សរ “ក”**

- បង្ហាញរូបភាពម្តង១ៗដោយបិទបាំង និងបិទលើក្តារខៀន រួចបិទបណ្ណពាក្យនៅក្រោមរូបភាព
- គ្រូអានពាក្យម្តង១ឱ្យកុមារអានតាម
- បិទបណ្ណឃ្លា គ្រូអាននិងឱ្យកុមារអានតាម




រូបភាពទី 1៖ ទឹកកកក្នុងកែវ

| ទឹកកកក្នុងកែវ |
|---|



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- គ្រូអានពាក្យនិងឃ្លាឱ្យកុមារស្តាប់សួរ
- គ្រូឱ្យកុមារពិនិត្យតួអក្សរក្នុងបណ្ណពាក្យ និងបណ្ណឃ្លាតើតួអក្សរមួយណា ដែលមានរាងដូចគ្នា
- ឱ្យកុមារ២ឬ៣នាក់ឡើងគូសវង់លើតួអក្សរដែលដូចគ្នា
- បំផុសរកឈ្មោះតួអក្សរ រួចគ្រូយកអក្សរចល័ត "ក" បិទនៅលើក្តារខៀន ហើយគ្រូឱ្យកុមារក្រឡេកមើលស្លោកនៅក្នុងថ្នាក់តើមានអក្សរណាដូចនឹងអក្សរ ដែលយើងទើបរៀនអំបាញ់មិញ



- គ្រូណែនាំពីរបៀបសរសេរអក្សរ "**ក**" ដំបូងកូនគូសពីក្រោមឡើងទៅលើ ទាញកោងទៅស្តាំ រួចទាញចុះមកក្រោម រួចដាក់សក់វា ដោយគូសផ្តេកត្រង់ ឬទាញពីក្រោមឡើងលើ ពីលើចុះក្រោម ពីក្រោមឡើងលើ និងពីលើចុះក្រោមវិញ។



- គ្រូសរសេរអក្សរ ក គ ត ច ឱ្យកុមារពិនិត្យមើលថាតើ តួអក្សរទាំងនេះដូចគ្នាត្រង់ណាខ្លះ និងខុសគ្នាត្រង់ណាខ្លះ
- ឱ្យកុមាររកពាក្យថ្មី ដែលផ្តើមចេញពីអក្សរ "ក"( កង្កែប កុមារា កុមារី កកេរ...)
- នាំកុមារលេងល្បែងពង្រឹង ដើម្បីឱ្យកុមារចំណាំតួអក្សរ"ក" បានច្បាស់លាស់ ដោយឱ្យកុមាររៀបគ្រាប់គ្រួសលើតួអក្សរ "ក" ។

**បញ្ជាក់:** គ្រូអាចជ្រើសរើសល្បែងណាមួយផ្សេងទៀតមកឱ្យកុមារលេងក៏បានដែរ ដើម្បីពង្រឹងចំណេះដឹង លើការចងចាំនិងស្គាល់តួអក្សរ "**ក**" នេះ។ ដូចជា ការគូសភ្ជាប់ ឬគូសវង់ជុំវិញតួអក្សរដែលដូចគ្នា ល្បែងស្ទូងត្រីអក្សរ"**ក**" តាមការយល់ឃើញរបស់គ្រូផ្ទាល់ ដោយអាស្រ័យតាមស្ថានភាពជាក់ស្តែង និងឱកាសផ្តល់ឱ្យ សម្រាប់ធ្វើសកម្មភាពនោះ។

### ខ.១.២ លំនាំបង្រៀនការសម្គាល់តួអក្សរ

ការបង្រៀនការសម្គាល់តួអក្សរ គឺជាសញ្ញាណដំបូងនៃការកត់សម្គាល់សញ្ញាតាងរបស់ភាសាចំពោះកុមារ ដែលវាជាគំនូសនានាតំណាងឱ្យសូរសព្ទនិងរូបសព្ទ(ហៅថាអក្សរ) នៅពេលវេលានេះហើយដែលកុមាររៀនពីបុរេសំណេរ មុននឹងពួកគេឈានទៅដល់ការសរសេរពេញលេញនៅកម្រិតបឋមសិក្សា។ ការបង្រៀនកុមារមត្តេយ្យសិក្សាឱ្យសម្គាល់តួអក្សរ គឺតែងគោលរពន្ធវលំនាំបង្រៀនតាមដំណាក់កាលនីមួយៗ ដូចខាងក្រោម៖

❖ **រកពាក្យ និងឃ្លា**

- បង្ហាញរូបភាពឬវត្ថុពិតឱ្យកុមារប្រាប់ឈ្មោះ(តាមរយៈការបំផុសសំណួរ ឬពាក្យបណ្តៅ
- ឬកាយវិការ ឬកំណាព្យ ការបិទបាំងរូបភាព ការលាក់រូបភាព...)
- បិទបណ្ណរូបភាព បិទបណ្ណពាក្យពីក្រោមរូបភាព និងបិទឃ្លា។

❖ **ស្តាប់សូរ**

- អានពាក្យនិងឃ្លាដែលបានបង្ហាញរួចទាំងនោះ ឱ្យកុមារស្តាប់សូរ ដោយអានឱ្យបានសូរសំឡេងច្បាស់ៗនិងត្រឹមត្រូវ។

❖ **ពិនិត្យរូបរាង**

- ឱ្យកុមារស្វែងរកតួអក្សរដែលមានរាងដូចគ្នា នៅក្នុងពាក្យនិងឃ្លាទាំងនោះ។

❖ **ប្រាប់ឈ្មោះតួអក្សរ**

- បំផុសឱ្យកុមាររកឈ្មោះតួអក្សរ និងឱ្យកុមារបង្ហាញតួអក្សរ (តាមវិធីផ្សេងៗ)
- បិទអក្សរចល័តលើក្តារខៀន និងប្រាប់ឈ្មោះតួអក្សរ
- សរសេរតួអក្សរទៅតាមទិសនៃសំណេរ នៅលើក្តារខៀនជិតអក្សរចល័ត។

❖ **ប្រៀបធៀបតួអក្សរ**

- សរសេរតួអក្សរ ដែលមានរាងប្រហាកប្រហែលគ្នាឱ្យកុមារសង្កេតនិងធ្វើប្រៀបធៀបលក្ខណៈខុសគ្នានិងដូចគ្នា។

❖ **រកពាក្យថ្មីផ្តើមចេញពី តួអក្សរដែលទើបរៀនរួច**

- ឱ្យកុមាររកពាក្យថ្មីផ្តើមចេញពី តួអក្សរដែលទើបតែបានរៀនរួច
- គ្រូសរសេរពាក្យទាំងអស់នោះ នៅលើក្តារខៀន ឱ្យបានច្បាស់លាស់
- ឱ្យកុមារផ្ទៀងផ្ទាត់ (គូសជុំវិញពាក្យដែលត្រឹមត្រូវ)។

**គ. ការបង្រៀនល្បែងបុរេសំណេរ**

ល្បែងបុរេសំណេរផ្តើមចេញពីបំណិនទាំង៦គឺ ការសង្កេត ការស្តាប់ ការនិយាយ ការធ្វើចលនាលំហ និងពេលវេលា។ ការគូសវាស គំនូសមូលដ្ឋាន ឬគំនូសផ្សេងៗតាមទ្រង់ទ្រាយតួអក្សរ រៀបគ្រាប់គ្រួសតាមតួអក្សរ ឬបិទគ្រាប់ធញ្ញជាតិលើតួអក្សរ ហាត់សរសេរអក្សរតាមស្នាមចុចៗ ផាត់ពណ៌បន្ថែមលើរូបភាព លេងល្បែងស្ទូចត្រីដែលមានអក្សរ គូសភ្ជាប់តួអក្សរដែលដូចគ្នា។



រូបភាពទី 2៖ ការបង្រៀនល្បែងបុរេសំណេរ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**គ.១ លំនាំបង្រៀនល្បែងបុរសំណេរ**

- បង្ហាញសម្ភារដែលត្រូវលេង ឱ្យកុមារប្រាប់ឈ្មោះ (ប្រសិនបើមាន)
- ណែនាំពីរបៀបលេង និងលក្ខខណ្ឌនៃការលេង
- ឱ្យកុមារនិយាយឡើងវិញពីរបៀបលេង និងលក្ខខណ្ឌនៃការលេង
- រៀបចំកុមារ (ជាក្រុមតូច ឬក្រុមធំអាស្រ័យទៅតាមប្រភេទល្បែង)
- ចែកសម្ភារឱ្យកុមារតាមក្រុម ឬបុគ្គល
- កុមារលេងហើយគ្រូ ជាអ្នកសម្របសម្រួលឬដឹកនាំលេង អាស្រ័យទៅតាមប្រភេទល្បែងនានា
- វាយតម្លៃលទ្ធផល
- កុមារ និងគ្រូផ្ទៀងផ្ទាត់ កែលម្អ និងអនុវត្តតាមលក្ខខណ្ឌនៃការលេង
- ប្រាប់ចំណងជើងល្បែង។

**គ.២ លំនាំបង្រៀនស្រះ**

❖ **ល្បែងឡូតូស្រះ**

- បង្ហាញផ្ទាំងក្រដាសឡូតូស្រះនិងកូនកាសស្រះទាំង៨ ឱ្យកុមារសង្កេតនិងគ្រូអានស្រះទាំងនោះ ឱ្យកុមារស្ដាប់
- កុមារម្នាក់ៗត្រូវមាន ផ្ទាំងឡូតូស្រះនិងកូនកាសស្រះទាំង៨ ដែលបានច្របល់ចូលគ្នារួចហើយ
- ហៅស្រះនីមួយៗទាំងនោះម្ដងមួយៗ ដើម្បីឱ្យកុមារស្វែងរកកូនកាស។ ឧទាហរណ៍៖ ស្រះា កុមារត្រូវយកកូនកាសស្រះា ដាក់នៅកន្លែងស្រះាលើផ្ទាំងក្រដាសឡូតូ
- នាំកុមារលេងរបៀបនេះ រហូតអស់កូនកាសស្រះ
- នាំកុមារពិនិត្យផ្ទៀងផ្ទាត់លទ្ធផល លើក្រដាសឡូតូដែលកុមារយកកូនកាសស្រះទៅដាក់នោះ និងឱ្យកុមារដាក់នៅកន្លែងត្រឹមត្រូវ បើសិនជាមានកុមារណាម្នាក់ ដាក់មិនត្រឹមត្រូវ។

បញ្ជាក់៖ ល្បែងនេះអាចលេងជាបុគ្គលឬក្រុមតូចអាស្រ័យតាមចំនួនសម្ភារ។

- ការបង្រៀនស្រះគឺយើងបង្រៀនតាមលំនាំបង្រៀនល្បែង។



រូបភាពទី 3៖ល្បែងឡុកឡាក់អំពី ស្រះ

### ៣.៤.២ រឿងនិទាន

#### ក. សារៈសំខាន់

ការអានឬនិទានរឿងមានសារៈសំខាន់យ៉ាងខ្លាំងចំពោះកុមារ ដែលមិនអាចខ្វះបានក្នុងការអប់រំកុមារស្ថិតនៅវ័យមត្តេយ្យសិក្សា ដែលធ្វើឱ្យកុមារទទួលបាននូវភាពសប្បាយរីករាយ និងសេចក្ដីស្រឡាញ់ពេញចិត្ត។ យ៉ាងណាមិញរឿងនិទាន គឺជាប្រភពនៃអក្សរសិល្ប៍ទាំងឡាយណា ដែលប្រើជាពាក្យរាយ ប្រើភាសានិយាយបែបសាមញ្ញ ឱ្យកុមារងាយយល់ ដែលអាចសម្ដែងចេញនូវភាពរស់រវើកបញ្ជាក់ពីអត្តចរិត ឫកពារ មនោសញ្ចេតនារបស់មនុស្ស សត្វ បាតុភូតធម្មជាតិ និងព្រឹត្តិការណ៍ផ្សេងៗ មានខ្លឹមសារអប់រំទៅតាមសម័យកាលនីមួយៗ មកពោលប្រាប់អ្នកស្ដាប់តៗគ្នាពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត និងពីតំបន់មួយទៅតំបន់មួយទៀត។ នៅមត្តេយ្យសិក្សារឿងនិទានមានតួនាទីសំខាន់បំផុត ព្រោះរឿងនិទានជួយឱ្យកុមារមានភាពកក់ក្ដៅ ការជឿជាក់ សុវត្ថិភាព សប្បាយរីករាយ អារម្មណ៍ធូរស្រាល មានសេចក្ដីសុខ និងទាក់ទាញអារម្មណ៍កុមារឱ្យយល់ដឹងពីជីវភាពរស់នៅរបស់មនុស្សនៅក្នុងសង្គម។ ការស្ដាប់រឿងនិទានធ្វើឱ្យកុមារមានការរីកចម្រើនលើការស្រមើស្រមៃ សមត្ថភាពអានរូបភាព និងស្ដាប់ ការត្រិះរិះពិចារណា បញ្ញាស្មារតី សញ្ចេតនា ផ្នែកភាសា សីលធម៌ក្នុងការរស់នៅ និងជាពិសេសការប្រើក្រសែភ្នែករវាងគ្រូ និងកុមារក្នុងពេលនិទានរឿង។

#### ក.១ ការរីកចម្រើនលើផ្នែកសំខាន់ៗ

#### ក.១.១ ការបង្កើនសមត្ថភាពស្រមើស្រមៃ

ពេលស្ដាប់រឿងនិទាន ធ្វើឱ្យកុមារចេះប្រើប្រាស់សមត្ថភាពស្រមើស្រមៃ តាមរយៈការបង្កើតរូបារម្មណ៍ទៅតាមសាច់រឿងក្នុងតួអង្គនីមួយៗក្រោយពីគ្រូបាននិទានរួច ហើយក៏បានរួមចំណែកឱ្យកុមារបង្កើននូវគំនិតច្នៃប្រឌិត ចេះសម្ដែងតួទៅតាមការនឹកឃើញ ក្រោយពីស្ដាប់រឿងនិទាន។ ឧទាហរណ៍៖ នៅក្នុងរឿងមេអំបៅមួយគូ គ្រូបាននិទានឱ្យកុមាស្ដាប់ បន្ទាប់ពីនិទានចប់ធ្វើឱ្យកុមារនឹកស្រមើស្រមៃទៅលើរូបរាងកាយរបស់មេអំបៅ ថាមានរូបរាងដូចម្ដេច ដោយគ្រូបានឱ្យកុមារប្រាប់ពីអ្វីដែលពួកគេបានដឹងខ្លះៗនូវកិនភាគរបស់មេអំបៅ ហើយបន្តមកទៀតគ្រូនឹងឱ្យកុមារដើរតួទៅតាមតួអង្គនីមួយៗដែលពួកគេបានចងចាំ។ជួនកាលពេលត្រឡប់ទៅផ្ទះវិញ កុមារអាចស្រមើស្រមៃ និងចាំនូវសាច់រឿងខ្លះៗដែលពួកគេបានរៀនរួច ទៅនិទានឱ្យឪពុកម្ដាយ ឬមិត្តភក្ដិស្ដាប់។

#### ក.១.២ ការបង្កើនសមត្ថភាពក្នុងការអានរូបភាព និងស្ដាប់

សមត្ថភាពស្ដាប់គឺជាការទទួលយកនូវព័ត៌មានទាំងឡាយណា ដែលមានការទាក់ទងទៅនឹងវិញ្ញាណទាំងប្រាំរួមមាន សោតវិញ្ញាណ ចក្ខុវិញ្ញាណ ជីវ្ហាវិញ្ញាណ ឃានវិញ្ញាណ និងកាយវិញ្ញាណ។ ការស្ដាប់រឿងនិទានធ្វើឱ្យកុមារស្គាល់លក្ខណៈសូរបានច្បាស់លាស់ និងឃានវិញ្ញាណជួយឱ្យកុមារមានគំនិតសង្កេតឃើញពីមជ្ឈដ្ឋានជុំវិញរបស់កុមារដូចជា មនុស្ស សត្វ ននិងរុក្ខជាតិ ដែលមានការទំនាក់ទំនងគ្នាក្នុងសង្គមកាន់តែមានលក្ខណៈល្អប្រសើរ។

ឧទាហរណ៍៖ រឿងទន្សាយ និងខ្យង នៅពេលដែលកុមារស្ដាប់រឿងនេះរួច ធ្វើឱ្យកុមារបានដឹងពីសូរសំឡេងខុសគ្នារវាងសត្វទាំងពីរ បានស្គាល់រូបរាងរបស់សត្វនោះ និងបានដឹងពីល្បែងប្រាជ្ញារបស់សត្វទាំងពីរ តាមរយៈការនិទានរៀបរាប់របស់អ្នកគ្រូ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ក.១.៣ ការបង្កើនសមត្ថភាពក្នុងការត្រិះរិះពិចារណា

កុមារមានការត្រិះរិះពិចារណា ថ្លឹងថ្លែង ស្គាល់ល្អ ស្គាល់អាក្រក់ ស្គាល់គុណ ស្គាល់ទោស ដើម្បីធ្វើឱ្យជីវិតរស់នៅប្រចាំថ្ងៃ បានល្អប្រសើរឡើង។ ហើយមិនត្រឹមតែប៉ុណ្ណោះទេ ធ្វើឱ្យគំនិតរបស់កុមារកាន់តែមានការលូតលាស់បន្តិចម្តងៗ ដែលគេបានអនុវត្តរាល់ការពិចារណាបានល្អរបស់ពួកគេ។

### ក.១.៤ ការបង្កើនសមត្ថភាពផ្នែកបញ្ញាស្មារតី

ពេលដែលកុមារបានស្តាប់នូវរឿងនិទាន ធ្វើឱ្យកុមារមានភាពឆ្លាតវៃ អាចប៉ាន់ស្មាននូវសកម្មភាពដែលមិនទាន់កើតមានឡើង ចេះសម្តែងតួ ចូលចិត្តស្តាប់រឿងនិទាន បណ្តុះស្មារតីឱ្យស្រឡាញ់អក្សរសិល្ប៍ ស្រឡាញ់ការអាន បង្កើនការចងចាំបានតាមរយៈការសម្តែង ហើយធ្វើឱ្យកុមារទទួលបាននូវបទពិសោធ និងពង្រីកចំណេះដឹងបានកាន់តែល្អប្រសើរ និងមានបម្រុងប្រយ័ត្នខ្ពស់ក្នុងការគិត។

ឧទាហរណ៍៖ ពេលគ្រូនិទានរឿងចប់ គ្រូហៅកុមារស្ម័គ្រចិត្តម្នាក់ឬពីរនាក់ ឱ្យឡើងនិទានឡើងវិញ ដែលធ្វើឱ្យកុមារមានការចងចាំបានល្អ និងមានភាពវៃឆ្លាត។ ជាក់ស្តែងនៅក្នុងរឿងទន្សាយនិងខ្យង នៅពេល ស្តាប់ការនិទានរបស់គ្រូចប់ កុមារអាចប៉ាន់ស្មានថាតួអង្គទាំងពីរមានចរិកខុសគ្នា ដោយទន្សាយជាសត្វស្មោះត្រង់ រីឯសត្វខ្យងជាសត្វដែលមានគំនិតមិនល្អ។

### ក.១.៥ ការរីកចម្រើនផ្នែកមនោសញ្ចេតនា

ការស្តាប់រឿងនិទានគឺជាផ្នែកមួយ ដែលរួមចំណែកឱ្យកុមារបានធ្វើការដាក់អារម្មណ៍ទៅតាមតួអង្គក្នុងសាច់រឿងដូចជា ការលើកដាក់សំឡេង ការធ្វើកាយវិការ និងការធ្វើទឹកមុខទៅតាមតួអង្គនីមួយៗ ដែលឱ្យកុមារចេះបត់បែនទៅតាមស្ថានភាពពេលកំពុងសម្តែង។ ជាក់ស្តែងកុមារសម្តែងជើរតួអង្គតាមសត្វកង្កែប ពេលនោះកុមារបានដឹងថាសត្វកង្កែប ជាសត្វដែលមានកាយវិការខុសពីសត្វដទៃផ្សេងទៀត កុមារនឹងប្រើអារម្មណ៍របស់ពួកគេឱ្យចូលទៅតាមតួអង្គកង្កែបបានយ៉ាងងាយស្រួល។ ឧទាហរណ៍៖ កុមារក្រោយពីបានស្តាប់រឿងអប់រំអ្វីមួយ ដែលគ្រូបាននិទានចប់ កុមារអាចយល់ដឹងខ្លះពីអត្ថន័យនៃសាច់រឿងនោះ។ ដូច្នេះកុមារបានប្រើប្រាស់នូវអារម្មណ៍របស់ពួកគេ។

### ក.១.៦ ការបង្កើនសមត្ថភាពផ្នែកភាសា

ការស្តាប់រឿងនិទានក៏ជាផ្នែកមួយយ៉ាងសំខាន់ ក្នុងការជួយឱ្យកុមារបង្កើននូវសមត្ថភាពផ្នែកភាសាផងដែរ។ នៅពេលដែលកុមារបានស្តាប់ហើយ ពួកគេបានទទួលនូវអ្វីដែលថ្មីៗ តាមរយៈការអានពាក្យនៅក្នុងសាច់រឿង និងការថាតាមគ្រូ ឬតាមការចងចាំរបស់ពួកគេ ហើយកុមារអាចលើកដាក់សំឡេងតាមតួអង្គក្នុងសាច់រឿង ជាពិសេសកុមារអាចបង្កើតជាពាក្យ ឬប្រយោគខ្លីៗដែលមានន័យហើយស្តាប់បាន និងធ្វើឱ្យកុមារមានភាពក្លាហានក្នុងការនិយាយទៅកាន់អ្នកនៅជុំវិញខ្លួនរបស់ពួកគេ។ ឧទាហរណ៍៖ នៅក្នុងរឿងដើមឈើចេះនិយាយ ធ្វើឱ្យកុមារស្គាល់នូវពាក្យថ្មីដែលមាននៅក្នុងសាច់រឿង តាមរយៈការនិទានរបស់គ្រូ ហើយកុមារអាចប្រើប្រាស់នូវពាក្យមួយចំនួនទៅតាមអ្វីដែលគេបានដឹង ស្គាល់ និងស្តាប់ឮ ហ៊ានឆ្លើយតបនូវអ្វីដែលគ្រូបានសួរ និងចេះឆ្ងល់។

### ក.១.៧ សីលធម៌ក្នុងការរស់នៅ

ការស្តាប់រឿងនិទានមានឥទ្ធិពលយ៉ាងខ្លាំង ក្នុងការអប់រំអត្តចរិករបស់កុមារ។ ឆ្លងកាត់ តាមរយៈការស្តាប់រឿងនិទាន កុមារអាចត្រាប់តាមតួអង្គ គួបផ្សំនិងការអប់រំបន្ថែមរបស់លោកគ្រូ អ្នកគ្រូ ធ្វើឱ្យកុមារ

ចេះគួរសម ចេះសំពះ សាមគ្គីគ្នា យោគយល់អធ្យាស្រ័យគ្នា និងចេះបែងចែកអ្វីដែលខ្លួនមានឱ្យគ្នាទៅវិញទៅមក ហើយឱ្យកុមារចេះបត់បែន និងសម្របខ្លួនទៅតាមស្ថានភាពជាក់ស្តែងដែលពួកគេបានជួបប្រទះ។ គ្រប់រឿងនិទានអាចធ្វើឱ្យកុមារមានភាពក្លាហាន និងមានភាពស្មោះត្រង់ ហើយមិនយកតម្រាប់តាមតួអង្គមិនល្អ។ ឧទាហរណ៍៖ ក្នុងរឿងចចក និងកំពិស ពេលនិទានចប់ កុមារអាចប្រាប់បានថាតួអង្គសត្វកំពិសគឺជាសត្វដែលមានភាពវៃឆ្លាត ហើយមានការតស៊ូ និងចេះសាមគ្គីគ្នា អាចដោះស្រាយបញ្ហាប្រឈមចំពោះមុខបានដោយជោគជ័យ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ក.២ ការអភិវឌ្ឍក្នុងវិស័យទាំង ៥

| | |
|---|---|
| **ការអភិវឌ្ឍរូបរាងកាយ និងសុខភាព**  | - កុមាររៀនពីរបៀបធ្វើចលនាដៃ និងម្រាមដៃដើម្បីបើកទំព័រសៀវភៅ។<br>- ទាក់ទងនឹងអនាម័យ អាហារូបត្ថម្ភ និងធ្វើឱ្យកុមារមានការយល់ដឹងពីបញ្ហាសុខភាព។ |
| **ការអភិវឌ្ឍសីលធម៌ និងវប្បធម៌**  | - តាមរយៈការស្តាប់រឿងនិទាន ធ្វើឱ្យដឹងពីអំពើល្អ អាក្រក់ ដឹងខុស ស្គាល់ត្រូវ ស្គាល់គុណ ស្គាល់ទោស និងរស់នៅក្នុងសេចក្តីថ្លៃថ្នូរ ប្រព្រឹត្តតែអំពើល្អ មិនបៀតបៀនអ្នកដទៃ។<br>- តាមរយៈរឿងនិទាន ធ្វើឱ្យកុមារស្គាល់ យល់ដឹង និងបណ្តុះនូវការស្រឡាញ់ ការពារ ថែរក្សា អភិរក្ស និងអភិវឌ្ឍវប្បធម៌ជាតិ។ |
| **ការអភិវឌ្ឍសង្គម និងអារម្មណ៍**  | - រឿងនិទានធ្វើឱ្យកុមារមានទំនាក់ទំនង ការចែករំលែក ការលេងរវាងកុមារ និងកុមារ និងអ្នកនៅជុំវិញខ្លួន។<br>- តាមរយៈរឿងនិទានធ្វើឱ្យកុមារមានភាពសប្បាយរីករាយ និងសេចក្តីស្រឡាញ់ពេញចិត្ត។ |
| **ការអភិវឌ្ឍការយល់ដឹង និងការពិចារណា**  | - កុមារចេះថ្លឹងថ្លែង ស្គាល់ល្អ ស្គាល់អាក្រក់ ស្គាល់គុណ ស្គាល់ទោស ដើម្បីជីវិតរស់នៅបានល្អប្រសើរ។ កុមារបង្ហាញពីការយល់ដឹងពីហេតុ និងផល ហើយកុមារអាចបង្ហាញពីនិមិត្តសញ្ញា ពីតថភាពផ្សេងៗ ហើយគេអាចប៉ាន់ស្មាន និងទាយទុកនូវអ្វីដែលជាចុងបញ្ចប់នៃសាច់រឿង ព្យាយាមរកវិធីផ្សេងៗ ដើម្បីធ្វើអ្វីមួយជាមួយមិត្តភក្តិ បងប្អូន និងជាមួយឪពុកម្តាយ។ |
| **ការអភិវឌ្ឍភាសា**  | - កុមារយល់ដឹងពីសៀវភៅ។<br>- កុមាររីកចម្រើនពាក្យពេចន៍។<br>- កុមារសម្បូរទុននៃពាក្យ។<br>- កុមារចំណាំ/ស្គាល់តួអក្សរបាន។<br>- កុមារមានបំណិនក្នុងការទំនាក់ទំនង ទាំងការស្តាប់ និងការនិយាយ។ |

### ខ. ប្រភេទនៃការនិទានរឿង

ការនិទានរឿង គឺជាការនិយាយពិពណ៌នាពីរឿងអ្វីមួយឱ្យកុមារស្ដាប់ទៅតាមដំណើររឿងនោះ ដោយចាប់ពីដំបូងរហូតដល់ចប់សាច់រឿង។ ការនិទានរឿងវាមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងការអានរឿងដែរ ប៉ុន្តែការនិទានរឿងមានភាពទន់ភ្លន់បត់បែនជាងការអានរឿង ហើយការនិទានរឿងមិនមែនប្រើតែសៀវភៅរឿងមួយមុខនោះទេ គឺមានមធ្យោបាយផ្សេងច្រើនទៀត សម្រាប់បម្រើឱ្យការនិទានរឿង។ តាមរយៈមធ្យោបាយទាំងនោះ ត្រូវបានគេចែកវាទៅជាប្រភេទនីមួយៗនៃការនិទានរឿង។ ដើម្បីឱ្យកុមារចាប់ចិត្តដក់អារម្មណ៍ គ្រូដែលជាអ្នកនិទានរឿង ត្រូវចេះលើកដាក់សំឡេង ចេះប្រើសំឡេងជាតួអង្គផ្សេងៗគ្នា សម្ដែងអារម្មណ៍សប្បាយរីករាយ ត្រេកអរ ទុក្ខសោក ភ័យព្រួយ រំភើបញាប់ញ័រ តាមព្រឹត្តិការណ៍នានាក្នុងរឿងផងដែរ ។ គ្រូអាចជ្រើសរើសប្រភេទនៃការនិទានរឿងមួយណា ដែលគេប្រើនៅមត្តេយ្យសិក្សា ដូចខាងក្រោម៖

### ខ.១ ការនិទានរឿងដោយផ្ទាល់មាត់



រូបភាពទី 4៖ ការនិទានរឿងដោយផ្ទាល់មាត់

- ចេះចាំសាច់រឿងឱ្យបានច្បាស់លាស់
- ចេះធ្វើកាយវិការ ទឹកមុខ លើកដាក់សំឡេងតាមតួអង្គឱ្យបានសមស្របទៅនឹងខ្លឹមសាររឿង ហើយត្រូវប្រុងប្រយ័ត្ន និងចងចាំថាការនិទានផ្ទាល់មាត់ពុំមែនជា ការសម្ដែងរឿងទេ
- ឈរ ឬអង្គុយមួយកន្លែង មិនត្រូវដើរចុះ ដើរឡើង ម្ដងទៅឆ្វេង ម្ដងទៅស្ដាំឡើយ
- គោរពតាមជំហាននៃការនិទានរឿង( មានបម្រុងប្រយ័ត្ន-និទានរឿងពីដើមដល់ចប់ )

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## ខ.២ ការនិទានរឿងដោយប្រើសៀវភៅរូបភាព



រូបភាពទី 5៖ ការនិទានរឿងដោយប្រើសៀវភៅរូបភាព

- អ្នកនិទានត្រូវហាត់កាន់សៀវភៅឱ្យមានលំនឹង និងហាត់បើកទំព័រនីមួយៗឱ្យបានរហ័ស ដោយយកដៃទាំងពីរដាក់ផ្នែកខាងក្រោយនៃសៀវភៅ (ដៃឆ្វេងដាក់ផ្នែកខាងក្រោមដើម្បីទប់សៀវភៅ ឯដៃស្ដាំដាក់ផ្នែកខាងមុខរួចយកម្រាមដៃលូកទាញសន្លឹកទំព័រថ្មីបន្តបន្ទាប់ បើកធ្វើយ៉ាងណាកុំឱ្យដៃបាំងរូបភាព)។
- បើកសៀវភៅតាមទំព័រនីមួយៗ បង្ហាញរូបភាពឱ្យកុមារមើលឃើញបានច្បាស់ រួចបត់ច្បួតឱ្យរាបស្មើ ដើម្បីងាយក្នុងការបើកតាមសន្លឹកទំព័រ។
- សៀវភៅរឿងនិទានភាគច្រើន គឺមានរូបភាព១ទំព័រ និងអក្សរ១ទំព័រ ដូចនេះផ្នែកទំព័រ ដែលមានអក្សរត្រូវបត់ត្រឡប់ទៅក្រោយ ឯរូបភាពបែរទៅរកអ្នកស្ដាប់ដើម្បីឱ្យបានឃើញ(ចៀសវាងការបើកទំព័រពីរចេញទៅផ្នែកខាងមុខទាំងអស់)។ ប្រសិនបើមានរូបភាពរួមគ្នាក្នុងពេលតែមួយលើទំព័រទាំងពីរបន្តគ្នាអ្នកនិទានត្រូវបើកទាំងពីរទំព័រនោះតែម្ដង។
- រូបភាពខ្លះក៏ត្រូវទាមទារ ឱ្យមានការធ្វើចលនាកម្រើកទៅមុខ ថយក្រោយ ឬចុះក្រោម ដើម្បីបញ្ជាក់ពីសកម្មភាពរបស់តួអង្គ ក្នុងពេលសន្ទនាគ្នា។

**បញ្ជាក់៖** ចំពោះការបង្ហាញចំណងជើងរឿង អាចអនុវត្តដូចខាងក្រោម៖

- ចំពោះសៀវភៅដែលមានចំណងជើង និងរូបភាពនៅក្របមុខ អ្នកនិទានមិនត្រូវត្រដាងសៀវភៅទេ គឺគ្រាន់តែបង្ហាញក្របមុខជាការគ្រប់គ្រាន់។
- ចំពោះសៀវភៅដែលមានរូបភាពនៅក្របមុខ និងក្រោយ អ្នកនិទានត្រូវត្រដាងក្របសៀវភៅទាំងសងខាង ដើម្បីឱ្យកុមារមើលឃើញចំណងជើង និងរូបភាពទាំងអស់រួចបើកសៀវភៅនិទានដោយរំលងទំព័របុព្វកថា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ខ.៣.ការនិទានរឿងដោយប្រើរូបភាព

(អាវអៀម/ផ្ទាំងសំពត់សំឡី ផ្ទាំងរូបភាព ទូរទស្សន៍)

### ខ.៣.១ ការនិទានរឿងដោយប្រើផ្ទាំងរូបភាព





រូបភាពទី 6៖ ការនិទានរឿងដោយប្រើផ្ទាំងរូបភាព

- ត្រៀមប្រអប់សម្រាប់ប្រើជាមួយផ្ទាំងរូបភាព ដែលមានទំហំធំ។ មុនពេលនិទានត្រូវពិនិត្យផ្ទាំងរូបភាពនីមួយៗឱ្យបានច្បាស់។ ពេលនិទាន អ្នកគ្រូត្រូវចេះទាញផ្ទាំងរូបភាព១ផ្ទាំងម្តងៗ ទៅតាមខ្លឹមសារនៃសាច់រឿង រួចស៊កផ្ទាំងរូបភាពដែលនិទានរួចទៅផ្នែកខាងក្រោយជាបន្តបន្ទាប់។
- ផ្ទាំងរូបភាពដែលមានទំហំតូច អាចប្រើដោយកាន់ផ្ទាល់ដៃពុំចាំបាច់ប្រើជាមួយប្រអប់ឡើយ ដោយគ្រាន់តែកាន់ផ្ទាំងរូបភាពកុំឱ្យបាំង ឬជ្រុះផ្ទាំងរូបភាពពីដៃនិងប្រយ័ត្នរូបភាពប៉ោង ឬងើយហើយកុំឱ្យផ្អៀងចុះផ្អៀងឡើង។ ឯរបៀបទាញផ្ទាំងរូបភាពអនុវត្តដូចការប្រើប្រអប់ដែរ។

**បញ្ជាក់៖** ការនិទានដោយប្រើផ្ទាំងរូបភាព អ្នកនិទានត្រូវចេះកម្រើកផ្ទាំងរូបភាពនីមួយៗ ទៅតាមអត្ថន័យ និងខ្លឹមសារនៃរឿង។

### ខ.៣.២ ការនិទានរឿងដោយប្រើទូរទស្សន៍

- ត្រៀមគំនូរលើផ្ទាំងកំណាត់សំពត់ ឬក្រដាសទៅតាមខ្លឹមសារ និងលំដាប់លំដោយនៃសាច់រឿងពីដើមរហូតដល់ចប់ រួចមូរផ្ទាំងកំណាត់សំពត់ ឬក្រដាសគំនូរនោះទៅនឹងឈើមូលចាប់ពីចុងបញ្ចប់នៃសាច់រឿងទៅមុន។
- ពេលនិទានត្រូវនិទានបណ្តើរ វេដុំឈើនោះបណ្តើរ និទានដល់ណាវេផ្ទាំងរូបភាពដល់នោះ។

### ខ.៣.៣ ការនិទានរឿងដោយប្រើផ្ទាំងសំពត់សំឡី ឬអាវអៀម



រូបភាពទី 7៖ ការនិទានរឿងដោយប្រើផ្ទាំងសំពត់សំឡី ឬអាវអៀម

- ត្រៀមរូបតួអង្គទាំងអស់ក្នុងសាច់រឿងដែលត្រូវនិទានទុកជាស្រេច
- ពេលនិទានត្រូវនិទានបណ្តើរ បិទរូបតួអង្គបណ្តើរ ទៅតាមសាច់រឿងនៅលើផ្ទាំងសំពត់សំឡី ឬលើអាវអៀមទៅតាមលំដាប់លំដោយនៃសាច់រឿងពីដើមរហូតដល់ចប់។

### ខ.៤ ការនិទានរឿងដោយប្រើតុក្កតាឬអាយ៉ង



រូបភាពទី 8៖ ការនិទានរឿងដោយប្រើតុក្កតាឬអាយ៉ង

- ត្រៀមសម្ភារអាយ៉ង ឬតុក្កតាដែលធ្វើអំពីក្រដាសកាតុង កំណាត់សំពត់ ឬប្លាស្ទិចតាមតួអង្គក្នុងរឿងនីមួយៗដែលត្រូវនិទានទុកជាស្រេច និងត្រៀមឆាកសម្រាប់សម្តែងធ្វើពីក្រដាសកេស ឬកំណាត់ ចងខ្សែ។
- កំណត់ឈ្មោះ និងចំនួនតួអង្គ។
- ពេលនិទានត្រូវលើករូបភាពតួអង្គបង្ហាញតាមសាច់រឿង និងត្រូវប្រុងប្រយ័ត្នក្នុងការបង្ហាញរូបតួអង្គចៀសវាងរូបតួអង្គនិយាយដោយបែរខ្នងដាក់គ្នា ដើម្បីធ្វើឱ្យរឿងនិទានមានភាពរស់រវើក។ នៅពេលខ្លះអ្នកនិទានក៏ត្រូវធ្វើចលនារបស់តួអង្គទៅតាមសាច់រឿងជាក់ស្តែងដូចជា លោត រត់ សប្បាយចិត្ត ខឹង យំ វាយគ្នា ។ល។

**ខ.៥ ការនិទានរឿងបណ្តើរគូររូបបណ្តើរ**



រូបភាពទី 9៖ ការនិទានរឿងបណ្តើរគូររូបបណ្តើរ

- ជ្រើសរើសខ្លឹមសាររឿងណាដែលមានគំនូរងាយៗសមស្របតាមវ័យកុមារ
- និទានដល់ណាគូររូបដល់នោះ
- គូរតែរូបតួអង្គ និងសកម្មភាពសំខាន់ៗ
- រូបភាពដែលគូរត្រូវច្បាស់ និងងាយយល់។

**ខ.៦ ការសម្តែងតួតាមសាច់រឿង**



រូបភាពទី 10៖ ការសម្តែងតួតាមសាច់រឿង

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ជ្រើសរើសរឿងណាមួយ ដើម្បីធ្វើសកម្មភាពសម្តែងតួ ដោយរៀបចំកុមារស្ម័គ្រចិត្ត។
- អ្នកសម្តែងត្រូវចាំពាក្យសម្តីរបស់តួអង្គតាមរយៈការទន្ទេញចាំមាត់។ ដើម្បីជាជំនួយដល់ការចងចាំ គ្រូត្រូវនិយាយប្រាប់សម្តីរបស់តួអង្គនីមួយៗឱ្យអ្នកសម្តែងទន្ទេញ។
- ក្នុងពេលសម្តែង អ្នកសម្តែងត្រូវធ្វើដូចខាងក្រោមៈ
  - ត្រាប់តាមសំឡេងតួអង្គនីមួយៗក្នុងសាច់រឿង និងការវិការរបស់តួអង្គទាំងនោះផងដែរ។
  - ពាក់មុខតំណាងឱ្យតួអង្គដែលខ្លួននឹងសម្តែង ឬត្រូវតែងតួបន្ថែមអ្វីផ្សេងទៀតសម្រាប់សម្គាល់តួអង្គនីមួយៗទាំងនោះ ក្នុងករណីចាំបាច់ណាមួយ។

**បញ្ជាក់៖** គេអាចប្រើប្រាស់តុក្កតា ដើម្បីជំនួយក្នុងការស (អំពីកំណាត់សំពត់ ក្រដាស ស្លឹកឈើ ឬផ្លែឈើ) ម្តែង។ ការផលិតនេះពុំត្រូវការចំណាយថវិកាច្រើនទេ អាចកែច្នៃអ្វីដែលមានស្រាប់ ដូចជាកំណាត់ចាស់ៗ ក្រដាសកាតុងដែលបានមកពីឡាំង ឬប្រអប់ចាស់ៗ។ ការស្តែងបែបនេះត្រូវការពេលវេលា ដើម្បីរៀបចំដោយមានគ្រូជាអ្នកដឹកនាំ និងជួយផ្តល់យោបល់។ សម្ភារដែលផលិតហើយ ត្រូវរក្សាទុកសម្រាប់ការសម្តែងលើកក្រោយទៀត។

វិធីបង្រៀននីមួយៗសុទ្ធតែមានលក្ខណៈពិសេស និងគុណប្រយោជន៍ដូចគ្នាមិនអាចវាយតម្លៃថាវិធីណាល្អ ឬមិនល្អនោះទេ គឺអាស្រ័យដោយអ្នកនិទានមានភាពឈ្លាសវៃប្រើប្រាស់ វិធីទាំងនេះមកបង្រៀនរឿង និទាន ធ្វើឱ្យកុមារមានជំនក់ចិត្ត ចង់ស្តាប់ មានចំណូលចិត្តចង់អានសៀវភៅ និងស្តាប់ការទូន្មានអប់រំរបស់ មនុស្សចាស់ប្រកបដោយសេចក្តីស្រឡាញ់រំភើបរីករាយ។

**គ.ការបង្រៀននិងរៀន**

**គ.១ ដំណើរការនៃការនិទានរឿង**

ដើម្បីនិទានរឿងបានល្អនិងមានប្រសិទ្ធភាព គ្រូត្រូវជ្រើសរើសរឿងសម្រាប់យកមកនិទានឱ្យបានសមស្របតាមវ័យរបស់កុមារ ឆ្លើយតបនឹងវត្ថុបំណងរបស់មេរៀន ដោយអនុវត្តតាមដំណាក់កាលទាំងបី (មុនពេលនិទានរឿង អំឡុងពេលនិទានរឿង និងក្រោយពេលនិទានរឿង) កំណត់ពេលវេលា និងទីកន្លែង (ពេលណា រយៈពេលប៉ុន្មាន កន្លែងណា) ឱ្យបានច្បាស់លាស់ជាមុនសិន។ ខាងក្រោមនេះជាដំណាក់កាលទាំងបី នៃដំណើរការអនុវត្តការនិទានរឿង៖

**គ១.១ មុនពេលនិទានរឿង**

- ការជ្រើសរើសរឿង៖ គ្រូត្រូវចេះជ្រើសរើសប្រភេទរឿងទៅតាមវ័យ និងកម្រិតយល់ដឹងរបស់កុមារ។ រឿងសម្រាប់កុមារមានសាច់រឿងខ្លី តួអង្គតិច ពាក្យពេចន៍សាមញ្ញ រូបភាពមានពណ៌ភ្លឺច្បាស់ ចំណងជើងស្របនឹងខ្លឹមសារ បង្កប់នូវខ្លឹមសារអប់រំ ប្រើរយៈពេលសមស្របជាដើម។
- ការអនុវត្តមុនពេលនិទានរឿង៖ ដើម្បីឱ្យការនិទានមានភាពរលូន គ្រូគប្បីយល់ច្បាស់ពីអត្ថន័យនៃរឿង ហ្វឹកហាត់និទានឱ្យចេះចាំស្ទាត់ ហ្វឹកហាត់ធ្វើកាយវិការ ទឹកមុខ លើកដាក់សំឡេងតាមតួអង្គ របៀបឈរ ឬអង្គុយរបៀបកាន់សៀវភៅឱ្យមានលំនឹងហើយបើកទំព័រនីមួយៗឱ្យបានស្ទាត់ (ដៃទាំងពីរដាក់ផ្នែកខាងក្រោយនៃសៀវភៅ ដោយដៃឆ្វេងដាក់ផ្នែកខាងក្រោម ដើម្បីទប់សៀវភៅ ឯដៃស្តាំដាក់ផ្នែកខាងមុខ រួចយកម្រាមដៃលូកទាញសន្លឹកទំព័រថ្មីបន្តបន្ទាប់ ប៉ុន្តែកុំឱ្យដៃបាំងរូបភាព) ការធ្វើចលនាកម្រើករូបភាពមួយចំនួនដើម្បីបញ្ជាក់ពីសកម្មភាពរបស់តួអង្គ។

គ្រូក៏ត្រូវរៀបចំជាមុននូវអ្វីៗដែលជាតម្រូវការចាំបាច់ដូចជាសៀវភៅ រូបភាព ឧបករណ៍នានា ដែលទាក់ទងនឹងប្រភេទនៃការនិទានរឿង ទីកន្លែង តុ កៅអី កម្រាល...។

**គ១.២ អំឡុងពេលនិទានរឿង**

- គ្រូត្រូវរៀបចំការអង្គុយរបស់កុមារ ឱ្យមានរបៀបរៀបរយ និងមានសណ្ដាប់ធ្នាប់ត្រឹមត្រូវ ដូចជាការអង្គុយជាពាក់កណ្ដាលរង្វង់ អង្គុយជាអក្សរអ៊ុយ (U) អង្គុយចម្រុះគ្នាក្រោមម្លប់ឈើ ឬខាងមុខអាគារ ឬក្រោមអាគារ ធ្វើយ៉ាងណាកុំឱ្យបាំងភ្នែកកុមារ នៅទីកន្លែងទូលាយ មានអនាម័យ និងមានខ្យល់អាកាសគ្រប់គ្រាន់ប្រកបដោយផាសុកភាព និងសុខសុវត្ថិភាព។
- ការពញ្ញាក់អារម្មណ៍កុមារគឺជាការចាប់ផ្ដើមប្រមូលអារម្មណ៍កុមារដោយផ្ដើមឡើងពីការនិយាយសំណេះសំណាល ឬការសួរសំណួរផ្សេងៗ ឬច្រៀង ឬធ្វើលំហាត់សម្រន់ជាដើម ដើម្បីទាក់ទាញអារម្មណ៍ពួកគេឱ្យមកចូលក្នុងការនិទានរឿងរបស់គ្រូ។ គ្រូធ្វើការពញ្ញាក់អារម្មណ៍កុមារ តាមវិធីផ្សេងៗរបស់ខ្លួនដែលបានត្រៀមទុកមុនជាស្រេចនោះ ឬដូរវិធីថ្មីវិញ ដោយផ្អែកលើស្ថានភាពអ្វីមួយជាកត្តាជំរុញឱ្យមានការប្រែប្រួល។
- ការចាប់ផ្ដើមនិទានរឿង គឺជាពេលវេលាដែលគ្រូ និងកុមារ កំពុងតែធ្វើទំនាក់ទំនងគ្នាយ៉ាងពេញលេញហើយ។ ការនិទានរឿងត្រូវតែបន្លឺសំឡេងនិងធ្វើកាយវិការឱ្យបានច្បាស់ និងមិនត្រូវលឿនពេក ឬយឺតពេកនោះទេ ហើយបើមានសម្ភារ រូបភាព ក៏ត្រូវបង្ហាញឱ្យកុមារមើលបានគ្រប់ៗគ្នាដែរ។ ឥរិយាបថរបស់គ្រូក្នុងការនិទានរឿង គ្រូអាចអង្គុយបែបណាឱ្យកុមារបានមើលឃើញទាំងអស់គ្នា។ គ្រូនិទានរឿងដោយលើកដាក់សំឡេងតាមព្រឹត្តិការណ៍ និងតួអង្គនីមួយៗក្នុងសាច់រឿង។ គ្រូមិនត្រូវផ្ដោតទៅលើតែការនិទានរឿងមួយមុខប៉ុណ្ណោះទេ គ្រូគប្បីព្យាយាមមើលការចូលរួមរបស់កុមារឱ្យបានញឹកញាប់ ដើម្បីដឹងថាកុមារចាប់អារម្មណ៍ ឬមិនចាប់អារម្មណ៍ និងយកចិត្តទុកដាក់ស្ដាប់ការនិទានរឿងរបស់គ្រូបានកម្រិតណា និងដើម្បីចៀសវាងគ្រូនិទានរឿងតែម្នាក់ឯង រីឯកុមារមិនស្ដាប់ដោយធ្វើសកម្មភាពផ្សេងទៅវិញ។

**គ១.៣ ក្រោយពេលនិទានរឿង**

- ក្រោយពេលនិទានរឿងចប់ គ្រូមិនត្រូវសួរកុមារថាតើការនិទានរឿងនេះល្អដែរឬទេ? គ្រូគប្បីមើលប្រតិកម្មរបស់កុមារ។ប្រតិកម្មកុមារគឺជារង្វាយតម្លៃនៃការនិទានរឿង ព្រោះតាមរយៈសកម្មភាព ទឹកមុខ ខ្សែភ្នែករបស់ពួកគេ អាចឱ្យគ្រូដឹងបានថាពួកគេចូលចិត្ត ឬមិនចូលចិត្តរឿងនិទាន។ គ្រូអាចសួរទៅកុមារ៖ តើកូនៗពេញចិត្តនឹងរឿងនោះទេ? តើកូនចូលចិត្តតួអង្គណាជាងគេ? ព្រោះអ្វី? តើកូនណា អាចនិទានរឿងនេះឡើងវិញបាន? តើរឿងនេះគេ ចង់អប់រំអំពីអ្វី? ជាដើម។ បន្ទាប់មកគ្រូនិយាយរឿងសង្ខេបឡើងវិញ និងពន្យល់ពីតម្លៃនៃការអប់រំរបស់សាច់រឿង ដល់កុមារនិងត្រូវផ្ដល់ឱកាសឱ្យកុមារសង្ខេបរឿងឡើងវិញ ព្រមទាំងជួយបំពេញចន្លោះខ្វះខាតនៃសាច់រឿង។
- រៀបចំជ្រុងសៀវភៅដើម្បីដាក់សៀវភៅដែលគ្រូបាននិទានរួចនៅក្នុងជ្រុងនោះ និងដើម្បីឱ្យកុមារអាចជ្រើសរើសសៀវភៅតាមចំណង់ចំណូលចិត្តនិងមើលដោយខ្លួនឯង។
- ភ្ជាប់រឿងនិទានទៅសកម្មភាពផ្សេងៗ ដូចជាការសម្ដែង គូររូប ការនិទានរឿងដោយខ្លួនឯង...

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews



រូបភាពទី11 ៖ ក្រោយពេលនិទានរឿង

**បញ្ហាក់៖** បើស្ថានភាពនិទានរឿង កុមារមិនយកចិត្តទុកដាក់ស្ដាប់ លក្ខណៈបែបហ្នឹង គឺកុមារមិនទទួលបានអ្វីទេ ឯគ្រូក៏បង្រៀនមិនបានសម្រេចតាមវត្ថុបំណងមេរៀនដែរ។ គ្រូត្រូវសួរខ្លួនឯងភ្លាមថា តើមូលហេតុអ្វីបានជាកុមារមិនស្ដាប់ការនិទានរឿងរបស់ខ្លួន គឺមិនត្រូវស្ដីបន្ទោសកុមារឡើយ។ បញ្ហាវាអាចបណ្ដាលមកពីមូលហេតុផ្សេងៗ ដូចជារឿងដែលគ្រូលើកយកមកនិទាន មិនទាន់សមស្របនឹងវ័យរបស់កុមារ ឬរឿងនោះកុមារធ្លាប់ស្ដាប់ច្រើនដងរួចហើយ ឬរឿងនោះមានពាក្យពិបាកច្រើនពេកស្ដាប់មិនយល់ ឬការនិទានរបស់គ្រូមិនច្បាស់ ឬការនិទានរបស់គ្រូលឿនពេក ឬការបង្ហាញរូបភាពរបស់គ្រូមិនត្រូវតាមខ្លឹមសារនៃសាច់រឿងដែលកំពុងនិទានជាដើម។ ដូច្នេះគ្រូត្រូវរិះគិតតាមចំណុចនីមួយៗ ដូចបានរៀបរាប់ខាងលើ ឬលើចំណុចអ្វីផ្សេងទៀត ដែលបណ្ដាលឱ្យមានបញ្ហាបែបនេះ។ បើដឹងប្រាកដថា វាបណ្ដាលមកពីចំណុចណាច្បាស់ហើយនោះ គ្រូត្រូវកែច្នៃឡើងវិញ ដើម្បីឱ្យការបង្រៀនរបស់ខ្លួនធ្វើឱ្យកុមារទទួលបាននូវសម្បទាទាំងបី ដែលបានកំណត់រួចហើយនៅក្នុងវត្ថុបំណងរបស់មេរៀន។

### គ.១.៤ លំនាំនៃការបង្រៀនរឿងនិទាន

- និទានរឿងឱ្យកុមារស្ដាប់ (និទានដោយលើកដាក់សំឡេង កាយវិការ ទឹកមុខ ទៅតាមតួអង្គក្នុងសាច់រឿង)
- ពន្យល់ន័យនៃពាក្យពិបាក (ប្រសិនបើមាន)
- បំផុសសំណួរឱ្យកុមារយល់ដឹងពីអត្ថន័យនៃសាច់រឿង (ខ្លឹមសារ តួអង្គ ការអប់រំ...)
- សង្ខេបរឿងឱ្យកុមារស្ដាប់ឡើងវិញ
- ឱ្យកុមារនិទានរឿងឡើងវិញ
- បំផុសកុមាររកចំណងជើងរឿង
- ប្រាប់ឈ្មោះអ្នកនិពន្ធ។

**បញ្ជាក់៖** សម្រាប់ការអនុវត្តនៅក្នុងកម្រិតថ្នាក់នីមួយៗ គ្រូគប្បីមានភាពបត់បែនក្នុងការអនុវត្តដើម្បីសម្រេចបានសម្បទាទាំងបី តាមលទ្ធផលរំពឹងទុក ដែលបាន (វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា) ។(២០១៨)ចែងនៅក្នុងកម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ

### គ.២ ដំណើរការនៃអំណានរឿង

អំណានរឿង គឺជាការអានសាច់រឿងតាមខ្លឹមសារ ដែលមានក្នុងសៀវភៅឱ្យកុមារស្ដាប់ បញ្ចេញសូរសំឡេង លើកដាក់សំឡេងតាមឃ្លាល្បះនៃអត្ថបទ ជាតួអង្គផ្សេងៗនៅក្នុងសាច់រឿងនោះ។ ជាទូទៅការអានរឿងអ្វីមួយ នៅក្នុងសៀវភៅ មិនទាមទារឱ្យបន្ថែមឬបន្ថយខ្លឹមសារទេ។ ម្យ៉ាងទៀតការអានរឿង ឱ្យកុមារមត្តេយ្យស្ដាប់ គឺត្រូវជ្រើសរើសរឿងទាំងឡាយណា ដែលមានសាច់រឿងខ្លី ខ្លឹមសារអប់រំល្អ មានរូបភាពធំៗ និងពណ៌ធម្មជាតិច្បាស់ ជាពិសេសនៅពេលអានឱ្យកុមារស្ដាប់ គ្រូត្រូវអានដោយចង្អុលឱ្យចំពាក្យនីមួយៗ ដើម្បីឱ្យកុមារស្គាល់ពីទិសនៃអំណាន។

#### គ.២.១ មុនពេលអានរឿង

- ការជ្រើសរើសរឿង៖ គ្រូត្រូវជ្រើសរើសសៀវភៅ ដែលមានខ្នាតធំសម្រាប់កុមារមានចំនួនច្រើននាក់ និងសៀវភៅខ្នាតតូចសម្រាប់កុមារមានចំនួនតិចនាក់។ សៀវភៅមានខ្លឹមសាររឿងខ្លី មានអត្ថន័យអប់រំ មានរូបភាពច្បាស់ ពណ៌ច្បាស់ល្អ លេចធ្លោ បញ្ជាក់ពីចរិតលក្ខណៈ និងទង្វើរបស់តួអង្គ និងធម្មជាតិ មិនរន្ធត់ មិនភ័យពេក និងមានអក្សរតិចហើយធំៗ សមស្របតាមចំណូលចិត្ត និងវ័យរបស់កុមារ។
- ការអនុវត្តមុនពេលអានរឿង៖ ការអានរឿងមិនទាមទារពេលវេលាច្រើនក្នុងការរៀបចំនោះទេ។ ដើម្បីឱ្យការអានរឿងមានភាពរលូន គ្រូគប្បីចងចាំសាច់រឿងជាមុន ដោយអានសៀវភៅសាចុះសាឡើងឱ្យបានច្រើនដងឱ្យចាំឃ្លាសំណួរ ឃ្លាបដិសេធ ឬសម្ដីរបស់តួអង្គ ដើម្បីងាយស្រួលលើកដាក់សំឡេង ក្នុងពេលអាន។

#### គ.២.២ អំឡុងពេលអានរឿង

- គ្រូត្រូវរៀបចំការអង្គុយរបស់កុមារ និងទីកន្លែងដូចទៅនឹងការអនុវត្តសកម្មភាពនិទានរឿងខាងលើ។
- ការពញ្ញាក់អារម្មណ៍កុមារ ដើម្បីប្រមូលអារម្មណ៍របស់ពួកគេ អាចអនុវត្តដូចទៅនឹងសកម្មភាពនិទានរឿងខាងលើ។
- នៅពេលអានរឿង គ្រូត្រូវអង្គុយនៅទីតាំង ដែលកុមារមើលឃើញ និងកាន់សៀវភៅ ឱ្យអត្ថបទ និងរូបភាពបែរមុខទៅរកកុមារ។ គ្រូអានរឿងដោយប្រើម្រាមដៃ ឬបន្ទាត់ចង្អុលតាមតួអក្សរឱ្យកុមារស្ដាប់ និងសង្កេត ដោយមិនឱ្យបាំងរូបភាព។ គ្រូមិនត្រូវផ្ដោតទៅលើតែការអានរឿងមួយមុខប៉ុណ្ណោះទេ គ្រូគប្បីព្យាយាមមើលការចូលរួមរបស់កុមារឱ្យបានញឹកញាប់ ដើម្បីដឹងថាកុមារចាប់អារម្មណ៍ ឬមិនចាប់អារម្មណ៍ និងយកចិត្តទុកដាក់ស្ដាប់ការអានរឿងរបស់គ្រូបានកម្រិតណា និងដើម្បីចៀសវាងគ្រូអានរឿង០តែម្នាក់ឯង រីឯកុមារមិនស្ដាប់ដោយធ្វើសកម្មភាពផ្សេងទៅវិញ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### គ.២.៣ ក្រោយពេលអានរឿង

- ក្រោយពេលអានរឿងចប់ គ្រូអាចអនុវត្តប្រហាក់ប្រហែលទៅនឹងសកម្មភាព ដែលបានសរសេរនៅក្នុងការនិទានរឿងខាងលើដែរ ដូចជាការពិនិត្យប្រតិកម្មកុមារ ដើម្បីដឹងពីរង្វាយតម្លៃនៃការអានរឿង ការបំផុសសំណួរកុមារទាក់ទងតួអង្គ ការវិភាគតួអង្គ និងអត្ថន័យរឿង ការឱ្យកុមារអានរឿងឡើងវិញតាមការចងចាំ ការទុកដាក់សៀវភៅ និងសកម្មភាពដែលអាចអនុវត្តបន្តបន្ទាប់ពីអំណានរឿងជាដើម។

### គ.២.៤ លំនាំនៃការបង្រៀនអំណានរឿង

- បង្ហាញក្របសៀវភៅ ឱ្យកុមារមើល រូបភាព រួចប៉ាន់ស្មានទាយចំណងជើងរឿង
- បើកសៀវភៅបង្ហាញរូបភាពមួយសន្លឹកម្តងៗរហូតចប់សាច់រឿង និងឱ្យកុមារទាយចំណងជើងម្តងទៀត
- ប្រាប់ចំណងជើងរឿង និងផ្ទៀងផ្ទាត់ការប៉ាន់ស្មានដាក់ចំណងជើងរបស់កុមារ
- ប្រាប់ឈ្មោះអ្នកនិពន្ធ
- អានរឿង និងចង្អុលតាមតួអក្សរឱ្យកុមារស្តាប់ និងសង្កេត ដោយមិនឱ្យបាំងរូបភាព
- ពន្យល់ន័យនៃពាក្យពិបាក (ប្រសិនបើមាន)
- បំផុសសំណួរឱ្យកុមារយល់ដឹងពីអត្ថន័យនៃសាច់រឿង (ខ្លឹមសារ តួអង្គ ការអប់រំ...)
- ឱ្យកុមារចង្អុល និងអានពាក្យក្នុងរឿងតាមការចងចាំ។

**បញ្ជាក់៖** ការអានរឿងអនុវត្តសម្រាប់តែថ្នាក់កម្រិតខ្ពស់។

### ៣.៤.៣ កំណាព្យ

### ក. សារៈសំខាន់កំណាព្យ

កំណាព្យខ្មែរ មានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ជីវិតរស់នៅរបស់ប្រជាជនខ្មែរ ព្រោះថា កំណាព្យ បានធ្វើឱ្យមនុស្សមានភាពរីករាយ ស្រាកស្រាន្តពីសេចក្តីនឿយហត់ ឬសេចក្តីទុក្ខព្រួយផងទាំងពួង បើសិនគេបានអាន សូត្រ ស្តាប់កំណាព្យ។ កំណាព្យមានឥទ្ធិពលខ្លាំង ក្នុងការទាក់ទាញការយកចិត្តទុកដាក់ របស់កុមារឱ្យមានស្តាប់ជាងអត្ថបទពាក្យរាយ ដោយសារកំណាព្យវាមានឥទ្ធិពលយ៉ាងខ្លាំង។ ដូច្នេះការអប់រំកុមារអំពីបញ្ហានានា តាមរយៈកំណាព្យក៏ទទួលបានលទ្ធផលល្អប្រសើរដែរ។

កំណាព្យខ្មែរមាន១៣មេកាព្យមូលដ្ឋាន និងមានរបៀបសូត្ររហូតដល់៥៦បែប ប៉ុន្តែសម្រាប់កម្រិត មត្តេយ្យសិក្សាយើង បានជ្រើសរើសយកតែប្រភេទបទមូលដ្ឋានដែលងាយៗមួយចំនួន និងរបៀបសូត្រងាយៗតែមួយចំនួនប៉ុណ្ណោះ។ បទកំណាព្យទ រួមមានដូចជា បទកាកគតិ បទពាក្យប្រាំពីរ បទភុជង្គលីលា បទព្រហ្មគីតិ ជាដើម។

### ក ១.និយមន័យ

កំណាព្យជាសិល្បអត្ថបទ ដែលមានចំណាប់ចួនត្រឹមត្រូវតាមក្បួនខ្នាតប្រកបដោយសូរសំឡេងពិរោះរណ្តំណែងណង ដែលបង្កើតបរិយាកាសប្លែកៗនៅក្នុងបេះដូងរបស់អ្នកអាននិងអ្នកស្តាប់ កំណាព្យដែលពិរោះមិនត្រឹមតែចេះនិពន្ធឱ្យចាប់ចុងចួនរណ្តំនោះទេ ថែមទាំងគួបផ្សំដោយមនោសញ្ចេតនាពុះពាររបស់កវីទៀតផង ។ កំណាព្យសម្រាប់មត្តេយ្យសិក្សាមានពីរប្រភេទគឺ៖

- កំណាព្យសម្រាប់អប់រំកុមារឱ្យមានសីលធម៌ល្អ មានអនាម័យ ចំណេះដឹងនិងស្រឡាញ់សោភ័ណ ។
- កំណាព្យដែលជ្រើសរើសក្នុងអត្ថបទនានា មកអានឱ្យកុមារស្ដាប់ដើម្បីទម្លាប់ឱ្យកុមារចេះស្ដាប់ពាក្យចូនភាសាខ្មែរ ស្រឡាញ់ព្រលឹងអក្សរសិល្ប៍ខ្មែរ ។

**ក.២ ធាតុសំខាន់ៗទាំងបីរបស់កំណាព្យ**

គឺជាវង្វាស់កាព្យ ចំណាប់ចួន និង ចង្វាក់។

**ក.៣ វង្វាស់កាព្យ**

គឺជាចំនួនព្យាង្គ (ព្យ ) ក្នុងឃ្លា (ឃ) និងចំនួនឃ្លាក្នុងល្បះ (ល) ។

**ឧទាហរណ៍៖**

- បទកាកគតិ៖ ១ល =៧ឃ
  ១ឃ =៤ព្យ
- បទព្រហ្មគីតិ៖ ១ល =៤ឃ
  ឃ១ =៥ព្យ ឃ២ =៦ព្យ
  ឃ៣ =៥ព្យ ឃ៤ =៦ព្យ
- បទកុជង្គលីលា៖ ១ល =៣ឃ
  ឃ១ =៦ព្យ ឃ២ =៤ព្យ
  ឃ៣ =៤ព្យ ឃ៤ =៦ព្យ
- បទពាក្យ ៧: ១ល =៤ឃ
  ១ឃ =៧ព្យ

**បញ្ជាក់៖** សូមកុំច្រឡំមួយពាក្យ ទៅនឹងមួយព្យាង្គឱ្យសោះ។ មួយព្យាង្គ គឺមួយសូរសំឡេងឬសូរសំឡេងមួយម៉ាត់។ រីឯមួយពាក្យវិញ អាចមានសូរសំឡេងមួយព្យាង្គ ឬច្រើនព្យាង្គ។

**ក.៤ ចំណាប់ចួន**

គឺជាសូរសំឡេងដែលដូច ឬស្រដៀងគ្នា។ ចំណាប់ចួនដែលល្អ គឺជាចំណាប់ចួនដែល សូរពួក[អ]ចួននឹងពួក[អ] ហើយសូរពួក[អ៊]ចួននឹងពួក[អ៊]។ តែបើចំណាប់ចួន គ្រាន់តែមានសូរសំឡេងស្រដៀង គេហៅថាចួនរលឿ ហើយចំណាប់ចួនបែបនេះមិនសូវល្អទេ។ ចំណាប់ចួនមានពីរ គឺចំណាប់ចួនឆ្លងឃ្លា និងចំណាប់ចួនឆ្លងល្បះ។

**ក.៥ ចង្វាក់**

គឺជាការលើកដាក់ បន្តឹងបន្ធូរ សង្កត់ បន្ធើរឬបង្អូស សំឡេងលើព្យាង្គណាមួយ នៃឃ្លាណាមួយ ហើយការលើកដាក់សំឡេងនេះ ដែលធ្វើឱ្យកំណាព្យមានសូរស័ព្ទសំឡេងពីរោះ។ ចង្វាក់ប្រែប្រួលទៅតាមប្រភេទបទ នីមួយៗ នៃកំណាព្យ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ក.៦ លក្ខណៈ ពិសេសរបស់កំណាព្យ

ខ្លីប៉ុន្តែខ្លឹម៖ លើកលែងតែកំណាព្យរឿង កំណាព្យដែលល្អមិនមែនសំដៅលើអត្ថបទវែងអន្លាយនោះទេ។ អត្ថបទកំណាព្យខ្លះវែង ច្រើនឃ្លា ច្រើនល្បះ ច្រើនទំព័រ ប៉ុន្តែខ្លឹមសារមានតិចតួចស្តួចស្តើងពេក ។ កំណាព្យដែលល្អគឺ មានលក្ខណខ្លី ប៉ុន្តែពោរពេញដោយខ្លឹមសារ។ កវីមានទេពកោសល្យ ក្នុងការប្រមូលផ្តុំគំនិតធំៗសំខាន់ៗ ( វិធីកំណុំ និងកំហាប់ ) ។

ភាសាកាព្យ៖ជាភាសាពិសេសដែលគេប្រើប្រាស់ក្នុងការតែងនិពន្ធកំណាព្យភាសានេះមានលក្ខណទន់ភ្លន់មានទឹកដមពិរោះរណ្តំណែងណង និងមានរូបារម្មណ៍រស់រវើកកវីថ្លឹងថ្លែង និងប្រយ័ត្នប្រយែងក្នុងការសំរិតសំរាំងចំរាញ់ពាក្យពេចន៍ ឃ្លាឃ្លោង។ លក្ខណៈពិសេសទាំងពីរខាងលើនេះ អាចបង្កើតបានគ្រប់ទិដ្ឋភាព បរិយាកាសក្នុងបេះដូងអ្នកអាននិងអ្នកស្តាប់។

**ឧទាហរណ៍៖ បទព្រហ្មគីតិ**

**កំណើតៈ** បទនេះកើតឡើងនៅសម័យអង្គរ

**ចង្វាក់ៈ** ទម្លាក់សំឡេងលើព្យាង្គទី២ ចំពោះឃ្លាមាន៥ព្យាង្គ និងលើព្យាង្គទី៣ ចំពោះឃ្លាមាន៦ព្យាង្គ។

**បរិយាកាសៈ** បទនេះគេយកទៅប្រើ ដើម្បីសំដែងភាពលន្លង់លន្លោច សេចក្តីទុក្ខសោក ការព្រាត់ប្រាសត្អូញត្អែផ្តែផ្តាំ ប្រៀនប្រដៅ និងស្ថានភាពផ្សេងៗទៀតក៏បាន។

**វង្វាស់កាព្យៈ** មួយវគ្គមាន ៤ឃ្លា ។ ឃ្លាទី១ ទី៣មាន ៥ព្យាង្គ និងឃ្លាទី២ ទី៤ មាន៦ព្យាង្គ។

**ចំណាប់ចួនៈ** មានពីរបែបគឺ៖

- **បែបទី១**



នេះបទព្រហ្ម**គីតិ** ពីព្រេង**ព្រឹទ្ធ**ទុកទូ**ន្មាន**
ចែងចងជានិ**ទាន** ទុកគ្រាន់មើលជាច្បាប់**ថ្មី**។
ឱ្យអស់កូនចៅ**ក្រោយ** ស្តាប់កុំ**ឱ្យ**ភ្លេចស្មារ**តី**
ប្រដៅទាំងប្រុស**ស្រី** យកទុកខ្លួនគ្រប់អាត្មា។

• **បែបទី២**



ពេលក្រោកពីព្រ**លឹម** មុខញញឹមរីកស្រស់**ស្រាយ**
មុឺម្នាសំអាត**កាយ** មិននឿយ**ណាយ**រៀបទុក**ដាក់** ។
មុងភួយកន្ទេល**ខ្នើយ** រៀបឱ្យ**ហើយ**ដោយស្មោះ**ស្ម័គ្រ**
កុំផ្អែកលើម្ដាយ**ម្នាក់** ត្រូវចេះ**ភ្ជាក់**ជួយគ្រប់គ្រា ។

**ឧទាហរណ៍៖ បទកាកគតិ**

**កំណើត៖** បទនេះ កើតឡើងនៅសម័យ អង្គរ

**ចង្វាក់៖** ទម្លាក់សំឡេងលើព្យាង្គទី២គ្រប់ឃ្លា។

**បរិយាកាស៖** ពណ៌នារៀបរាប់ពីដំណើររឿងមានចលនា រឿងរ៉ាវមានភាពសោកសៅ ស្ដាយស្រណោះ ការទូន្មានប្រៀនប្រដៅ និងបញ្ហាផ្សេងៗទៀត។

**វង្វាស់កាព្យ៖** មួយវគ្គមាន ៧ឃ្លា ឃ្លានីមួយៗ៤ព្យាង្គឬពាក្យ។

**ចំណាប់ចួន៖** បទកាកគតិមានពីរ បែបគឺ៖





youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| ពួកមិត្ត**អើយ** | កុំនៅ**កន្តើយ** | យើងទៅ**សាលា** |
| យើងលេងយើងគូរ | យើងដើរ**ទស្សនា** | កន្លែង**នានា** |
| | បង្កើន**ចំណេះ** ។ | |
| សង្កេតឱ្យច្បាស់ **ចេះ** | រួចហើយគូរវាស | តាមការចាំ |
| យើងដាំបន្លែ | បានផ្លែយើងបេះ យើងទៅសាលា ។ | មិត្តកុំគេចវេះ |

## ខ. ការបង្រៀននិងរៀន

ការបង្រៀនកំណាព្យត្រូវឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុកដែលបានកំណត់នៅក្នុងកម្មវិធីសិក្សាសម្រាប់មត្តេយ្យសិក្សារដ្ឋ ក្នុងនោះបានផ្តោតលើប្រធានបទ ការស្គាល់តួអក្សរ ដែលឋិតនៅក្នុងខ្លឹមសារការយល់ដឹងពីភាពខុសគ្នានៃសូរសំឡេង និងកំណាព្យ។ លទ្ធផលរំពឹងទុកនៃការបងរៀននិងរៀនកំណាព្យមានដូចជា៖

- **វិជ្ជាសម្បទា៖** ប្រាប់ពីចំណងជើង អត្ថបទនៃកំណាព្យ ពាក្យចួន និងខ្លឹមសាររបស់កំណាព្យ
- **បំណិនសម្បទា៖** សូត្រកំណាព្យបានត្រឹមត្រូវ តាមរបៀបសូត្រនៃបទកំណាព្យនីមួយៗ
- **ចរិយាសម្បទា៖** មានបម្រុងប្រយ័ត្នក្នុងការស្តាប់សូរសំឡេង និងស្រឡាញ់ចូលចិត្តសូត្រកំណាព្យ។

## ខ.១ លំនាំនៃការបងៀននិងរៀនកំណាព្យ

### ខ.១.១ ពេលទី១៖




រូបភាពទី 12៖ លំនាំនៃការបងៀននិងរៀនកំណាព្យ

- សូត្រកំណាព្យឱ្យកុមារស្ដាប់ មួយចប់ជាមុនសិន
- នាំកុមារអានអត្ថបទ(រូបភាព) អាននិងពន្យល់ន័យពាក្យពិបាក
- នាំកុមារសូត្រកំណាក្យឃ្លា១ ឃ្លាទី២ បន្ទាប់មកសូត្រឃ្លាទី១ និងឃ្លាទី២ រួមបញ្ចូលគ្នា
- សូត្រឃ្លាបន្តបន្ទាប់ តាមរបៀបខាងលើ រហូតដល់ចប់
- ឱ្យកុមារប្រាប់ពីខ្លឹមសារ នៃកំណាព្យ និងបំពេញបន្ថែមឬកែតម្រូវ
- ប្រាប់ពាក្យចួនពីឃ្លាមួយទៅមួយ ក្នុងអត្ថបទកំណាព្យដល់កុមារ
- បំផុសរកចំណងជើងកំណាព្យ និងប្រាប់ឈ្មោះអ្នកនិពន្ធ(អាចនៅពេលចាប់ផ្ដើមក៏បាន)។

**ខ.១.២ ពេលទី២**

- ឱ្យកុមារប្រាប់ចំណងជើងកំណាព្យ
- សួរកុមារឱ្យប្រាប់ពាក្យចួនពីឃ្លាមួយទៅមួយ ក្នុងអត្ថបទកំណាព្យ
- ឱ្យកុមារសូត្រកំណាព្យពេលទី១ សារឡើងវិញ
- សូត្រតិចៗ ឱ្យកុមារសូត្រឮៗ(ក្រុមធំ/តូច)
- ឱ្យកុមារសូត្រកំណាក្យបណ្ដាក់គ្នា តាមសញ្ញាបញ្ជារបស់គ្រូ
- កុមារសូត្រឡើងវិញ ឱ្យបាន១ឬ២ចប់។

**បញ្ជាក់:** ការបង្រៀនកំណាព្យ គ្រូត្រូវព្យាយាមបង្កើតរូបភាពតំណាងឱ្យពាក្យនីមួយៗ ដែលមាននៅក្នុងអត្ថបទកំណាព្យ និងបិទរូបភាពទាំងនោះ តាមលំដាប់ខ្លឹមសារកំណាព្យនៅលើក្ដារខៀន ដើម្បីឱ្យកុមារមើលនិងចងចាំពាក្យ ដែលតំណាងដោយរូបភាពនីមួយៗ។ ម្យ៉ាងទៀតការលើកយកអត្ថបទកំណាព្យ មកបង្រៀនក៏ត្រូវគិតតាមកម្រិតថ្នាក់មត្តេយ្យសិក្សាផងដែរ។(មើលកំណាព្យក្នុងឧបសម្ព័ន្ធ)

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ជំពូក ៤

# ការរៀបចំបរិស្ថានសិក្សា នៃមុខវិជ្ជាភាសាខ្មែរ

## ជំពូក៤ ការរៀបចំបរិស្ថានសិក្សា នៃមុខវិជ្ជាភាសាខ្មែរ

### ៤.១. យន្តការអនុវត្ត

ការរៀបចំបរិស្ថានសម្រាប់អនុវត្តការបង្រៀនជាការងារចាំបាច់ ព្រោះថាវាជាចំណុចសំខាន់មួយក្នុងចំណោមចំណុចសំខាន់នានា នៃដំណើរការបង្រៀននិងរៀនរបស់គ្រូនិងកុមារ។ ការរៀបចំបរិស្ថានសិក្សានេះ មានបរិស្ថានក្នុងថ្នាក់រៀននិងបរិស្ថានក្រៅថ្នាក់ ដោយផ្តោតលើបរិស្ថានទាំងបី ដើម្បីបង្កើតនូវភាពទាក់ទាញស្រឡាញ់ពេញចិត្តពីកុមារ ដែលបម្រើឱ្យសកម្មភាពបង្រៀននិងរៀន ហើយកុមារនឹងទទួលបានចំណេះដឹងយ៉ាងច្រើនពីបរិស្ថាននោះដែរ។

ការរៀបចំបរិស្ថានក្នុងថ្នាក់រៀន ដូចជា ក្តារខៀន តុកៅអីគ្រូ តុកៅអីកុមារ កម្រាលសម្រាប់កុមាររៀន ឬធ្វើសកម្មភាព ជ្រុងអនាម័យ ជ្រុងវិទ្យាសាស្ត្រ ជ្រុងល្បែង ជ្រុងសិល្បៈ ជ្រុងសិក្សា កន្លែងទុកដាក់ស្បែកជើង(អាចនៅក្រៅថ្នាក់)ទូរដាក់កាតាបសម្រាប់កុមារ ការតាំងលម្អរូបភាពផ្សេងៗ និងស្នាដៃកុមារ។

ការរៀបចំបរិស្ថានក្រៅថ្នាក់ ដូចជា ល្បែងក្រៅថ្នាក់ (...ក្តាររំអិល ទោងយោល ជញ្ជីងប៉ាក់ប៉ើក) ទីធ្លាសម្រាប់សកម្មភាពផ្សេងៗ អាងខ្សាច់ សួនជីវចម្រុះ។

ការបង្រៀនបុរេសំណេរ ការស្គាល់អក្សរ រឿងនិទាន និងកំណាព្យ គឺទាមទារការរៀបចំថ្នាក់រៀន/មានរបៀបរៀបរយ អនាម័យល្អ ផាសុកភាព និងទីធ្លាទាំងក្នុងនិងក្រៅថ្នាក់ជាទីមេត្រី ប្រកបដោយសុវត្ថិភាពសម្រាប់ការរៀនសូត្ររបស់កុមារ។ យើងសង្ឃឹមថាកុមាររៀនសូត្របានកាន់តែច្រើន ហើយមានគុណភាពកាន់តែប្រសើរ ដោយសារការរៀបចំបរិស្ថានបានសម្បូរបែបនិងត្រឹមត្រូវល្អ។

### ៤.២. គម្រូវការធនធានសម្ភារឧបទេសសិក្សា

សម្ភារឧបទេសសិក្សាគឺជារបស់របរនានា សម្រាប់បម្រើដល់ការសិក្សារៀនសូត្ររបស់សិស្សានុសិស្ស។ ដូចជា៖ អគារសិក្សា បណ្ណាល័យ ទីលានកីឡា សួនជីវចម្រុះ តុ កៅអី ក្តារខៀន កន្ទេល បណ្ណរូបភាព បណ្ណពាក្យ បណ្ណឃ្លា អក្សរចល័ត សម្ភារល្បែង និងសម្ភារផលិតតាមមេរៀន ផ្ទាំងរូបភាព សៀវភៅរឿងនិទាន សម្ភាររឿងនិទាននានា ខ្មៅដៃ ខ្មៅដៃពណ៌ និងអ្វីៗផ្សេងច្រើនទៀត។ ក្រៅពីគិតលើធនធានសម្ភារឧបទេសសំខាន់ចម្បងៗ គ្រូក៏ត្រូវគិតពីអ្វីដែលជាសម្ភារឧបទេសសំខាន់ៗចាំបាច់ផ្តោតលើមុខវិជ្ជាភាសាខ្មែរ ដើម្បីប្រើប្រាស់ក្នុងការបង្រៀនកុមារឱ្យទទួលបានលទ្ធផលល្អប្រសើរផងដែរ។

- ឧទាហរណ៍សម្ភារឧបទេសក្នុងថ្នាក់រៀន៖ មានក្តារខៀន តុកៅអីគ្រូ តុកៅអីកុមារ កម្រាលកន្ទេល ឬ) របស់សម្រាប់ក្រាលឱ្យកុមារអង្គុយបាន (សម្ភារអនាម័យ (..កន្សែង សាប៊ូ ធុងទឹក ផ្តិល) ទូដាក់សម្ភារ ទូ ឬកន្លែងសម្រាប់កុមារសម្ភារផ្ទាល់ខ្លួន ទូឬកន្លែងដាក់ទ្រនាប់ជើងរបស់កុមារ។..
- ឧទាហរណ៍សម្ភារឧបទេសដែលត្រូវប្រើពេលនិទានរឿងដោយប្រើសៀវភៅរូបភាព៖
  - សៀវភៅរឿងដែលមានរូបភាពនិងខ្លឹមសារល្អទាក់ទងនឹង វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា វិទ្យាសាស្ត្រ បាតុភូតធម្មជាតិ ដែលសមស្របនឹងកម្រិតអាយុរបស់កុមារមត្តេយ្យសិក្សា។
  - កន្ទេល ឬកៅអី សម្ភារចាំបាច់ផ្សេងទៀត ដែលត្រូវការ។
- ឧទាហរណ៍សម្ភារឧបទេសដែលត្រូវប្រើពេលនិទានរឿងដោយប្រើផ្ទាំងរូបភាព៖



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ត្រូវមានផ្ទាំងរូបភាព នៃឈុតឆាកនីមួយៗនិងតួអង្គសំខាន់ៗគួរជាទីចាប់ចិត្ត ដើម្បីទាក់ទាញការចាប់អារម្មណ៍ពីកុមារ និងកុមារងាយតាមដាននិងចងចាំសាច់រឿងល្អ។ សម្ភារទាំងនោះអាចផលិតខ្លួនឯង ឬស្វែងរកតាមមធ្យោបាយណា ដែលធ្វើទៅបានឱ្យតែសមស្របនឹងសាច់រឿងត្រូវលើកយកមកនិទាននោះ។
- កន្ទេល ឬកៅអី សម្ភារចាំបាច់ផ្សេងទៀត ដែលត្រូវការ។

## ៤.៣. គោលការណ៍ ឬបញ្ញត្តិប្រតិបត្តិ

- ការរៀបចំកន្លែងសិក្សារៀនសូត្រ ត្រូវឱ្យសមស្របតាមគរុកោសល្យ ថ្នាក់រៀនត្រូវមានពន្លឺគ្រប់គ្រាន់ ខ្យល់អាកាសចេញចូលល្អ មានសោភណភាព ប្រកបដោយអនាម័យនិងសុវត្ថិភាព ឆ្លើយតបទៅនឹងគោលការណែនាំនានារបស់ក្រសួងអប់រំ យុវជន និងកីឡា។ ដូចជា សេចក្ដីណែនាំបរវេសនកាល ស្តង់ដារអប្បរមាថ្នាក់រៀននិងសាលារៀនជាដើម។
- ឥរិយាបថនិងអាកប្បកិរិយារបស់គ្រូ ត្រូវគោរពនិងប្រតិបត្តិតាមក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន និងបទបញ្ជាផ្ទៃក្នុងរបស់សាលាផងដែរ។ ការបង្រៀនត្រូវឈរលើស្មារតីទទួលខុសត្រូវខ្ពស់ គឺបង្រៀនពិតជាបង្រៀនមិនត្រូវមកបង្រៀនដោយខ្ជះកិច្ចតែងការ សម្ភារឧបទេស ឬបង្រៀនមិនមានការសង្កេតតាមដានចំពោះកុមារនោះឡើយ។

## ៤.៤. ការស្វែងរកការគាំទ្រផ្សេងៗ

នាយកឬនាយិកា គ្រូបង្រៀនគួមានបំណិនទំនាក់ទំនងយ៉ាងប៉ិនប្រសប់ ជាមួយគ្រប់ភាគីអ្នកពាក់ព័ន្ធ។ ដូចជា រវាងនាយកឬនាយិកា នឹងគ្រូទាំងអស់ ឬគ្រូបង្រៀននឹងគ្រូបង្រៀនដូចគ្នា ទាំងក្នុង និងក្រៅសាលា ជាមួយមាតាបិតា ជាមួយសហគមន៍ ជាមួយព្រះសង្ឃជាមួយអាជ្ញាធរមូលដ្ឋាន ជាមួយអ្នកនយោបាយ និងជាពិសេសជាមួយដៃគូអភិវឌ្ឍន៍នានាផងដែរ។ ទំនាក់ទនងល្អនាំមកនូវការរាប់អានល្អ ការរាប់អានល្អ នាំមកនូវភាពជិតស្និទនិងការជឿទុកចិត្តល្អ ភាពជិតស្និទនិងការជឿទុកចិត្ត នឹងអាចនាំមកនូវការជួយគាំទ្រដល់ការអភិវឌ្ឍថ្នាក់ឬសាលារៀនបាន។ ប្រកពទាំងនេះ នឹងជួយគាំទ្រ សាលាយើងបានទាន់ពេលវេលាបំផុតនិងមិនរីងស្ងួតរីងស្ងួតឡើយ បើសិនបើសាលារបស់យើងទទួលបានការជឿទុកចិត្តពីពួកគាត់ហើយ។

# ជំពូក ៥

# ការពិនិត្យតាមដាន និងវាយតម្លៃ

t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

## ជំពូក៥ ការពិនិត្យតាមដាន និងវាយតម្លៃ

### ៥.១. ចំពោះគ្រូ

គ្រូបង្រៀនត្រូវធ្វើស្វ័យវាយតម្លៃខ្លួនឯង រៀងរាល់ម៉ោងសិក្សារៀនសូត្រមេរៀននីមួយៗនៃភាសាខ្មែរ លើពីសកម្មភាព វិធីសាស្ត្របង្រៀន ការប្រើប្រាស់សម្ភារ ការសម្របសម្រួលកុមារ ការគ្រប់គ្រងពេលវេលា ការចូលរួមសកម្មភាពរបស់កុមារ និងលទ្ធផលសិក្សារបស់កុមារ។ តើហេតុអ្វីចាំបាច់ធ្វើស្វ័យវាយតម្លៃខ្លួនឯងហេតុផលគឺ ដើម្បីឆ្លុះបញ្ចាំងនិងកែលម្អនូវរាល់ចំណុចខ្វះខាតរបស់ខ្លួន និងឈានទៅអនុវត្ត ? ការងារនៅពេលបន្ទាប់ទៀត មានភាពជាក់លាក់ពេញលេញល្អ ឆ្លើយតបនឹងវត្ថុបំណងរបស់មេរៀននីមួយៗ ហើយធ្វើឱ្យលទ្ធផលសិក្សារបស់កុមារកាន់តែប្រសើរឡើង។

ក្រៅពីធ្វើស្វ័យវាយតម្លៃលើខ្លួនឯង គ្រូបង្រៀនក៏ត្រូវទទួលការវាយតម្លៃឬជួយកែលម្អពីគ្រូដូចគ្នាផ្សេងទៀត និងនាយកឬនាយិកាដែរ។ ការឆ្លុះបញ្ចាំលើខ្លួនឯងពិតណាស់ថា វាមិនគ្រាប់ជ្រុងជ្រោយទេ គឺទាមទរអ្នកដទៃជួយផ្ដល់ការកែលម្អបន្ថែម ព្រោះអ្នកផ្សេងទៀតអាចមើលឃើញនិងជួយនូវអ្វីដែលគ្រូខ្លួនឯង មិនបានមើលឃើញ។ ការធ្វើដូច្នេះវានឹងនាំឱ្យគ្រូម្នាក់ៗ បានអភិវឌ្ឍនូវចំណេះដឹងឬសមត្ថភាពកាន់តែប្រសើរឡើង លើភាសាខ្មែរ។

### ៥.២.ចំពោះកុមារ

ជាទូទៅការតាមដាននិងវាយតម្លៃមានច្រើនបែប និងមានគោលបំណងផ្សេងៗគ្នា។ ប៉ុន្តែការពិនិត្យតាមដាននិងវាយតម្លៃ ក្នុងការណែនាំនេះ មានគោលបំណង៖

វាស់វែងស្វែងរកនូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ដែលកុមារទទួលបាន និងអាចធ្វើបាន គ្រូត្រូវធ្វើការវាយតម្លៃសិស្សជាប្រចាំ តាមរយៈការបង្រៀនមេរៀននីមួយៗរបស់ខ្លួន និងត្រូវធ្វើការវាយតម្លៃ តាម រយៈតេស្តប្រចាំត្រីមាសផងដែរ។ ការបង្រៀន ល្បែងបុរេសំណេរ ការស្គាល់(បីដំណាក់កាល) អក្សរ រឿងនិទាន និងកំណាព្យ ត្រូវធ្វើការវាយតម្លៃចំណេះដឹងកុមារ តាមមេរៀននីមួយៗដូចគ្នា តាមរបៀបដូចដែលបានរៀបរាប់ខាងលើនេះ និងស្វែងរកកុមារដែលរៀនយឺត ដើម្បីរកវិធីជួយដល់ពួកគេបន្ថែម។

## ការវាយតម្លៃលទ្ធផលសិក្សារបស់កុមារ
## លើមេរៀនការសម្គាល់អក្សរ "ក "

តើរូបភាពណាខ្លះ មានឈ្មោះដែលផ្ដើមឡើងជាមួយអក្សរ"ក"

     

ការសម្គាល់សូរអក្សរ "ក"

| ចាប់ផ្ដើមឡើងជាមួយអក្សរ "ក" | មិនចាប់ផ្ដើមឡើងជាមួយអក្សរ "ក" ទេ |
|---|---|
|    |    |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ឧបសម្ព័ន្ធទី១- ផ្នែកខ្លឹមសារ នៃសកម្មភាពគោល

### ១- មុនសំណេរ

នៅពេលកុមារធ្វើការស្វែងរិះរកនិងពិសោធន៍ លើការសរសេរ ពួកគេបានធ្វើឱ្យមានការផ្លាស់ប្តូរពីទម្រង់ នៃការសរសេរមិនសូវល្អ ឱ្យទៅជាទម្រង់ល្អប្រសើរ ។ ប្រភេទនៃការសរសេរនេះមាន៦ប្រភេទ (Sulzby, ១៩៩០) កុមារតែងតែបញ្ចូលគ្នា នូវប្រភេទផ្សេងៗនៃការសរសេរ ដើម្បីតំណាងឱ្យគំនិតរបស់ពួកគេ និងជាការសម្តែងដោយផ្ទាល់ខ្លួនរបស់ពួកគេផងដែរ។ តារាងខាងក្រោមនេះ បង្ហាញពីការសរសេរចំនួន៦ប្រភេទ៖

| ប្រភេទ | ការពណ៌នា | រូបតំណាង |
|---|---|---|
| ១.ការគូរ (drawing) | កុមារគូរភាព តំណាងឱ្យគំនិតរបស់ខ្លួន។ គេអានគំនូររបស់ពួកគេ ដូចជាមានសំ-ណេរនៅលើរូបភាពនោះដូច្នោះដែរ។ |  |
| ២.ការគូសវាស (Scribbing) | កុមារប្រែយល់ដឹងថាការសរសេរ គឺខុសប្លែកពីការគូរ។ ពួកគេមានការអភិវឌ្ឍលើចលករតូច តាមការចាប់ផ្តើមគូសវាស រួចឆ្ពោះទៅរកការសរសេរ។ |  |
| ៣.ទម្រង់អក្សរ និងនិមិត្តសញ្ញា (Letter-like forms and symbols) | កុមារចាប់ផ្តើមកត់សម្គាល់តួអក្សរ និងដឹងពីភាពខុសប្លែកគ្នានៃរូបរាង (ឧ.គំនូសបន្ទាត់ គំនូសកាច់បត់បែនក្ងិកក្ងក់ គំនូសបិទជិតជារង្វង់)ដែលបង្កើតបានតួជាអក្សរ។ ការសរសេររបស់ពួកគេ ចាប់ផ្តើមឈានឆ្ពោះទៅដូចតួអក្សរនានា និងនិមិត្តសញ្ញាផ្សេងៗ ដែលបែកចេញពីក្នុងចំណោមគំនូរនិងការគូសវាសនានារបស់ពួកគេ។ |  |

| | | |
|---|---|---|
| ៤. ការដេរដោតអក្សរ (letter strings) | កុមារប្រើអក្សរបន្តគ្នា(ឧ.អក្សរនានាដែលជាឈ្មោះរបស់ពួកគេ ឬដេរដោតលើអក្សរទាំងនោះ) ក្នុងការសរសេររបស់ពួកគេ។ ពួកគេអាចផ្គុំអក្សរបានជាពាក្យត្រឹមត្រូវ ឬមិនត្រឹមត្រូវជាដើម។ |  |
| ៥.ការសរសេរដោយច្នៃប្រឌិត (Writing with invented spelling) | កុមារចាប់ផ្ដើមស្រាវជ្រាវរក ពាក្យនិយាយដែលបង្កើតឡើងមានសូរសំឡេង វាមានការពាក់ព័ន្ធទៅនឹងអក្សរនានា ជាមួយពាក្យដែលបានសរសេរក្នុងអត្ថបទ។ ពួកគេអាចច្នៃប្រឌិតប្រើអក្សរ ដើម្បីប្រកបបង្ហាញសូរសំឡេងដែលគេបានឮជាមួយពាក្យផ្សេងៗ។ |  |
| ៦.ការសរសេរដោយសន្ទត់ (Writing with conventional spelling) | កុមារមានការរីកចម្រើនពីការបង្ហាញសូរសំខាន់មួយក្នុងពាក្យ ដែលគេបានឮ(សូរបញ្ចប់នៃព្យញ្ជនៈឬស្រៈ)។ ការសរសេររបស់ពួកគេវាប្រហាក់ប្រហែលនឹងមនុស្សធំដែរ។ |  |

**១.សមត្ថភាពសង្កេត** គឺជាសមត្ថភាពចេះកំណត់សម្គាល់ព័ត៌មានទាំងឡាយ ដោយចក្ខុវិញ្ញាណធ្វើការវិភាគស្គាល់ភាពខុសគ្នា និងភាពស្រដៀងគ្នា រាងរូបរាង មាឌ ឬពណ៌និងវត្ថុនានា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# លំហាត់សង្ខេប

❖ **ថ្នាក់កម្រិតទាប**

១.បង្ហាញរូបភាពចំពោះកុមារនិងណែនាំគេឱ្យពិនិត្យរាងធរណីមាត្រជាមូលដ្ឋានផ្សេងៗដូចជារាងរង្វង់ត្រីកោណការេ។

២.រៀបរាប់វត្ថុឬសត្វផ្សេងៗនៅជុំវិញខ្លួនត្រឹម៣៤(សកម្មភាពនេះអាចលេងជាមួយនឹងពណ៌ផ្សេងៗក៏បានដែរ)។

៣.ល្បែងជ្រើសរើសរាងពណ៌ទំហំ។

៤.ពង្រាយប្រអប់ និងគម្របដែលមានទំហំខុសៗគ្នានៅលើតុហើយឱ្យកុមាររកគម្របឱ្យត្រូវនឹងប្រអប់នីមួយៗ។

៥.កុមារម្នាក់ធ្វើត្រាប់តាមសត្វអ្វីមួយ។កុមារដទៃទៀតរកនឹកមើលថាតើកុមារនោះធ្វើត្រាប់សត្វអ្វី។

៦.ល្បែងផ្គុំរូប។

❖ **ថ្នាក់កម្រិតមធ្យម**

១.បង្ហាញរូបភាពចំពោះកុមារនិងណែនាំគេឱ្យពិនិត្យរាងធរណីមាត្រជាមូលដ្ឋានផ្សេងៗដូចជារាងរង្វង់ ត្រីកោណ ចតុកោណ ការេ ចតុកោណកែង។

២.រៀបរាប់ឈ្មោះវត្ថុឬសត្វផ្សេងៗនៅជុំវិញខ្លួនត្រឹម៥៦ (សកម្មភាពនេះអាចលេងជាមួយនឹងពណ៌ផ្សេងៗក៏បានដែរ)។

៣.កុមារ៣នាក់ឈរនៅក្នុងស្ថានភាពដូចគ្នាដោយមានកាន់វត្ថុ (ប៊ិចខ្មៅដៃកាទឹក...) ហើយកុមារដទៃទៀតត្រូវពិនិត្យមើលតើអ្នកណាដែលមានស្ថានភាពខុសគេ

៤.កុមារម្នាក់ បង្ហាញខ្លួនចំពោះមុខកុមារដទៃទៀតដែលត្រូវសង្កេតយ៉ាងយកចិត្តទុកដាក់ចំពោះកុមារនោះ។ កុមារដដែលដកខ្លួនទៅកន្លែងស្ងាត់ហើយប្តូរវត្ថុអ្វីមួយដែលមាននៅលើខ្លួនគេរួចត្រឡប់មកវិញ។ កុមារដទៃទៀតត្រូវសង្កេតមើលតើអ្វីខ្លះបានផ្លាស់ប្តូរនៅលើខ្លួនរបស់កុមារនោះ។

៥.គ្រូដាក់វត្ថុផ្សេងៗនៅលើតុ។ កុមារសង្កេតមើលវត្ថុទាំងនោះយ៉ាងយកចិត្តទុកដាក់។ កុមារចេញទៅខាងក្រៅថ្នាក់ ឬឱ្យកុមារបិទភ្នែក ហើយគ្រូដក ឬប្តូរទីកន្លែងវត្ថុណាមួយនៅលើតុនោះ។ កុមារចូលមកវិញ ហើយពិនិត្យមើលថាតើបាត់អ្វី ឬមានវត្ថុណាដែលត្រូវបានគេផ្លាស់ប្តូរទីកន្លែង។

៦.គ្រូបង្ហាញផ្ទាំងគំនូរដែលមានរូបវត្ថុផ្សេងៗ ចំពោះកុមារក្នុងរយៈពេល៣០វិនាទី រួចគ្រូលាក់ ឬបិទរូបនោះទុកហើយសួរឱ្យកុមាររៀបរាប់វត្ថុដែលគេបានឃើញនៅលើផ្ទាំងគំនូរនោះ។

៧.ឱ្យកុមារមើលណិងប្រៀបធៀបគំនូរពីរដែលខុសគ្នានៅត្រង់ចំណុចណាមួយឬច្រើនចំណុច។ (រូបភាពទំព័រទី១២)

៨. ល្បែងជ្រើសរើសរាងពណ៌ទំហំ។

៩. ល្បែងគ្រាប់តាមកុមារមើលហើយធ្វើកាយវិការឱ្យដូចអ្នកដែលបញ្ជាភ្លេង។

១០.កុមារទាំងអស់អង្គុយរាយពាសពេញថ្នាក់ហើយបិទភ្នែកកុំឱ្យមើលឃើញ។ ដកកុមារម្នាក់ចេញហើយស្រាយមុខកុមារដទៃទៀតនិងឱ្យរកមើលតើបាត់កុមារណា។

១១.ដាក់វត្ថុផ្សេងៗដែលមានទំនាក់ទំនងគ្នានៅលើតុហើយដាក់វត្ថុមួយទៀតដែលគ្មានទំនាក់ទំនងជាមួយវត្ថុទាំងនោះរួចឱ្យកុមាររកមើលវត្ថុដែលគ្មានទំនាក់ទំនង។

១២.បង្ហាញរូបដែលខុសប្លែកពីធម្មតាចំពោះកុមារហើយឱ្យគេរកមើលចំណុចដែលខុសប្លែកនោះ។

១៣. ល្បែងផ្គុំរូប។

❖ **ថ្នាក់កម្រិតខ្ពស់**

១.បង្ហាញផ្នែកខ្លះនៃវត្ថុ ហើយសួរកុមារថាតើជារូបអ្វី? គេអាចបង្ហាញរូបគំនូរដែលនៅខ្វះខាតចំណែកខ្លះៗហើយសួរឱ្យកុមារឆ្លើយថារូបនោះខ្វះអ្វី?

| ពង្រីកសមត្ថភាពសង្កេត | |
|---|---|
| ក្នុងរូបគំនូរនេះ មាន៥ ចំណុចខុសៗគ្នា | ចូរបំពេញ ឬដកចំណុចរូបនេះ ដើម្បីបានដូចរូបខាងឆ្វេង |
|  |  |
|  |  |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

២.សមត្ថភាពស្តាប់ គឺជាការណែនាំឱ្យចេះស្តាប់សម្គាល់សូរសំឡេងខុសគ្នាដែលកើតឡើងក្នុងបរិស្ថាន សូរខុសគ្នារវាងសូរសំឡេងនៃភាសា។

- ណែនាំកុមារសម្គាល់សូរខុសគ្នារវាងព្យញ្ជនៈ២។ គ្រូបញ្ចេញសូរព្យញ្ជនៈ២ដែលប្រហាក់ប្រហែលគ្នាហើយឱ្យកុមារថាតាម។
- ភាពប្លែកគ្នានៃសូរស្រដៀងគ្នាស្ថិតក្នុងពាក្យ។
  ឧទាហរណ៍៖គ្រូនិយាយពាក្យជាច្រើនដែលមានអក្សរ ច ឬឆ។ កុមារត្រូវដឹងថាអក្សរពីរនេះអក្សរណាមួយដែលមានក្នុងពាក្យដែលគ្រូនិយាយ៖
  ឧទាហរណ៍៖
  - ដោយបង្ហាញតួអក្សរ។
  - ដោយហៅឈ្មោះតួអក្សរ។
  - ដោយទះដៃតំណាងតួអក្សរ «ច»។
  - ដោយទន្ត្រំជើងតំណាងតួអក្សរ «ឆ»។
- គ្រូនិទានរឿងខ្លីមួយឱ្យកុមារស្តាប់ដោយប្រើជាញឹកញាប់ព្យញ្ជនៈមួយ។គ្រប់ពេលដែលកុមារឮសូរព្យញ្ជនៈនោះកុមារត្រូវធ្វើកាយវិការអ្វីមួយតាមគ្រូកំណត់។
- កុមារពាក់ស្លាកតួអក្សរមួយម្នាក់។កាលណាឮគ្រូហៅចំតួអក្សរដែលខ្លួនពាក់កុមារត្រូវ

**លំហាត់ញែកសូរក្នុងភាសា**

ណែនាំកុមារដៅរកកន្លែងសំឡេងមួយស្ថិតនៅក្នុងពាក្យ៖

**ឧទាហរណ៍៖** 



| ខ្ញុំឮសូរខ្យល់តួអក្សរនៅដើមពាក្យ | សូរខ្យល់តួអក្សរនៅកណ្តាលពាក្យ | សូរខ្យល់តួអក្សរនៅចុងពាក្យ |
| --- | --- | --- |

**ឧទាហរណ៍៖** សំបក ត្រសក់ផ្អ សំពត់ស

ឱ្យកុមារគូសខ្វែងនៅលើរូបណាដែលមានសូរ "អី" នៅចុង

ស្រដៀងនឹងពាក្យ៖ បារី





## ការស្តាប់ និងការសង្កេត

គ្រូចាប់ផ្តើមបង្រៀនដោយបង្ហាញរូបភាពងាយៗ។ គ្រូបង្ហាញរូបភាពងាយស្រួលតែម្តង ឯកុមារក៏មិនមានការងឿងឆ្ងល់ដែរ។ គ្រូបង្កើតល្បែងផ្សេងៗ ដូចជា ការបង្ហាញរូបភាពមួយចំពោះតែកុមារម្នាក់ មិនបង្ហាញចំពោះកុមារទាំងអស់នោះទេ។ កុមារម្នាក់នោះខ្សឹបប្រាប់បន្តទៅមិត្តភក្តិដទៃទៀត។ បន្ទាប់មកគ្រូបញ្ឈប់ត្រឹមកុមារទី៥ ដោយឱ្យគេថាឃ្លានោះ ជាមួយសំឡេងខ្លាំងៗ។ កុមារបញ្ជាក់ឃ្លាតាមរូបភាព រួចគ្រូអាននិងបង្ហាញរូបភាពផ្សេងទៀត។ ឧទាហរណ៍៖ តួអក្សរ **ត** ។ គ្រូអាចរករូបភាពផ្សេងៗដែលអាចរកបាន។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ល្បែងខ្សឹបៈ កុមារឈរតម្រៀបគ្នាជាពាក់កណ្ដាលរង្វង់។ គ្រូនិយាយខ្សឹបពាក្យអ្វីមួយ ឧទាហរណ៍ "ពណ៌ស" ។ កុមារថាតាមពាក្យដែលគ្រូបានខ្សឹប។ នៅពេលខ្លះកុមារអាចធ្វើជំនួសគ្រូ។

គេអាចយកឧទាហរណ៍ផ្សេងទៀតដោយប្រើចំនួន ៣ , ០ , ៦ , ១ , ៤ , ៥ ។

៧ , ៨ , ៩ , ២ ។៧ , ១ , ៥ , ៤ , ៨ ។ ៦ , ៥ , ៨ , ៣ , ៩ ។

ម្យ៉ាងទៀត គេអាចប្រើឃ្លាខ្លីៗ «ក្រោកឈរឡើង» «ទៅបើកបង្អួច» «យកសៀវភៅ» «ទៅរកសៀវភៅ»



**ការស្តាប់ និងការសង្កេត**

គ្រូចាប់ផ្តើមបង្រៀនដោយបង្ហាញរូបភាពងាយៗ។ គ្រូបង្ហាញរូបភាពងាយស្រួលតែម្តង ឯកុមារក៏មិនមានការងឿងឆ្ងល់ដែរ។ គ្រូបង្កើតល្បែងផ្សេងៗ ដូចជា ការបង្ហាញរូបភាពមួយចំពោះតែកុមារម្នាក់ មិនបង្ហាញចំពោះកុមារទាំងអស់នោះទេ។ កុមារម្នាក់នោះខ្សឹបប្រាប់បន្តទៅមិត្តភក្តិដទៃទៀត។ បន្ទាប់មកគ្រូបញ្ឈប់ត្រឹមកុមារទី៥ ដោយឱ្យគេថាឃ្លានោះ ជាមួយសំឡេងខ្លាំងៗ។ កុមារបញ្ជាក់ឃ្លាតាមរូបភាព រួចគ្រូអាននិងបង្ហាញរូបភាពផ្សេងទៀត។ ឧទាហរណ៍: តួអក្សរ **ត** ។ គ្រូអាចរករូបភាពផ្សេងៗដែលអាចរកបាន។

| | |
|---|---|
|  តោលើតុ |  តោក្នុងតៅ |
|  តោក្នុងប៉ាន់តែ |  ប៉ាន់តែក្នុងតៅ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## លក្ខណៈពិសេសនៃសំឡេងជាមួយសញ្ញា

បង្ហាញកាយវិការជាឧទាហរណ៍ ឱ្យកុមារសង្កេតពិនិត្យនិងសម្គាល់ ដែលធ្វើឱ្យកុមារអាចឆ្លើយតបតាមសញ្ញានោះ។ ជាមួយគ្នានេះដែរ កុមារអាចប្រើប្រាស់លក្ខណៈពិសេសទាំងនោះ ដើម្បីកម្តៅសំឡេងរបស់ពួកគេ។

(គេអាចប្រើសំឡេងព្យ៉ាណូ)

| | សញ្ញានៅលើក្តារខៀន | សញ្ញាក្នុងលំហ (កាយវិការមានទំនាក់ទំនងតាមសញ្ញា) |
|---|---|---|
| ទំហំ |  សំឡេងខ្សឹប សំឡេងធម្មតា សំឡេងធំ |  ដោយប្រើដៃពីរ គ្រូធ្វើរាងមូលតូច គឺជាសញ្ញាខ្សឹប។ សំឡេងខ្លាំងបន្តិច គ្រូទាញដៃឃ្លាតចេញពីគ្នាបន្តិច។ សំឡេងធំ ទាញដៃឱ្យអស់តែម្តង។ |
| រយៈពេល | សំឡេងខ្លីបំផុត សំឡេងរយៈពេល២វិនាទី សំឡេងរយៈពេលច្រើនវិនាទី | គ្រូធ្វើចលនាដៃដូចជាសរសេរៈ<br>- ចំណុចមួយសម្រាប់សំឡេងខ្លី<br>- បន្ទាត់ខ្លីពីរសម្រាប់សំឡេង ២នាទី<br>- បន្ទាត់វែង សម្រាប់សំឡេងច្រើននាទី |
| កម្ពស់ |  សំឡេងគ្រលួច<br>សំឡេងធម្មតា<br>សំឡេងគ្រលរ | គ្រូលើកដៃឡើងលើ និងដាក់ដៃមកក្រោម។<br>- ដៃចុះក្រោម៖សំឡេងគ្រលរ<br>- គ្រូដាក់ដៃត្រង់ទៅមុខ៖ សំឡេងធម្មតា<br>- ដៃគ្រូឡើងលើ៖ សំឡេងគ្រលួច |

## លំហាត់ស្ដាប់

- **ថ្នាក់កម្រិតទាប**

១.គ្រូទម្លាក់វត្ថុផ្សេងៗ(សៀវភៅខ្មៅដៃដីស...) ទៅលើឥដ្ឋឱ្យកុមារមើលនិងស្ដាប់។ឱ្យកុមារបិទភ្នែកហើយទាយវត្ថុដែលគ្រូទម្លាក់ចុះ។

២.បង្ហាញរូបឱ្យកុមារចង្អុលនៅពេលដែលឮគ្រូហៅឈ្មោះវា។

- **ថ្នាក់កម្រិតមធ្យម**

១.កុមារត្រូវសម្គាល់សំឡេងផ្សេងៗនៅជុំវិញខ្លួន (សំរែកសត្វសូរវត្ថុនានានៅក្នុងបរិស្ថាន។ ឧទាហរណ៍៖សូរហែកក្រដាសសូរចាក់ទឹកសូរខាំករកេរផ្លែឈើសូរកូនសោរប៉ះគ្នា...)។

២.កុមារដែលបិទភ្នែករួចអាចរៀបរាប់អំពីសំឡេងដែលគេបានឮនៅក្នុងថ្នាក់រៀនក្នុងទីធ្លា...។

៣.កុមារទាំងអស់អង្គុយបែរខ្នងមករកគ្រូដែលទម្លាក់គ្រួសម្ដងមួយៗចូលទៅក្នុងប្រអប់មួយ។ ដុំគ្រួសធ្លាក់មួយពីរបី... កុមារត្រូវផ្ទៀងផ្ទាត់ស្ដាប់សំឡេងដុំគ្រួសធ្លាក់និងឆ្លើយចំនួនដុំគ្រួសដែលគ្រូបានទម្លាក់ចុះ។

៤.ខ្សឹបពាក្យមួយឬឃ្លាមួយដាក់ត្រចៀកកុមារម្នាក់។ ឱ្យគេខ្សឹបបន្តគ្នាម្ដងម្នាក់រហូតដល់ចុងបញ្ចប់ឱ្យថាតាមពាក្យនោះឡើងវិញ។

៥.គ្រូបង្កើតរឿងនិទានខ្លីមួយដោយប្រើពាក្យងាយៗហើយច្បាស់លាស់។ ឧទាហរណ៍៖ ពណ៌ក្រហមពណ៌បៃតង។ នៅពេលដែលគ្រូប្រើពាក្យណាមួយកុមារទាំងអស់ត្រូវធ្វើកាយវិការសមស្របទៅនឹងពាក្យនោះ។ ឧទាហរណ៍៖ ក្នុងរឿងនិទានកុមារឮពាក្យ«ក្រហម» កុមារទះដៃ។ ប្រសិនបើកុមារឮពាក្យថា«បៃតង» កុមារទន្ទ្រំជើង។

**រឿងនិទាន៖** កុមារីម្នាក់ពាក់មួកក្រហមធ្វើដំណើរក្នុងព្រៃដែលមានស្លឹកឈើពណ៌លឿងនិងពណ៌បៃតងដៃនាងស្រវាប្រមូលបេះយកផ្កាពណ៌ក្រហម។ នៅលើផ្លូវនាងជួបសត្វកង្កែបមួយពណ៌សូកូឡាមានភ្នែកក្រហមពាំគ្រាប់សណ្ដែកពណ៌បៃតងជាច្រើន។ កុមារីឃើញភ្ញាក់ព្រើតធ្លាក់មួកក្រហមពីលើក្បាលទៅលើស្មៅពណ៌បៃតង។ ក្នុងឆាកជីវិតរបស់នាងនាងពុំដែលជួបប្រទះកង្កែបពណ៌សូកូឡាពាំគ្រាប់សណ្ដែកបៃតងនេះសោះ។

១. ចងភ្នែកដោយក្រមាកុមារមួយចំនួន។ លាក់នាឡិកាពេទីនៅកន្លែងណាមួយហើយឱ្យកុមារទាំងនោះដើររកនាឡិកាដែលកំពុងរោទិ៍(សំឡេងក្រឡុកគ្រាប់គ្រួសដុំថ្មតូចៗកញ្ចែ...)។

២. កុមារឈរជារង្វង់គ្រូគោះស្គរធុងកំប៉ុងជាចង្វាក់(យឺតយឺតខ្លាំងញាប់ញាប់ខ្លាំង)។ បន្ទាប់ពីបានស្ដាប់ហើយកុមារបន្លឺសំឡេងដោយទះដៃតាមចង្វាក់។

៣.គ្រូឱ្យសញ្ញាបីដល់កុមារ៖

- ទះដៃម្ដងសម្គាល់ថាដើរ
- ទះដៃ២ដងសម្គាល់ថារត់
- ទះដៃ៣ដងសម្គាល់ថាលោតជើង១

**(គ្រូអាចរកសញ្ញាផ្សេងៗទៀត)**

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

❖ **ថ្នាក់កម្រិតខ្ពស់**

១. ណែនាំកុមារឱ្យចាប់អារម្មណ៍នឹងសូរស្រដៀងគ្នានៃពាក្យ។ គ្រូបន្លឺពាក្យដែលស្រដៀងគ្នាហើយឱ្យកុមារថាតាម។ឧទាហរណ៍៖ឆ្មាស្មាស្និតផ្និតរងាររងាវ ...។

២. យកកែវ៤ឬ៥មកចាក់ទឹកចូលក្នុងកម្ពស់មិនស្មើគ្នា។ យកវត្ថុអ្វីមួយមកគោះកែវទាំងនោះនិងណែនាំកុមារឱ្យកត់សម្គាល់សូរខុសគ្នានៃកែវនីមួយៗ។ ឱ្យកុមារគោះកែវរកសំឡេងមានសូរស្រាលស្រួយសូរធ្ងន់...។ បន្ទាប់មកឱ្យកុមារបិទភ្នែករួចគ្រូគោះកែវ ហើយឱ្យកុមារឆ្លើយថាសំឡេងនេះចេញពីកែវមួយណា។

៣. ឱ្យកុមារទាំងអស់បិទភ្នែកហើយត្រូវចង្អុលទីកន្លែងដែលគេបានឮសូរសំឡេង។ គ្រូចាប់ផ្ដើមដោយហៅឈ្មោះកុមារនោះពីទីកន្លែងខុសគ្នានៅក្នុងថ្នាក់មិនត្រូវធ្វើឱ្យឮសម្រឹបអ្វីឡើយនៅពេលផ្លាស់ប្ដូរទីកន្លែង។ កុមារចង្អុលបន្ទាប់មកគ្រូឱ្យកុមារបើកភ្នែកមើលដើម្បីគេអាចដឹងថាគ្រូឈរនៅកន្លែងណា។ ជាបន្តបន្ទាប់គ្រូអាចប្រើសូរដែលកុមារធ្លាប់ស្គាល់ហើយដូចជាសូរជួង... ហើយនៅចុងបញ្ចប់អាចប្រើសូរច្រើនរួមគ្នាក្នុងពេលតែមួយ។

៤. ធ្វើសំឡេងសត្វស្រុកនានាឱ្យកុមារស្ដាប់។ ដោយប្រើរូបភាពគ្រូឱ្យកុមាររកមើលរូបសត្វណាដែលគេបានឮនូវសំឡេងរបស់វា។

៥. រកពាក្យណាដែលខាងចុងមានសូរសំឡេងដូចគ្នា។ ឧទាហរណ៍៖សម្លអង្ករសរសេរបេរ។ល។

៦. កុមារទាំងអស់ឈរជារង្វង់ហើយម្នាក់ៗជ្រើសរើសឈ្មោះបន្លែមួយមុខ។ អ្នកដឹកនាំល្បែងហៅឈ្មោះបន្លែមួយមុខ។ កុមារណាដែលមានឈ្មោះដូចដែលគេបានហៅត្រូវអង្គុយចុះភ្លាម។ បើកុមារភ្លេចខ្លួន មិនបានអង្គុយចុះ ត្រូវទៅឈរនៅកណ្ដាលរង្វង់(ធ្វើជាឆ្នាំងសម្ល)។

៧. កុមារធ្វើតាមបញ្ជារបស់គ្រូ នៅពេលដែលគាត់និយាយឃ្លាមួយ។ ឧទាហរណ៍៖ដើរទៅមុខពីរជំហាន

៨. កុមារអង្គុយជារង្វង់គ្រូចាប់ផ្ដើម «ខ្ញុំទៅផ្សារទិញការ៉ុត»។ កុមារនិយាយម្ដងម្នាក់ៗដោយថាតាមឃ្លាដដែលនិងបន្ថែមឈ្មោះបន្លែមួយមុខទៀត «ខ្ញុំទៅផ្សារទិញការ៉ុតសាឡាដ» កុមារបន្ទាប់និយាយបន្ត៖ «ខ្ញុំទៅផ្សារទិញការ៉ុតសាលាដម្ទេស...»។

៩. រៀបកុមារជាពីរក្រុម អង្គុយទល់ខ្នងគ្នា កុមារម្នាក់និយាយ ហើយកុមារមួយក្រុមទៀតត្រូវទាយសំឡេងកុមារនោះ។

១០. គ្រូបង្កើតឃ្លាជាបទចម្រៀងខ្លីៗឱ្យបានច្រើន។

១១. បន្លឺចង្វាក់ដោយទះដៃនិងដោយប្រើចង្វាក់ប្លែកៗ។

១២. នៅពេលច្រៀងកុំបន្លឺពាក្យហើយត្រូវច្រៀងតាមតែបទចម្រៀងនោះ

១៣. នៅពេលច្រៀងកុំបន្លឺពាក្យហើយត្រូវច្រៀងតាមបទចម្រៀងនោះ

- ច្រៀងតិច ច្រៀងខ្លាំង
- ច្រៀងយឺត ច្រៀងលឿន
- ច្រៀងដោយបន្លឺថា «ឡាឡា»... ។ល។
- ច្រៀងសំឡេងធំ ច្រៀងសំឡេងតូចស្រួយ។

**៣.សមត្ថភាពចលនា** គឺជាការប្រើប្រាស់បំណិនលំនឹងការសម្របសម្រួលទំនាក់ទំនងក្នុងការធ្វើចលនារាងកាយ ឬចលនាម្រាមដៃ។ បើកុមារមានកាយវិការស្ទាត់ជំនាញច្បាស់លាស់ក្នុងការធ្វើចលនារបស់គេ ព្រមទាំងមាន ទំនាក់ទំនងបានប្រសើរ វានឹងងាយស្រួលដល់ការសរសេរ នៅឆ្នាំទីមួយនៃបឋមសិក្សា។ នៅមត្តេយ្យសិក្សាគ្រូណែនាំកុមារឱ្យអភិវឌ្ឍសមត្ថភាពនៃចលនា ដូចជា ទំនាក់ទំនងរវាងភ្នែកនិងដៃ។ មិនមែនដោយសារតែការមើលទេ ដែលធ្វើឱ្យភាពម្ចាស់ការ និងភាពទន់ភ្លន់របស់កុមាររីកចំរើនឡើង។ ចំពោះចលនារាងកាយ និងចលនាដៃ កុមារត្រូវតែជាអ្នកសំដែងដោយខ្លួនឯងមិនមែនជាអ្នកទស្សនាទេ។

## លំហាត់ចលនាដៃ

❖ **កម្រិតទាប**

១.សិប្បកម្ម៖

- ធ្វើរាងមូលវែងដោយដៃម្ខាង។
- ធ្វើរាងវែងដោយដៃទាំងពីរ។
- កុមារប្រើម្រាមដៃលញ់ដីឥដ្ឋដោយមិនឱ្យប្រើបាតដៃទេ។
- លញ់ដីឥដ្ឋជារាងមូលដោយដៃទាំងពីរ។
- លញ់ប្រមៀលដីឥដ្ឋរហូតដល់ចុងម្រាមដៃ។
- កាន់លញ់ដីឥដ្ឋដោយប្រើមេដៃនិងចង្អុលដៃ។មេដៃនិងម្រាមកណ្ដាលមេដៃនិងនាងដៃមេដៃនិងកូនដៃ។
- លាយច្របាច់ដីឥដ្ឋដោយប្រើដៃម្ខាង។
- លញ់ដីដោយដៃម្ខាងនិងប្រើចលនាម្រាមដៃ។

២.បោះបាល់ពីដៃមួយទៅដៃមួយទៀត។

៣.កុមារទាំងអស់មានកែវមួយម្នាក់ហើយគ្រូដាក់សណ្ដែកអង្ករពោត ឬស្រូវ នៅពីមុខគេ។ គ្រូកំណត់ពេលហើយ ឱ្យកុមាររើសគ្រាប់ពោត ឬគ្រប់សណ្ដែក នោះដាក់ចូលក្នុងកែវរៀងៗខ្លួន។ អ្នកឈ្នះគឺជាអ្នកដែលដាក់គ្រាប់ពោត ឬគ្រាប់សណ្ដែកក្ន ងកែវបានច្រើនជាងគេ។

៤. ល្បែងចលនាដៃទាំងអស់ (មើលឯកសារចលនាម្រាមដៃ)។

❖ **ថ្នាក់កម្រិតមធ្យម**

១. សិប្បកម្ម៖

- ធ្វើរាងមូលវែងដោយដៃម្ខាង។
- ធ្វើរាងមូលវែងដោយដៃទាំងពីរ។
- កុមារប្រើម្រាមដៃលញ់ដីឥដ្ឋដោយមិនឱ្យប្រើបាតដៃទេ។
- លញ់ដីឥដ្ឋជារាងមូលនៅលើតុដោយប្រើបាតដៃ។
- លញ់ដីឥដ្ឋជារាងមូលដោយដៃទាំងពីរ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- លញ់ប្រមៀលដីឥដ្ឋរហូតដល់ចុងម្រាមដៃ។
- កាន់លញ់ដីឥដ្ឋដោយប្រើមេដៃនិងចង្អុលដៃ។មេដៃនិងម្រាមកណ្ដាលមេដៃនិងនាងដៃមេដៃនិងកូនដៃ។
- លាយច្របាច់ដីឥដ្ឋដោយប្រើដៃម្ខាង។
- លញ់ដីដោយដៃម្ខាងនិងប្រើចលនាម្រាមដៃ។

២. កុមារធ្វើខ្សែកដោយដោតអង្កាំឡេវអាវវត្ថុផ្សេងៗ...។

៣. សកម្មភាពប្រចាំថ្ងៃជាច្រើនអាចផ្ដល់ឱកាសដល់ការធ្វើចលនាម្រាមដៃ៖ស្លៀកពាក់បិទឡេវចងដោត... រៀបចំតុចាក់ទឹក ....។

៤. ល្បែងសាងសង់ (សង់ផ្ទះសង់ប្រាសាទដោយប្រើដុំឈើដុំឥដ្ឋសំបកកំប៉ុង...)។

៥. ល្បែងបោះនិងចាប់បាល់។

៦.រៀបឱ្យកុមារឈរឆ្ងាយបន្តិចពីកៅអីដែលដាក់ផ្ងារជើងឡើងលើ។ កុមារត្រូវបោះកងបញ្ចូលក្នុងជើងកៅអីនោះ។

៧. រៀបឱ្យកុមារឈរឆ្ងាយបន្តិចពីកញ្ជើមួយហើយឱ្យកុមារបោះបាល់ចូលក្នុងកញ្ជើនោះ។

៨. រៀបចំកំប៉ុងទទេជារាងសាជី។ កុមារឈរឆ្ងាយបន្តិចហើយគប់នឹងបាល់ ដើម្បីធ្វើឱ្យកំប៉ុងនោះ រលំ។

៩. ល្បែងចលនាដៃទាំងអស់ (មើលឯកសារល្បែងចលនា)។

❖ **ថ្នាក់កម្រិតខ្ពស់**

១. យកចង្កឹះមួយចំនួនទម្លាក់ឬពង្រាយលើតុ។ កុមារសាកល្បងដកយកចង្កឹះម្ដងមួយៗដោយមិនធ្វើឱ្យរង្គើដទៃទៀត។

២. ល្បែងស្ទូចត្រីរៀបចំប្រអប់ឱ្យច្រើនជាងចំនួនកុមារ។ ដាក់ប្រអប់ទាំងនោះនៅចំកណ្ដាលរង្វង់មួយដែលគូរនៅលើដី។កុមារម្នាក់ៗអាចស្ទូចយកប្រអប់មួយដោយប្រើសន្ទូច។

៣. ល្បែងចលនាដៃទាំងអស់ (មើលឯកសារល្បែងចលនា)។

## លំហាត់ចលនាម្រាមដៃដែលទាក់ទងនឹងសំណេរ

**វត្ថុបំណង៖** នាំកុមារឱ្យរីចម្រើនលើសមត្ថភាពភ្នែក ដៃ ដើម្បីឱ្យគេអាចសរសេរអក្សរផ្សេងៗបាន។

១. សកម្មភាពគំនូស៖ ណែនាំកុមារឱ្យគូសបំពេញគំនូរ ។ចលនាដៃកុមារធ្វើនៅក្នុងគំនូរ ត្រូវមានទំនាក់ទំនងចាំបាច់ ទៅនឹងការសរសេរអក្សរណាមួយ។

២. ឱ្យកុមារគូស ឬសរសេរអក្សរនៅក្នុងលំហរ។

៣. កុមារប្រើម្រាមដៃគូសតាមរាងអក្សរដែលអ្នកគ្រូកាត់អំពីក្រណាត់។

៤. កុមារគូរតាមពីក្នុង ឬ ពីលើអក្សរគំរូ។

៥. កុមាររៀបអក្សរ ដោយគ្រាប់គ្រួស សំបកលៀស ឬងាវ ឬចង្កឹះ...។

ចូរគូសលំអសំបកខ្យងនេះ ដោយបន្ទាត់ស្ពីរ៉ាល់តាមពណ៌ដែលអ្នកជ្រើសរើស។



ចូរគូសលម្អសំបកខ្យងទាំងនេះ ដោយប្រើពណ៌ខុសៗគ្នា



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

៤.សមត្ថភាពភាសា គឺសំខាន់បំផុតក្នុងការរៀបចំកុមារឱ្យបានចូលរៀន។ គ្រូត្រូវជួយបង្កើតឃ្លាដោយភាសា ណែនាំកុមារពង្រីកពាក្យរបស់គេព្រមទាំងធ្វើឃ្លានឹងពាក្យឱ្យសមស្របតាមន័យផ្សេងៗគ្នា។ កុមារត្រូវបានលើកទឹកចិត្តបន្តិចម្តងៗ ក្នុងការតែងឃ្លាត្រឹមត្រូវ និងទំនាក់ទំនងយ៉ាងច្បាស់លាស់ទៅតាមសេចក្តីត្រូវការរបស់គេ។ កាលណាកុមារនិយាយមិនច្បាស់ គ្រូត្រូវឈរចំពោះមុខកុមារដោយបន្លឺសំឡេងមួយឱ្យច្បាស់ ឱ្យកុមារមើលមាត់គ្រូ និងនិយាយ តាម២ទៅ៣ដង និងឱ្យកុមារដទៃទៀតនិយាយបន្ទរ។

## លំហាត់សម្រាប់ពង្រីកភាសា

- **ថ្នាក់កម្រិតទាប**

១. ចម្រៀង៤ឃ្លា។

២. កំណាព្យ១ល្បះកាព្យ។

៣. រឿងនិទានខ្លីពាក្យងាយៗ។

៤. ល្បែងឡូតូរូបភាព (សម្ភារឬសត្វដែលកុមារឃើញរាល់ថ្ងៃ)។

- **ថ្នាក់កម្រិតមធ្យម**

១. ចម្រៀង៦ឃ្លា។

២. កំណាព្យ២ល្បះកាព្យ។

៣. រឿងនិទានខ្លីពាក្យងាយៗ។

៤. ល្បែងឡូតូ១២រូបភាព (សម្ភារឬសត្វដែលកុមារឃើញរាល់ថ្ងៃ)។

- **ថ្នាក់កម្រិតខ្ពស់**

១. ចម្រៀង៦ឃ្លាឡើង។

២. កំណាព្យ៣ល្បះកាព្យឡើង។

៣. រឿងនិទានវែងបន្តិចអាចមានតួអង្គលើសពីពីរ។

៤. ល្បែងឡូតូ១៦រូបភាព (សម្ភារបន្លែសត្វ...)។

៥. ល្បែងរកឈ្មោះសត្វបន្លែផ្លែឈើផ្កា...។ កុមារអង្គុយជារង្វង់គ្រូបោះកន្សែងឬបាល់មួយទៅលើកុមារហៅឈ្មោះសត្វម្នាក់មួយៗ។ កុមារត្រូវខិតខំរកនឹកឈ្មោះសត្វឱ្យបានលឿនមុនពេលកន្សែង ធ្លាក់ដល់ដី។គេអាចលេងល្បែងនេះដោយជ្រើសរើសយកឈ្មោះផ្លែឈើ បន្លែ ផ្កា ដើមឈើ...។

៦. ល្បែងពណ៌នារូបភាពដែលគេចាប់បាន។ បិតរូបសត្វដែលកុមារធ្លាប់ស្គាល់ច្បាស់នៅលើក្រដាសកាតុងង។ ផ្កាប់ក្រដាសរូបនោះ ហើយពង្រាយលើតុ។ កុមារម្នាក់ៗ ត្រូវចាប់យកក្រដាសរូបមួយ និង និយាយពីអ្វីដែលគេបានដឹង ហើយដែលទាក់ទងនឹងរូបនោះ (ពណ៌នាអំពីរូបដែលគេចាប់បាន)។ គ្រូត្រូវទុកឱ្យកុមារបញ្ចេញគំនិតនិយាយដោយខ្លួនគេ។ បើគេពុំឃើញអ្វីដែលគេត្រូវនិយាយនោះទេ គ្រូអាចបំផុសសំណួរដើម្បីជួយកុមារក្នុងការបញ្ចេញគំនិត។

**ឧទាហរណ៍៖**

- តើគេចិញ្ចឹមសត្វគោដោយសារអ្វី?
- តើវារស់នៅកន្លែងណា?
- តើវាមានជើងប៉ុន្មាន?
- តើសត្វគោមានស្លាបឬទេ?
- តើគោមានរោមឬទេ?

១. គ្រូនិយាយពាក្យ«ម៉ែ»។ កុមារត្រូវរកពាក្យណាដែលមានសំឡេង «ម»។

២. ការសម្តែងតួ ពាក់មុខ តុ្កត តុក្កតា។

៣. ណែនាំកុមារឱ្យចេះពិពណ៌នាអំពីតួអង្គ ឬវត្ថុនានាដែលអ្នកជទៃស្គាល់។

៤. ការមើលសៀវភៅដែលគ្រូឱ្យកុមារមើលទំព័រមួយទៅទំព័រមួយអាចឱ្យកុមារនិយាយរឿងដោយខ្លួនឯងជាបន្តបន្ទាប់។ គ្រូអាចអានបន្ត ឬមិនបាច់អាន។

៥. បង្កើតជារឿងតាមរយៈព្រឹត្តិការណ៍ គំនិត កុមារអាចគូរគំនូរ(គ្រូសរសេរជារឿង)។

៦. ផ្តល់ឱកាសឱ្យកុមារបានជជែកគ្នា ដើម្បីគេអាចនិយាយអំពីគំនិតផ្ទាល់ខ្លួន ដោយប្រើឃ្លាងាយៗ និងពិបាក។

៧. បង្ហាញឱ្យកុមារឃើញជាក់ស្តែង នូវទំនាក់ទំនងរវាងភាសានិយាយ និងភាសាសរសេរ។ គ្រូសរសេរពីមុខកុមារ ដោយនិយាយពាក្យដែលគាត់កំពុងសរសេរនោះ។ គ្រូសរសេរអ្វីដែលកុមារ និយាយ។

## ភាសាតាមរយៈសំឡេង

### នាំកុមារពង្រីកភាសាបង្កើនពាក្យ

១. គ្រូនាំកុមាររកពាក្យឱ្យបានច្រើន ដែលសរសេរជាតួអក្សរណាមួយ ។

ឧទាហរណ៍៖ «ទ»៖ទា ទូក ទោច ទុង ទោង ...។

២. កុមារបំពេញឃ្លាដោយប្រើពាក្យ ដែលសរសេរដោយតួអក្សរណាមួយ ដែលគ្រូកំណត់។

៣. កុមារត្រូវរកពាក្យដែលគ្រូបានលុបចេញនៅក្នុងចម្រៀង ឬ កំណាព្យដែលគេធ្លាប់ស្គាល់។ ដោយផ្អែកទៅលើការចាំមាត់នៃបទចម្រៀង និង ការសង្កេតនៅលើតួអក្សរសរសេរ កុមារត្រូវរកពាក្យមួយផ្នែក ដែលគ្រូបានលុបចេញ។

៤. ល្បែងបិទបាំងនៅពេលដែលគ្រូបង្ហាញរូបអ្វីមួយដែលកុមារស្គាល់ មុនដំបូងត្រូវលាក់ផ្នែកខ្លះ ហើយ បង្ហាញបន្តិចម្តងៗ ដើម្បីឱ្យកុមាររិះគិតអំពីចំណែកតូចមួយ ដែលគេបានមើលឃើញ និង ធ្វើការពិចារណា ហើយសន្និដ្ឋានថារូបអ្វី?។

ការបង្ហាញរូបភាពមួយៗ គ្រូបង្កើតជាវត្ថុមួយ ដែលអាចធ្វើទៅបាន។ របៀបនេះធ្វើឱ្យកុមារមានបំរុង ប្រយ័ត្នជាច្រើន ជាពិសេស បើគ្រូរកឃើញនូវមធ្យោបាយដែលត្រូវអ្វើជាមួយកុមារដោយបង្ហាញ សញ្ញាទាំងនោះ ព្រមទាំងបង្កើត ចេញជារូបមន្តនៃសម្មតិកម្ម។

**ឧទាហរណ៍៖** ចំពោះអក្សរ «ជ» ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

គ្រូចង្អុលត្រង់កន្លែងបិទបាំងដោយបង្កើតជាសំណួរ «តើមានរូបអ្វីនៅត្រង់កន្លែងនេះ?» គ្រូជំរុញភាពក្លាហានរបស់កុមារ ដើម្បីគេបង្កើតចេញជារូបមន្តសម្មតិកម្មជាច្រើន រួចហើយត្រូវបញ្ជាក់ពីសម្មតិកម្មទាំងនោះ។ ពេលណាបើកត្រង់កន្លែងបិទបាំង គ្រូថាពាក្យនោះ រួចហើយសរសេរពាក្យនោះនៅលើក្ដារខៀន។ ទីបញ្ចប់ គំនូរត្រូវបានពន្យល់។ គេនឹងស្ដាប់សូរនៃពាក្យទាំងនោះ ដើម្បីរកឃើញសូរតែមួយ រួចហើយគេនឹងរកឈ្មោះតួអក្សរ។

**ឧទាហរណ៍៖** រូបភាពបិទបាំង

នាំកុមារមើលផ្នែកសម្គាល់ខ្លះៗ ដើម្បីធ្វើការប៉ាន់ស្មាន រកហេតុផលបញ្ជាក់លើការប៉ាន់ស្មាននោះ និងកែតម្រូវវិញនៅពេលឃើញផ្នែកសម្គាល់ថ្មីៗទៀត។

គ្រូមានរូបភាពមួយដែលគ្រូមិន បង្ហាញឱ្យកុមារឃើញឡើយ។ គ្រូត្រៀមក្រដាសក្រាស់សម្រាប់បាំងឱ្យ បានធំជាងរូបភាពនោះ ដោយមានតែប្រហោងមួយតែប៉ុណ្ណោះ។

១. ដំបូងគ្រូដាក់ឱ្យឃើញតាមប្រហោងនោះ តែផ្នែកសម្គាល់មួយដែលអាចឱ្យកុមារប៉ាន់ស្មានច្រើនយ៉ាង

២. គ្រូរំកិលក្រដាសបាំងទៅកន្លែងផ្សេងទៀត។ កុមារនឹងអាចជ្រើសរើសយកចម្លើយណាមួយដោយ ទាត់ចោល នូវចម្លើយដទៃទៀត។

សំខាន់គឺធ្វើឱ្យកុមារនិយាយៈ រាល់ការប៉ាន់ស្មានទាំងអស់ត្រូវតែពន្យល់ រកហេតុផលបញ្ជាក់។ ត្រូវជំរុញ ឱ្យកុមាររកយោបល់ជំទាស់នឹងចម្លើយរបស់មិត្តខ្លួន។ គ្រូត្រូវរក្សាផ្ទាំងក្រដាសបាំងនោះឱ្យនៅមួយកន្លែង រហូតដល់កុមារបានឆ្លើយ និងពិក្សាលើការប៉ាន់ស្មាននោះរួចអស់។

៣. នេះជាផ្នែកសម្គាល់ថ្មីចុងក្រោយ មុននឹងបើករូបភាពនេះទាំងអស់ឱ្យកុមារមើល។ ទោះជាចម្លើយ អាចរកឃើញ ឬមិនអាច ក៏មិនជាការអ្វីឡើយ។ សំខាន់គឺនាំឱ្យកុមាររកហេតុផល កែតម្រូវ តម្រៃ តម្រង់ ឬ បំពេញចម្លើយរបស់ខ្លួន ទៅតាមព័ត៌មាននៃផ្នែកសម្គាល់ថ្មីមួយ ប៉ុន្តែដោយមិនបំភ្លេចចោល នូវចម្លើយមុនៗឡើយ។

## ៥. ការរកទិសក្នុងលំហ

គឺជាសមត្ថភាពរបស់កុមារ ដើម្បីស្គាល់ទីកន្លែងមួយ ដែលស្ថិតនៅក្នុងលំហ ការស្គាល់ទីតាំងខ្លួនដោយប្រៀបធៀបទៅនឹងចំណុចសម្គាល់មួយ។ ការស្គាល់ទិសក្នុងលំហប្រៀបប្រដូចនឹងការស្គាល់សញ្ញាណ ដំបូងនៃលំហ (មុន ក្រោយ ចំហៀង ខ្ពស់ ចន្លោះ លើ ខាងលើ ខាងក្រោម...) ដើម្បីរៀបចំកុមារឱ្យរៀនសូត្រ អំពីការអាន និងសរសេរ គ្រូមត្តេយ្យសិក្សា ត្រូវអនុវត្តសកម្មភាពដែលនាំឱ្យកុមារស្គាល់ទិសនៃការសរសេរអក្សរ។

## លំហាត់សម្រាប់ការស្គាល់លំហ

❖ **ថ្នាក់កម្រិតទាប និង មធ្យម**

គ្រូបង្កើតល្បែងនានាដោយបញ្ចូលពាក្យ ដែលទាក់ទងនឹងការស្គាល់ទិស៖ លើ ក្រោម មុខ ក្រោយ ខាងក្នុង ខាងក្រៅ។

១. សួរកុមារបន្តគ្នា៖ «អ្នកណានៅពីមុខអ្នក នៅខាងឆ្វេង ...?»។ «ហៅឈ្មោះវត្ថុណាមួយដែលនៅលើតុ» «តើមានអ្វីនៅពីលើក្តារខៀន ក្រោមបង្អួច...?»

២. ណែនាំកុមារឱ្យដឹងពីសញ្ញាណ ខាងក្នុង ខាងក្រៅ ។ កុមារដាក់វត្ថុនានា នៅខាងក្នុង ឬខាងក្រៅ រង្វង់។

❖ **ថ្នាក់កម្រិតខ្ពស់**

១. បង្កើតល្បែងនានាដោយបញ្ចូលពាក្យដែលទាក់ទងនឹងការស្គាល់ទិស៖ មុខ ក្រោយ ជិត លើ ក្រោម ចន្លោះ ពីលើ ពីក្រោម ...។

- លោតពីលើខ្សែ។
- លោតចូលក្នុងកង។
- ចូលក្រោមតុ។
- ដើរចន្លោះ ។ «បូណា» និង «នារី»
- ដាក់ខ្មៅដៃនៅលើតុ ។
- ដើរមួយជំហានទៅមុខ ទៅក្រោយ ។
- ............

២. ល្បែងឆ្លងកាត់ឧបសគ្គ។

**ការស្គាល់សងខាងខ្លួន**

កុមាររកទិសក្នុងលំហដោយយកខ្លួនរបស់គេជាមូលដ្ឋាន។ គឺជាការចាំបាច់ ត្រូវយកផ្នែកណាមួយដែល ជាគោលដើម្បីនូវនិតិសម្បទាយ៉ាងច្បាស់លាស់ ដូចជា ស្តាំ ឬ ឆ្វេង ។ គ្រូត្រូវពិនិត្យមធ្យោបាយនៃការសម្តែង សមានចិត្តដោយសម្តី ឬ ដោយកាយវិការរបស់កុមារ ដើម្បីយល់ដឹងអំពីការប្រើប្រាស់ដៃរបស់គេ និង ខ្លួនគេជា ចំណុចគោល ព្រមទាំងការអភិវឌ្ឍនៃផ្នែកនោះ។

## លំហាត់ដោយយកដងខ្លួនជាមូលដ្ឋាន

❖ **ថ្នាក់កម្រិតទាប**

១. កុមារឈរ គ្រូបង្គាប់ឱ្យកុមារពត់ខ្លួនទៅស្តាំ ទៅឆ្វេង ទៅមុខ ទៅក្រោយ។

២. កុមារលោតទៅមុខ លោតថយក្រោយ លោតស្តាំ លោតទៅឆ្វេង។

❖ **ថ្នាក់កម្រិតមធ្យម**

១. ធ្វើចលនានៅក្នុងលំហ ដោយប្រើដៃដែលគេធ្លាប់ប្រើជាញឹកញាប់។ធ្វើចលនាដោយប្រើដៃម្ខាងទៀត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

២. កុមារអង្គុយផ្ទាល់ដី គ្រូបង្គាប់ឱ្យកុមារដាក់វត្ថុខាងស្តាំ ខាងឆ្វេង ខាងមុខ ខាងក្រោយខ្លួន។ ធ្វើលំហាត់ ដដែលដោយឱ្យកុមារឈរម្តង។
៣. ធ្វើលំហាត់ដោយប្រើតែដៃស្តាំ ហើយបន្ទាប់មក ប្រើដៃផ្នែកឆ្វេង ។ (គ្រូសួរកុមារថា តើផ្នែកណាងាយស្រួលជាង)។
៤. បង្វិលកងនៅក្រៅថ្នាក់ ដោយប្រើបាតដៃស្តាំ កុំឱ្យប៉ះឧបសគ្គ ហើយបន្ទាប់មកបង្វិលដោយបាតដៃឆ្វេង។
៥. ផ្លាស់ប្តូរទីកន្លែងទៅតាមសញ្ញាបញ្ជា ដូចជា «ចូរអ្នកឈរខាងស្តាំតុ»...។
៦. ត្រៀមរៀបចំទុកជាស្រេចមុននឹងធ្វើលំហាត់នេះ។ ឧទាហរណ៍៖ ទះដៃមួយដងបានន័យថា បែទៅស្តាំ ទះដៃពីរដងបានន័យថា បែទៅឆ្វេង ទះដៃបីដងបានន័យថា ឈប់ស្ងៀម។ កុមារផ្លាស់ប្តូរ ចលនានៅនឹងកន្លែង ឬតាមជួរដោយរបៀបផ្សេងគ្នា និងគោរពទៅតាមបញ្ជា។
៧. ដាក់រាងរង្វង់ ឬ រាងការេដែលជាតំណាងដុំថ្មនៅក្នុងរង្វង់នៅលើដី។ ថ្មទាំងនេះមានពីរពណ៌ ហើយបទ បញ្ជាមានដូចតទៅ៖ជើងស្តាំដាក់នៅលើថ្មពណ៌ក្រហម និង ជើងឆ្វេងដាក់លើថ្មពណ៌លឿង។ កុមារលោតតាម ចង្វាក់ ហើយកាន់តែលឿនឡើងៗ។
៨. គ្រូចងខ្សែនៅដៃស្តាំរបស់កុមារ ហើយប្រាប់គេឱ្យច្បាស់ថា នេះគឺដៃស្តាំ។ កុមារនោះដើរតាមសម្លេង ចម្រៀង ដោយមានកាន់បាល់មួយ ។ ពេលចប់ចម្រៀងកុមារបណ្តើរបាល់ដោយដៃ ដែលមានចងខ្សែនោះ។ គ្រូ សួរឱ្យកុមារឆ្លើយ តើដៃចងខ្សែនោះជាដៃខាងណា (ឆ្វេង ឬ ស្តាំ)។
៩. កុមារឈរជាជួរ ហើយម្នាក់ៗ កាន់បាល់មួយ ។ កាលណាគ្រូនិយាយថា «ខាងស្តាំ» កុមារត្រូវប្រមៀល បាល់លើជើងស្តាំដោយដៃស្តាំ។ បើគ្រូនិយាយថា «ខាងឆ្វេង» កុមារត្រូវប្រមៀលបាល់លើជើងឆ្វេងដោយដៃ ឆ្វេង។

❖ **ថ្នាក់កម្រិតខ្ពស់**

១០. ចងខ្សែបញ្ឈរត្រង់មួយ ហើយឱ្យកុមារឈរចំកណ្តាលដើម្បីឱ្យមើលទៅឃើញរាងកាយរបស់គេដែលចែក ជាពីរផ្នែកដូចគ្នាដោយខ្សែនោះ ហើយហៅឈ្មោះ និងធ្វើចលនាមួយផ្នែកនៃរាងកាយ (ឧទាហរណ៍៖ជើង ដៃ កំភួនដៃ ជង្គង់ ផ្នែកខាងស្តាំ)។ កុមារហៅឈ្មោះ និង ធ្វើចលនាផ្នែកម្ខាងទៀត (ខាងឆ្វេង)
១១. កាត់ក្រដាសជារាងបាតដៃ ដោយយកទំហំប្រហាក់ប្រហែលនឹងដៃកុមារ (ខ្នាតដៃស្តាំ ចំនួន ៦ ដោយ យកពណ៌តែមួយ និង ដៃឆ្វេងដោយពណ៌តែមួយផ្សេងទៀត)។ បិទបាតដៃទាំងនេះនៅលើជញ្ជាំង ដោយឆ្លាស់ ដៃឆ្វេង និង ដៃស្តាំ ។ កុមារដាក់ដៃរបស់ខ្លួនទៅលើដៃម្តងមួយៗ ដោយនិយាយថា «ស្តាំ» និង «ឆ្វេង»...។
១២. ធ្វើលំហាត់ដដែលនេះនៅលើដី ឬ លើទីណាដែលគេអាចបិទរូបបាតជើងបាន។ បិទរូបបាតជើងដោយប្តូរ ទិស ឬដាក់ជិតផ្ទុំគ្នា ដោយមិនបាច់គិតអំពីការផ្លាស់ពណ៌ឡើយ។
១៣. សម្រួលចលនាខ្វែងគ្នាដែលទាក់ទង ខាងឆ្វេង ខាងស្តាំ។

ឧទាហរណ៍៖ – កាន់ក្បាលជង្គង់ស្តាំដោយប្រើដៃឆ្វេង។
– ដាក់ដៃស្តាំទៅលើកែងដៃឆ្វេង។

១៤. គ្រូហៅឱ្យកុមារគូរតាម: គូរលើក្តារខៀន ក្តារឆ្នួន ឬក្រដាស។

ឧទាហរណ៍ៈ – គូរកូនឃ្លីមួយពណ៌ក្រហមនៅជ្រុងខាងលើ ផ្នែកខាងឆ្វេង។

– គូរកូនឃ្លីមួយពណ៌លឿងនៅខាងស្តាំកូនឃ្លីពណ៌ក្រហម...។

## ការស្គាល់ទិស និង សំណេរ

ណែនាំកុមារឱ្យស្គាល់ទិសក្នុងការសរសេរ ( ពីឆ្វេងទៅស្តាំ ពីក្រោមទៅលើ ពីលើចុះក្រោម )។

១. កុមារគូសក្នុងលំហរនូវតួអក្សរផ្សេងៗ ទៅតាមការណែនាំរបស់គ្រូ ពីក្រោយឡើងលើ ពីឆ្វេងទៅស្តាំ ពីលើចុះ ក្រោម )។

២. កុមាររៀបតួអក្សរដោយប្រើគ្រាប់គ្រួស ឬ ចង្កឹះដោយស្តាប់តាមការណែនាំរបស់គ្រូ។

ផាត់ពណ៌កុមារដែល នៅក្រោមតុ។

ផាត់ពណ៌វត្ថុណាដែលនៅពីមុខវត្ថុមួយទៀត។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ជួយរកផ្លូវឱ្យកូនកណ្ដុរផង



ផាត់ពណ៌បៃតង ប្រអប់ណាដែលនៅខាងឆ្វេងបាល់។
ផាត់ពណ៌ក្រហម ប្រអប់ណាដែលនៅខាងស្ដាំបាល់។







youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៦. ការរៀនសម្គាល់ពេល និង សម្គាល់ចង្វាក់

ការសម្គាល់ពេល គឺជាសមត្ថភាពរបស់កុមារក្នុងការធ្វើសកម្មភាពមុនរួចបន្តបន្ទាប់ ដោយបញ្ជាក់លក្ខណៈ បច្ចុប្បន្នកាល អតីតកាល និង អនាគតកាល ដើម្បីយល់ដឹងអំពីចង្វាក់។ ចង្វាក់ គឺជាលំនាំដែលក្លាយទៅជា សកម្មភាពមួយ ឬ ទៅជាសកម្មភាពបន្តបន្ទាប់គ្នាជាច្រើន។

ឧទាហរណ៍៖ សញ្ញាណនៃភាពលឿន៖ រហ័ស យឺត សញ្ញាណនៃប្រវែង៖ ខ្លី វែង សញ្ញាណនៃរយៈពេលដ៏ខ្លី៖ មុន បន្ទាប់ ឬការបន្តបន្ទាប់គ្នាពីចំណាត់ថ្នាក់លេខមួយ រហូតដល់លេខបញ្ចប់។ ចំពោះការរៀនសូត្រ នៅសាលាគេនឹងអាចភ្ជាប់ទំនាក់ទំនងរវាងសញ្ញាណ លំហ ពេល និង ចង្វាក់តាមរបៀបដូចតទៅ៖ កុមារអានឬសរសេរ ពីឆ្វេង ទៅស្តាំ កុមារត្រូវដឹងថា ត្រូវសរសេរអ្វីមុន អ្វីក្រោយ និងត្រូវចេះសរសេរ តាមរបៀបត្រឹមត្រូវ ដើម្បីបង្កើតបានជាអត្ថបទដែលគេមើលយល់ ឬ សរសេរមានរបៀបល្អ។

**លំហាត់សម្រាប់ការសម្គាល់ពេល និង សម្គាល់ចង្វាក់**

❖ **ថ្នាក់កម្រិតទាប មធ្យម**

១. ធ្វើត្រាប់តាមបទចម្រៀង ឬរឿងនិទានខ្លីទៅតាមលំដាប់លំដោយ។

២. កុមារប្រមៀលបាល់នៅលើដី កាត់ពីមុខវត្ថុមួយដែលគ្រូបានកំណត់ ឱ្យកុមារទះដៃមុនពេលបាល់ទៅដល់ ឬហួសវត្ថុដែលកំណត់នោះ។

៣. នាំកុមារឱ្យស្គាល់អំពីល្បឿនដោយចោទសំណួរដូចជា៖

តើល្បឿនអ្វីដែលលឿនជាងគេ?

- យន្តហោះ និង កប៉ាល់?
- ទន្សាយ និង អណ្តើក?
- អ្នកជិះកង់ និង អ្នកជិះឡាន?

❖ **ថ្នាក់កម្រិតខ្ពស់**

១. គ្រូជ្រើសរើសព្រឹត្តិការណ៍មួយ ដែលគាត់បានចូលរួមជាមួយនឹងកុមារ ក្នុងពេលកន្លងទៅថ្មីៗនេះ។ ឧទាហរណ៍៖ ការចេញទស្សនាសង្កេត។ កុមារត្រូវរៀបរាប់ព្រឹត្តិការណ៍នេះតាមលំដាប់លំដោយ។ គ្រូសួរសំណួរ ទាក់ទងនឹងសកម្មភាព «មុនពេលចេញទស្សនាសង្កេត» មុននឹងចេញដំណើរ តើយើងបានធ្វើអ្វីខ្លះ? នៅពេលទស្សនាសង្កេត តើយើងបានធ្វើអ្វីខ្លះនៅទីនេះ? និងក្រោយទស្សនាសង្កេត តើយើងត្រូវធ្វើអ្វីខ្លះ?។ ជាការចាំបាច់ គ្រូត្រូវជ្រើសរើសព្រឹត្តិការណ៍ណាដែលទើបនឹងកន្លងផុតទៅថ្មីៗ។

២. គ្រូឱ្យកុមារនិយាយអំពីសកម្មភាពខ្លះដែលគេបានធ្វើបន្ទាប់ពីដំណេក។ ណែនាំឱ្យកុមាររៀបរាប់តាមលំដាប់ លំដោយអំពីអ្វីដែលគេបានធ្វើបន្តបន្ទាប់។

៣. ក្នុងពេលជាមួយគ្នាឱ្យកុមារធ្វើសកម្មភាព ៣ បន្តបន្ទាប់ឱ្យបានត្រឹមត្រូវ។

៤. គូសបន្ទាត់ត្រង់បញ្ឈរមួយនៅចំកណ្តាលក្តារខៀន។ គ្រូឈរនៅខាងឆ្វេងក្តារខៀន ហើយដើរមកចុង ក្តារខៀនខាងស្តាំ ដោយយកចង្អុលដៃគូសបង្អួសនៅលើក្តារខៀន។ គ្រូចែកកុមារជាបីក្រុម។ ក្រុមទីមួយ បញ្ចេញ សម្លេង «អា» នៅពេលដែលចង្អុលដៃគ្រូ នៅខាងមុខបន្ទាត់ត្រង់។

ក្រុមទីពីរ ទះដៃនៅពេលចង្អុលដៃគ្រូអូស កាត់ ចំបន្ទាត់ត្រង់បញ្ឈរ ហើយក្រុមទីបី បញ្ចេញសម្លេង «អ៊ូ» នៅពេលចង្អុលដៃគ្រូបង្អូសមកក្រោយបន្ទាត់ត្រង់ នោះ។

៥. ណែនាំឱ្យកុមារស្គាល់ ពេលវេលា ក្នុងមួយថ្ងៃ ស្គាល់ថ្ងៃក្នុងមួយសប្តាហ៍ ចេះប្រើប្រាស់នូវចំណុចសម្គាល់ សរសេរឈ្មោះថ្ងៃ តាមលំដាប់លំដោយ។ រាល់ៗព្រឹក គ្រូត្រូវណែនាំឱ្យកុមារស្គាល់ថ្ងៃនេះ ម្សិលមិញ និងថ្ងៃស្អែក ជាថ្ងៃអ្វី?។ គ្រូសរសេរថ្ងៃទាំងអស់ ព្រមទាំងរៀបចំតាមលំដាប់ពេលវេលាផ្សេងៗគ្នានៃថ្ងៃ។

៦. គ្រូត្រូវសង្កត់ធ្ងន់ទៅលើវាក្យស័ព្ទ ដែលទាក់ទងនឹងពេល ដោយឱ្យជាបទបញ្ជា ឬចោទជាសំណួរផ្សេងៗ។

៧. កុមាររៀបរូបភាពទៅតាមលំដាប់ពេល ដូចជា ការនិទានរឿងមួយ។ រៀបតាមលំដាប់លំដោយពីឆ្វេងទៅស្តាំ នៅលើបន្ទាត់មួយ៖

| | | | | |
|---|---|---|---|---|
| ១ | ២ | ៣ | ៤ | រូបភាព |
| ------------<br>------------ | ------------<br>------------ | ------------<br>------------<br>------------ | ------------<br>------------<br>------------ | អត្ថបទ |

៨. គ្រូបង្ហាញចលនាតាមរយៈកាយវិការ ការនិយាយ ឬរូបភាព ដើម្បីឱ្យកុមារមានការចងចាំ។

ឧទាហរណ៍៖

១ ២ ៣ ៤



(**របៀបបកស្រាយដោយការសម្តែង**)

ឱ្យកុមារលោតពីរជេងទៅមុខ រួចដាក់ដៃឆ្វេងលើក្បាល បន្ទាប់មក ដាក់ដៃស្តាំលើចង្កេះ និងចុងបញ្ចប់ បិទភ្នែក (របៀបបកស្រាយដោយការនិយាយ)។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ចង្វាក់

❖ **ថ្នាក់កម្រិតទាប**

១. កុមារធ្វើចលនាតាមចង្វាក់ស្គរដោយសេរី ឬដោយទះដៃ។

២. កុមារធ្វើចលនាតាមចង្វាក់ខុសៗគ្នា (ដើរយឺត ដើរលឿន រត់...)។

៣. ឱ្យកុមារអើត្រាប់តាមដំណើរសត្វដូចជា ដំរី កណ្តុរ កង់គួរ កូនទា...។

❖ **ថ្នាក់កម្រិតមធ្យម**

១. ណែនាំឱ្យកុមារធ្វើចលនា ឬត្រាប់តាមបទភ្លេង។

២. កុមារដើរឬ យោលខ្លួនទៅតាមចង្វាក់ភ្លេង (កុមារត្រូវឈប់ នៅពេលគ្រូបញ្ឈប់ភ្លេង ហើយធ្វើសារឡើងវិញ នៅពេលឮសូរភ្លេង)។

៣. គ្រូបង្កើតចម្រៀងងាយៗ ឬ រឿងនិទានដែលកុមារធ្លាប់ស្គាល់ហើយ ដោយធ្វើចលនាទះដៃ ទះភ្លៅគោះជើង ឬទះដៃជាមួយកុមារផ្សេងៗទៀត។

៤.លេងជាមួយនឹងកង គ្រូធ្វើចលនាខុសៗគ្នា ហើយឱ្យកុមារធ្វើចលនានោះតាមលំដាប់លំដោយ។

៥. កុមារត្រូវបំពេញចន្លោះណាដែលគ្រូដាក់ឱ្យដោយគោរពទៅតាមន័យ និងលំដាប់។

ចូរកាត់និងបិទរូបនេះតាមលំដាប់សកម្មភាព នារីញុាំចេក។

- នារីយកចេក
- នារីបកសំបកចេក
- នារីចោលសំបកចេក
- នារីញុាំចេក។

| | |
|---|---|
| នាងបកសំបកចេក ១  | នាងចោលសំបក ២  |
| នាងញុាំចេក ៣  | នាងយកចេក ៤  |

ឧទាហរណ៍សកម្មភាពអំណានៈ ក្រោយពីបានតំរៀបរូបភាពរួច កុមាររកពាក្យ«សំបក» និង «ចេក» ។ បន្ទាប់មក កុមារសាកល្បងបង្កើតឃ្លា។

ចូរកាត់ និងបិតរូបនេះតាមលំដាប់សកម្មភាព។ តើអ្នកឃើញរូបអ្វីខ្លះ?

១. សុភាពយកច្រាស និង ថ្នាំដុសធ្មេញ។
២. សុភាពច្របាច់ថ្នាំដុសធ្មេញដាក់លើច្រាស។
៣. សុភាពដុសសំអាតធ្មេញ។
៤. សុភាពលាងសំអាតមាត់ធ្មេញ។



ឧទាហរណ៍សកម្មភាពអំណានៈ

- ក្រោយពីរៀបចំតាមលំដាប់រួច កុមារចំណាំពាក្យ»ធ្មេញ «។
- កុមារទាយស្មាន រួចអានឃ្លាជាមួយគ្រូ។

ចូរកាត់ និង បិទរូបនេះតាមលំដាប់សកម្មភាព។

| | |
|---|---|
| ខ្ញុំអុជទៀន  | នេះគឺទៀនមួយដើម  |
| ទៀនឆេះបំភ្លឺ  | ខ្ញុំផ្លុំពន្លត់ទៀន  |



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ចូរកាត់ និង បិទរូបទាំងនេះ តាមលំដាប់សកម្មភាព



ចូរកាត់ និង បិទរូបទាំងនេះ តាមលំដាប់សកម្មភាព



លំហាត់សាច់រឿង៖ គខងក

រូបដែលមិនទាក់ទង៖ ឃ

ចូររៀបរឿងនេះទៅតាមលំដាប់សកម្មភាព ហើយដកចេញរូបណាដែលមិនទាក់ទងនឹងសាច់រឿង

| | |
|---|---|
| ក  | ខ  |
| គ  | ឃ  |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**កំណាព្យ**

- បទពាក្យ៤ កើតក្នុងដំណាក់កាលនគរភ្នំ ឬ ហ្វូណន ។
- បទបថ្យាវដ្ត កើតក្នុងដំណាក់កាលចេនឡា ។

**សម័យអង្គរ៖** នៅសម័យកាលនោះ កវីខ្មែរបានបង្កើតវិធីសាស្ត្រសម្រាប់តែងកំណាព្យចំនួន៥បទ ប៉ុន្តែពុំទាន់មានឈ្មោះត្រឹមត្រូវទេ។ គេបានសង្កេតឃើញបទទាំង៥នោះមានលំនាំតែងនិពន្ធប្រហាក់ប្រហែលទៅនឹង៖

- បទកាកគតិ - បទព្រហ្មគីតិ
- បទបន្ទោលកាក - បទពំនោល
- បទភុជង្គលីលា

**សម័យកាលកណ្ដាល៖** តាមការសិក្សាស្រាវជ្រាវប្រវត្តិសាស្ត្រ អក្សរសាស្ត្រ ក៏ដូចជាសង្គមសាស្ត្រ សម័យកាល កណ្ដាលនេះបានក្ដោបយកដំណាក់កាលឧដុង្គ និងដំណាក់កាលលង្វែក។ អ្នកសិក្សាស្រាវជ្រាវបានសង្កេតឃើញថាសម័យកាលកណ្ដាលនេះជាសម័យកាល ដែលបានដាក់ឈ្មោះបទទាំង៥ នាសម័យកាលអង្គរឱ្យមានឈ្មោះត្រឹមត្រូវថា៖

- បទកាកគតិ - បទព្រហ្មគីតិ
- បទបន្ទោលកាក - បទពំនោល
- បទភុជង្គលីលា

តាមការសិក្សាស្រាវជ្រាវបានឱ្យដឹងថា សម័យកាលកណ្ដាល ជាសម័យកាលដែលប្រើប្រាស់ ឬ អនុវត្តយ៉ាងខ្លាំងក្លាខ្ជាប់ខ្ជួន និងយ៉ាងផ្ចិតផ្ចង់នូវវិធីសាស្ត្រតែងនិពន្ធទាំង៧បទនៃសម័យកាលមុនអង្គរ និងសម័យកាលអង្គរ។ លើសពីនេះទៀតកវីខ្មែរយើងបានបង្កើតវិធីសាស្ត្រតែងនិពន្ធកំណាព្យមួយបទទៀតគឺ បទពាក្យ៦។ វិធីសាស្ត្រតែង និពន្ធកំណាព្យទាំង ៨បទខាងលើនេះគេហៅថា បទបុរាណ ។

**សម័យកាលចតុមុខ៖** ដោយយល់ថាបទបុរាណទាំង៨បទខាងលើ ជាបទដែលលំបាកក្នុងការតែងនិពន្ធ កវីខ្មែរយើងក៏បានបង្កើតនូវវិធីសាស្ត្រងាយៗ ក្នុងការតែងនិពន្ធចំនួន៥បទទៀតគឺ៖

- បទពាក្យ ៧ - បទពាក្យ ៨
- បទពាក្យ ៩ - បទពាក្យ ១០
- បទពាក្យ ១១

## **អនុវត្តន៍**

### ១- ត្រូវចេះគួរសមមុនពេលចេញទៅផ្ទះ

(បទកាកគតិ)

មុនពេលទៅផ្ទះ លើកដៃសំពះ ជម្រាបលាគ្រូ
ហើយតម្រង់ជួរ មួយគួៗ កុំឱ្យយឺតយូរ
ខាតពេលវេលា ។

### ២- ត្រូវចេះជម្រាបសួរពុកម៉ែ យាយតា

(បទកាកគតិ)

ពេលទៅដល់ផ្ទះ យើងត្រូវសំពះ ជម្រាបពុកម៉ែ
លោកយាយលោកតា ពូមីងផងដែរ តាមទម្លាប់ខ្មែរ
យើងពីបុរាណ ។

## ៣- អ្នកគ្រូមត្តេយ្យ

(បទកាកគតិ)

អ្នកគ្រូមត្តេយ្យ ជាម្ដាយទីពីរ របស់យើងខ្ញុំ
គាត់ថែរក្សា ព្រមទាំងណែនាំ ឱ្យពួកយើងខ្ញុំ
រៀនផងលេងផង ។

## ៤- កុមារមត្តេយ្យ

(បទកាកគតិ)

យើងខ្ញុំកុមារ មត្តេយ្យសាលា ត្រូវស្ដាប់ពាក្យពេចន៍
អ្នកគ្រូប្រដៅ ត្រាប់តាមជានិច្ច មិនត្រូវវេះគេច
ឱ្យអ្នកគ្រូព្រួយ ។

## ៥- យើងថែទាំល្បែងលេង

(បទកាកគតិ)

ប្រដាប់ប្រដា មានល្បែងត្រៀបត្រា យើងលេងរាល់ថ្ងៃ
ត្រូវចែកមិត្តភក្ដិ ហើយចេះគិតថ្លៃ ថែទាំសំថៃ
កុំឱ្យបាក់បែក ។

## ៦- កុមារថ្មី

(បទកាកគតិ)

កម្ពុជាថ្មី កុមារមត្តេយ្យ ស្រឡាញ់គ្រប់គ្នា
ប្ដេជ្ញាខំរៀន ហើយនិងការពារ ដែនកម្ពុជា
ឱ្យបានគង់វង្ស ។

## ៧- យើងស្រឡាញ់អ្នកគ្រូ

(បទកាកគតិ)

ខ្ញុំស្រឡាញ់គ្រូ គាត់ចេះគិតគូរ ឱ្យយើងបានថ្លើង
ស្រឡាញ់ដូចបង ដូចពុកម៉ែយើង មកមិត្តកុំឆ្មើង
ធ្វើតាមអ្នកគ្រូ ។

## ៨- មិត្តថាសត្វអ្វី?

(បទកាកគតិ)

មិត្តអើយសត្វអ្វី រស់នៅលើដី មានរោមមានស្លាប
ម្រាមជើងជាប់គ្នា ស្រែកឮកាបៗ ដំណើរដូចក្រាប
ចំពុះវាវែង ។

មិត្តអើយសត្វនោះ ខ្ញុំឆ្លើយមិនខុស ប្រាប់ទៅមិត្តឯង
គឺជាសត្វទា ស្លាបពីរកវែង ក្បាលមូលត្រមែង
ភ្នែកពីរតូចៗ ។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ៩- សម្លៀកបំពាក់

(បទកាកគតិ)

សម្លៀកបំពាក់ បោកហាលទុកដាក់ រក្សាឱ្យល្អ
ស្លៀកពាក់ត្រឹមត្រូវ ជិតពោះទ្រូង ក សុខភាពបវរ
មាំទាំមាំមួន ។

### ១០- ដៃប្អូនទាំងពីរ

(បទកុជង្គលីលា)

ដៃប្អូនដុសធ្មេញឱ្យ ស ឱ្យបានស្អាតល្អ ចាំង ស ដូចភ្លុក ។
ដៃប្អូនសិតសក់វែកមុខ សក់វែងចងទុក សិតស្លូតទៅក្រោយ ។

## កម្រិតមធ្យម

### ១១- យើងតម្រង់ជួរ

(បទកាកគតិ)

សូរជួងម៉ឺងៗ រត់មកពួកយើង ឈរទន្ទឹមគ្នា
រៀបបានជាជួរ កុំនៅរេរោ ត្រង់ល្អម្ទីម្នា
យើងដើរចូលថ្នាក់ ។

### ១២- ខ្ញុំស្រឡាញ់មាតុភូមិ

(បទកាកគិត)

ឱកម្ពុជា យើងខ្ញុំគ្រប់គ្នា ស្រឡាញ់អ្នកណាស់
វាលភ្នំទន្លេ ព្រឹក្សាស្ដើងក្រាស់ សម្បូរឥតខ្វះ
ពេលពសុធា ។

ខ្ញុំប្ដេជ្ញាថា ធំឡើងកាលណា ចូលធ្វើយោធា
ធន្ទះមោះមុត កសាងការពារ ដែនកម្ពុជា
ឱ្យបានគង់វង្ស ។

### ១៣- មិត្តចំណាំបានអ្វីខ្លះ?

(បទកាកគតិ)

មិត្តអើយជួយចាំ ខំជួយចំណាំ មានផ្លែអ្វីខ្លះ
មានពណ៌ខុសគ្នា លឿងក្រហមចាស់ ផ្លែខ្លះសាច់ក្រាស់
ទឹកដមឈ្ងុយឆ្ងាញ់ ។

### ១៤- ធំឡើងខ្ញុំធ្វើយោធា

(បទកាកគតិ)

អាយុប្អូនឆ្នាំ ខ្ញុំរៀនឱ្យចាំ តាមអ្នកគ្រូថា
រៀនគ្រប់វិជ្ជា មត្តេយ្យសាលា ធំឡើងកាលណា
ខ្ញុំធ្វើយោធា ។

លះបង់ទាំងអស់ ការពារដោយស្មោះ ចិត្តខ្ញុំធានា
រក្សាឱ្យបាន សុខសាន្តគ្រប់គ្រា ឱ្យកម្ពុជា
មានសន្តិភាព

## ១៥- ខ្ញុំអាយុបួនឆ្នាំ

(បទកាកគតិ)

ខ្ញុំអាយុបួនឆ្នាំ ខ្ញុំរៀនចេះចាំ លេខ ១. ២ .៣
ចេះទាំងគូររូប កូនមាន់កូនត្រី ចេះទាំងស្រដី
និទានរឿនផង ។
នៅផ្ទះខ្ញុំជួយ ធ្វើការជួយមួយ ពុកម៉ែ និងបង
ស្រោចទឹកបន្លែ ចាប់ដង្កូវផង ធំឡើងខ្ញុំប៉ង
ធ្វើកសិករ ។

## ១៦- ត្រូវហូបទឹកឆ្អិន

(បទកាកគតិ)

យើងជាកុមារ ត្រូវតែចាំថា គួរហូបទឹកឆ្អិន
បើឃើញទឹកឆៅ ត្រូវបង្អង់សិន ចាំហូបទឹកឆ្អិន
ទើបគ្មានមេរោគ ។

## ១៧- ល្បែងលេងនានា

(បទកាកគតិ)

ល្បែងតុក្កតា រូបមាន់ឆ្កែឆ្មា គោសេះដំរី
កូនក្រមុំជ័រ ទន្សាយទាត្រី លេងទាំងប្រុសស្រី
សប្បាយអស្ចារ្យ ។
ឡានរទេះភ្លើង ល្បែងឡុកឡាក់យើង ថែទាំរក្សា
កុំឱ្យបាក់បែក រហែកឡើយណា ទើបបានឈ្មោះថា
ជាកុមារល្អ ។

## ១៨- យើងសាមគ្គីគ្នា

(បទកាកគតិ)

កុមារមេត្តេយ្យ ទាំងប្រុសទាំងស្រី សាមគ្គីសាមគ្គា
ពេលរៀនពេលឈប់ គ្រប់ពេលវេលា យកអាសាគ្នា
កុំខ្លាចនឿយហត់ ។
យើងជួយស្រោចផ្កា ជួយបោសសាលា ឱ្យបានម៉ត់ចត់
យើងរៀនធ្វើការ ឱ្យបានចេះស្ទាត់ ពេលភ័យកុំរត់
បោលមិត្តភក្តិយើង ។

## ១៩- ចេះថែទាំសម្លៀកបំពាក់

(បទព្រហ្មគីតិ)

ខោអាវត្រូវថែទាំ តាមលំនាំលំអានស្រាប់
កុំរាយឥតសណ្ដាប់ មិនគួរគាប់នឹងភ្នែកញាតិ ។
ជាកូនមានបទល្អ មិនដែលក្រឥតមារយាទ
ទុកដាក់ហើយចេះឆ្លៀត ជួយការទៀតជំនួសម្ដាយ ។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ២០- ជើងប្អូន

(បទព្រហ្មគីតិ)

ជើងតូចរបស់ប្អូន សស្រលូនគួរទម្លាប់
ថៃពាក់ថែមទ្រនាប់ ឱ្យបានជាប់ជាលំអ ។
ដើររត់មិនភ័យព្រួយ មានស្បែកជួយជើងជាល្អ
មិនពងមុត ឬដរ កមក្រមរមិនបៀតបៀន ។

## កម្រិតខ្ពស់

## ២១- ពេលដើរតាមផ្លូវ

(បទកាកគតិ )

ពេលដើរតាមផ្លូវកូនអើយកូនត្រូវ តែប្រកាន់ស្តាំ
ដើរអែបខាងៗ គ្រប់យ៉ាងកូនចាំ កុំភ្លេចបណ្តាំ
ដើរស្តាំជានិច្ច ។
ពេលឆ្លងកាត់ផ្លូវ កូនអើយកូនត្រូវ ប្រយ័ត្នមិនភ្លេច
ត្រូវមើលមុខក្រោយ សញ្ញារំលេច ប្រុងខ្លួនជានិច្ច
ទើបគេចផុតគ្រោះ ។

## ២២- យើងរៀនគ្រប់មុខវិជ្ជា

(បទកាកគតិ)

មត្តេយ្យកុមារ ខិតខំសិក្សា រៀនលេងរៀនគូរ
យើងរៀនគិតលេខ រៀនមើលគំនូរ ព្រមទាំងស្តាប់គ្រូ
និទានរឿងផង ។
យើងរាំយើងច្រៀង រៀនស្តាប់សូរសៀង កំណាព្យបងៗ
យើងដើរទស្សនា ហើយសង្កេតផង ហាត់ប្រាណតម្រង់
បានខ្លួនត្រង់ល្អ

## ២៣- មិត្តស្គាល់អ្វីខ្លះ ?

(បទកាកគតិ)

មិត្តចាំបានទេ នោះឈ្មោះអ្វីគេ ព្យួរចំពីមុខ
បើមិត្តថាត្រូវ មិត្តអស់មានស្មុគ ស្គាល់ចំណាំទុក
ខ្ញុំសូមសរសើរ ។

## ២៤- ត្រូវធ្វើពលកម្ម និង ចិញ្ចឹមសត្វ

(បទកាកគតិ )

កុមារប្រុសស្រី ត្រូវខំឃ្មាតខ្មី រៀនធ្វើពលកម្ម
រៀនដាំបណ្តុះ សព្វផលដំណាំ ស្រោចទឹកប្រចាំ
ថៃកុំទំនេរ ។
យើងចិញ្ចឹមមាន់ បានស៊ុតគ្រប់គ្រាន់ មិនខ្វះញាំទេ
យើងចិញ្ចឹមទា ក៏បានពងដែរ ដោយយើងចេះថៃ
ឱ្យចំណីសត្វ ។

## ២៥- អ្នកគ្រូយើង

(បទកាកគតិ)

អ្នកគ្រូយើងអើយ នៅជិតបង្កើយ កៀកកិតកុមារ
លួងលោមថ្នាក់ថ្នម អស់ពីចិន្តា ប្រៀបបុត្រស្នេហា
រក្សាលើកស្ទួយ ។
ពួកយើងសង្ឃឹម អ្នកគ្រូញញឹម រង់ចាំតែជួយ
ដោះស្រាយមុខក្រោយ មិនឱ្យមានព្រួយ យើងចិត្តតែមួយ
ស្រឡាញ់អ្នកគ្រូ ។

## ២៦- មិត្តចំណាំបានអ្វីខ្លះ ?

(បទកាកគតិ)

មិត្តអើយជួយចាំ ចំជួយចំណាំ មានផ្លែអ្វីខ្លះ
មានពណ៌ខុសគ្នា លឿងក្រហមចាស់ ផ្លែខ្លះសាច់ក្រាស់
ទឹកដមឈ្ងុយឆ្ងាញ់ ។

## ២៧- សាលា និង ផ្ទះ

(បទកាកគតិ)

នៅផ្ទះម៉ាក់ប៉ា ស្រឡាញ់រក្សា ថៃទាំកក់ក្តៅ
ពេលមកសាលា អ្នកគ្រូប្រដៅ មិនឱ្យល្ងង់ខ្លៅ
មោះមុតក្លាហាន ។
យើងសើចក្អាកក្អាយ សាលាសប្បាយ ច្រៀងរាំកំសាន្ត
រៀនគូរស្តាប់រឿង ចងចាំគ្រប់ប្រាណ ស្រឡាញ់រាប់អាន
ប្រៀបបានបងប្អូន ។

## ២៨- ពាក្យបណ្តៅដើមឈូក

(បទកាកគតិ)

ដើមវាប៉ុនទៀន កាលណាវាលៀន ស្លឹកធំប៉ុនថាស
បើមិត្តគិតឃើញ សូមឆ្លើយឱ្យច្បាស់ ពាក្យបណ្តៅចាស់
ដើមនេះដើមអ្វី ។
មិត្តអើយដើមនោះ ខ្ញុំទាយមិនខុស ស្លឹកបៃតងខ្ចី
គឺជាដើមឈូក ដើមប៉ុនមេដៃ ផ្កាក្រអូបក្រៃ
សាច់វាឆ្ងាញ់ណាស់ ។

## ២៩- ពាក្យបណ្តៅសត្វដំរី

(បទកាកគតិ)

មិត្តអើយចាំរក គិតហើយឆ្លើយមក ប្រាប់ខ្ញុំវិញណា
មានសត្វមួយនោះ មាឌធំអស្ចារ្យ លើសសត្វនានា
តែភ្នែកតូចណាស់ ។
មិត្តអើយខ្ញុំដឹង ឈ្មោះសត្វមួយហ្នឹង ខ្ញុំស្គាល់យ៉ាងច្បាស់
ពណ៌ខ្លួនក្របី ធំខ្ពស់ស្រឡះ ប្រមោយរហ័ស
គឺសត្វដំរី ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣០- ត្រូវធ្វើពលកម្ម

(បទកាកគតិ)

ពលកម្មកុមារ　យើងត្រូវឧស្សាហ៍　ប្រឹងប្រែងរាល់ថ្ងៃ
យើងធ្វើពីក្មេង　ចាស់ទៅធ្លាប់ដៃ　ចេះគិតចេះធ្វៃ
កសាងសេដ្ឋកិច្ច ។
ពេលធ្វើពលកម្ម　យើងត្រូវចំណាំ　យើងមិនត្រូវភ្លេច
យកចបកាំបិត　បង្គឹមកស្រេច　កាប់គាស់កំទេច
វល្លិស្មៅក្នុងធ្លា ។

## ៣១- ដើរក្រោមដៅថ្ងៃ

(បទព្រហ្មគីតិ)

សត្វចាបញីឈ្មោលច្រៀង　មានគូកៀងលើព្រឹក្សា
ទោះបីក្ដៅយ៉ាងណា　ក៏បក្សាមិនខ្វល់ខ្វាយ ។
ឯយើងត្រូវការពារ　ទើបជានាសុខសប្បាយ
ពាក់មួកទៅជិតឆ្ងាយ　សុខទាំងកាយសប្បាយចិត្ត ។

## ៣២- ហាត់ប្រាណដើម្បីសុខភាព

(បទកាកគតិ)

អរុណរះហើយ　ឱប្អូនៗអើយ　នាំគ្នាក្រោកឡើង
ហាត់ពត់កាយា　លើកដៃលើកជើង　ងើបមុខខ្ពស់ឡើង
ស្រូបយកខ្យល់ល្អ ។
កុំខ្ជិលកុំអៀន　ត្រូវតែប្រឹងប្រៀន　សុខភាពបវរ
នាំកាយចម្រើន　រឹងមាំដូចថ្ម　ជំងឺអន្តរ
ប្រាជ្ញាភ្លឺស្វាង ។

## ៣៣- ខែទាំង ១២

(បទព្រហ្មគីតិ)

ទីមួយខែមករា　ពីរសោតណាខែកុម្ភៈ
ទីបីមីនាដាក់　បួនលើកដាក់ខែមេសា ។
ឧសភាខែទីប្រាំ　ប្រាំមួយចាំមិថុនា
ប្រាំពីរខែកក្កដា　ខែសីហាទីប្រាំបី ។
ប្រាំបួនខែកញ្ញា　ដប់តុលាលោកស្រដី
ដប់មួយវិច្ឆិកាប្រិមប្រិយ៍　ដប់ពីរថ្មីត្រូវខែធ្នូ ។

## ៣៤- ឆ្នាំខ្មែរទាំង ១២

(បទកាកគតិ)

ខ្ញុំចេះទាំងអស់　ជូត ឆ្លូវ ខាល ថោះ　ចង់ចាំហូរហែ
រោង ម្សាញ់ មមី　មមែ ឆ្នាំខ្មែរ　វក រកា ដែរ
ច កុរ ក្រោយគេ ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ៣៥- សួនសាធារណៈ

(បទកាកគតិ)

នុះន៏សួនច្បារ មានស្មៅមានផ្កា ពណ៌ក្រហមលឿង
សិរមាន់ទំហូ ចន្ទស្បៃរឿង រីកវះរុងរឿង
ចំកណ្តាលសួន ។

### ៣៦- សិប្បកម្ម តុ ទូ

(បទកាកគតិ)

កៅអីតុ ទូ ស្នាដៃពូៗ នៅរោងសិប្បកម្ម
ម៉ែទិញដាក់ផ្ទះ ជូតជាប្រចាំ ប្រើប្រាស់យូរឆ្នាំ
ស្អាតភ្លឺរលោង ។

### ៣៧- ដើមត្នោត

(បទកាកគតិ)

កូនមើលដើមត្នោត ជូនតាជាំដោត នៅលើដីកេរ្តិ៍
ពីដើមរៀងមក ល្អឯកឥតទ្វេ ស្លឹកសោតយើងដេរ
ប្រក់លំនៅស្ថាន ។

ត្នោតតាដុះហៃ នៅលើភ្លឺស្រែ រុងរឿងច្រើនថ្នាន
មានផ្លែមានផ្កា ស្លហូបក៏បាន សង់ផ្ទះចំណាន
យើងបានសុខា ។

ពូកាន់ពូគាប ផ្កាល្អដោយឃ្នាប ទឹកផ្អែមណាស់ណា
រំងាប់ជាស្ករ ឈ្ងុយឆ្ងាញ់អស្ចារ្យ ម៉ែអាចប្រើការ
ធ្វើនំគ្រប់មុខ ។

### ៣៨- ពិធីបុណ្យអុំទូ

(បទកាកគតិ)

មិត្តអើយឃើញទេ នៅក្នុងទន្លេ មានទូកច្រើនក្រៃ
ខ្លះអុំខ្លះចែវ បង្ហាញថ្វីដៃ គំរប់បីថ្ងៃ
ប្រពៃណីជាតិ ។

ទំនៀមទម្លាប់ ខែដប់មួយជាប់ អារម្មណ៍ផៅញាតិ
ធ្វើបុណ្យអុំទូក ប្រជាព្រោងព្រាត គ្រប់គ្នាខ្មីឃ្មាត
ចូលរួមសប្បាយ ។

### ៣៩- សំណង់ពូយើង

(បទកាកគតិ)

ពូៗកម្មករ មានចិត្តស្មោះសរ ប្រឹងឥតបង្អង់
ខ្លះចូកខ្លះឃូរ ទាញខ្សែតំរង់ ដើម្បីសាងសង់
អគារថ្មីយើង ។

មើលពូកម្មករ រីករាយបវរ ញាប់ដៃញាប់ជើង
អគារតូចធំ លេចត្រដែតឡើង ស្នាដៃពូយើង
បានល្អអស្ចារ្យ ។

## ៤០- ចំការចេកតា

(បទកាកគតិ)

ថ្ងៃមួយនោះណា ខ្ញុំទៅផ្ទះតា ឃើញតាដាំចេក
តាដាំជាជួរ ត្រង់ល្អអនេក ខ្ញុំសប្បាយពេក
ជួយដាំចេកតា ។

## ៤១- គ្រឿងល្អឯក

(បទកាកគតិ)

ឱ!ពួកម្មករ ទឹកចិត្តស្មោះសរ ធ្វើការឥតអាក់
កាប់ជ្រុំជ្រួយដី បែកញើសសស្រាក់ មិនមានថ្នាំងថ្នាក់
ជាន់ដីយ៉ាងសឿង ។
រួចហើយពួយក ដីឥដ្ឋនោះមក បញ្ចូលពុម្ពក្បឿង
រួចដុតចំអិន ពណ៌ក្រហមលឿង ផ្សំបានគ្រប់គ្រឿង
ប្រក់ដំបូលផ្ទះ ។

## ៤២- ម៉ាញ៉េ

(បទកាកគតិ)

មិត្តអើយនុះន៍ អ្វីនៅបញ្ឈរ ក្បែរៗរាងកាយ
មានចុចមានមូល ខ្សែដោតបន្លាយ សូរស័ព្ទលាន់ឆ្ងាញ់
ពិរោះម៉្លេះទេ ។
រូបរាងបួនជ្រុង ទ្រវែងមានខ្ទង់ យើងខំរិះរេ
រៀនបើករៀនដាក់ កាសែតម៉ាញ៉េ ពេលយើងទំនេរ
រាំលេងសប្បាយ ។

## ៤៣- ផលប្រយោជន៍អិដ្ឋពណ៌

(បទកាកគតិ)

ហៃពួកមិត្តយើង ប្រញាប់ឆាប់ឡើង រូតរះម្ទីម្នា
មើលថ្នាក់រៀនយើង ពូខ្លះលាបទ្វា ពូខ្លះស្រាយលា
បត់ឡាំងអិដ្ឋពណ៌ ។
រលើបរលោង រលីងដូចត្បូង ចែងចាំងបវរ
ក្រហមលាយលឿង ខៀវបៃតងស ក្រាលឆ្លុះភ្លឺល្អ
យើងសែនបេតី ។
អិដ្ឋពណ៌មានផល យើងមិនខ្វាយខ្វល់ ជាន់ប្រលាក់ដី
យើងនាំគ្នាជួយ ទាំងប្រុសទាំងស្រី បោសជូតឃ្នាតខ្មី
ថែទាំជានិច្ច ។

## ៤៤- ប្រយោជន៍ក្រមា

(បទកាកគតិ)

ក្រមាសំខាន់ ស្លៀកមិនប្រកាន់ ជូតក្បាលអស្វារ្យ
បង់កពានា ទៅវត្តហ៊ុហា ក្រមានេះណា
អ៊ុំខ្ញុំគាត់ត្បាញ ។

## ៤៥- លូ អណ្តូង

(បទកាកគតិ)

អង្គុយឱ្យជិត យើងខំពិនិត្យ ការលាយបាយអ
ដាក់ខ្សាច់ដាក់ទឹក ស៊ីម៉ង់ និង ថ្ម រៀបពុម្ពឱ្យឈរ
ចាក់លូអណ្តូង ។

## ៤៦- រដូវចម្រូត

(បទកាកគតិ)

ចម្រូតដល់ហើយ កសិករអើយ ខិតខំធ្វើការ
ច្រូតកាត់បោកបែន ប្រមូលផល្លា ចិញ្ចឹមអាត្មា
តទៅថ្ងៃមុខ ។

## ៤៧- ម៉ាស៊ីនអារឈើ

(បទកាកគតិ)

ហ៊ុមមូលធំៗ ដឹកពីព្រៃភ្នំ គរផ្ដុំត្រៀបត្រា
បញ្ចូលម្ដងមួយ ក្រោមម៉ាស៊ីនអារ ច្រៀកដោយរណារ
ក្ដារឈើគ្រប់ធុន ។

## ៤៨- យើងថែទាំដំណាំ

(បទកាកគតិ)

មកមិត្តរាល់ព្រឹក បោចស្មៅស្រោចទឹក សណ្ដែកក្ងរយើង
កំពុងចេញផ្កា រហង់ពេញទ្រើង ផ្លែលេចចេញឡើង
ទាំងក្ងរៗ ។

## ៤៩- យើងដាំឬស្សី

(បទកាកគតិ)

ខ្ញុំដាំឬស្សី យកធ្វើអ្វីៗ បានតាមត្រូវការ
ដើមតូចដើមធំ តាមចិត្តប្រាថ្នា យើងខំរក្សា
វាឱ្យបានល្អ ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ឧបសម្ព័ន្ធទី ២
# គរុកោសល្យរៀន និងបង្រៀន

## គរុកោសល្យរៀន និងបង្រៀន
## ដើម្បីឆ្លើយតបសមភាពយេនឌ័រ រវាងកុមារី និងកុមារានៅមត្តេយ្យសិក្សា



## សម្រាប់ជំនួយដល់គ្រូមត្តេយ្យសិក្សាដឹកនាំ
## សកម្មភាពរៀន និងបង្រៀន

## ១-សេចក្តីផ្តើម

សមភាពយេនឌ័រ មិនមែនគ្រាន់តែជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការកសាងនិងរក្សាសន្តិភាព ភាពរុងរឿង និងស្ថិរភាពក្នុងសង្គមលើពិភពលោកផងដែរ។ ការផ្តល់ឱ្យស្ត្រី និងកុមារីនូវភាពស្មើគ្នាក្នុងការទទួលបាននូវការអប់រំ ការថែទាំសុខភាព ការងារដ៏ត្រឹមត្រូវ និងការត្រៀមជាស្រេចក្នុងការចូលរួមក្នុងដំណើរការសម្រេចចិត្តផ្សេងៗ ក្នុងសង្គមមួយដែលមានសមភាព និងស្ថិរភាព។

## ២-ស្ថានភាពទូទៅ

ផ្អែកលើស្ថានភាពជាក់ស្តែងក្នុងសង្គមកម្ពុជា ជារឿយៗឪពុកម្តាយនិងអ្នកថែកុមារមិនបានដឹងថាពួកគាត់បានបន្តបង្ហាញនូវផ្នត់គំនិតលម្អៀងជំនឿអំពីតួនាទីខុសគ្នារវាងបុរសនិងស្ត្រីនោះទេ។ កុមារីមួយចំនួនត្រូវបានទទួលការថែទាំនិងចិញ្ចឹមបីបាច់ខុសគ្នាពីកុមារា ជាទូទៅកុមារីត្រូវបានរៀបចំឱ្យស្លៀកពាក់ទៅតាមពណ៌ ដូចជាពណ៌ផ្កាឈូក ពណ៌ក្រហម ពណ៌ស្វាយជាដើម ហើយប្រដាប់លេងទៀតសោត គឺកូនក្រមុំ តុក្កតា និងប្រដាប់ប្រដាផ្ទះល្វែង គឺសម្រាប់កុមារីលេង រីឯបាល់ និងកូនឡាន សម្រាប់កុមារាលេង។ កូនស្រីត្រូវបានបង្រៀនឱ្យស្តាប់បង្គាប់និងសុភាពរាបសា រីឯកុមារាត្រូវបានបង្រៀនឱ្យក្លាហាន និងរឹងមាំ ជួនកាលកុមារីត្រូវបានការពារម៉ត់ចត់ជាងកុមារា ទន្ទឹមនឹងនេះកុមារាត្រូវបានបង្រៀនមិនឱ្យយំព្រោះជាសញ្ញាបង្ហាញថាទន់ខ្សោយ ។

នៅតាមសាលារៀន យើងសង្កេតឃើញថាការរៀបចំសកម្មភាពរៀននិងបង្រៀននៅកម្រិតមត្តេយ្យសិក្សាមួយចំនួន មិនទាន់ទទួលបាននូវបរិយាកាសរៀនសូត្រដែលមានលក្ខណៈសមភាពយេនឌ័រ រវាងកុមារីនិងកុមារានៅឡើយទេ។ កត្តាទាំងអស់នោះ គឺដោយសារតែចំណេះដឹង និងការអនុវត្តរបស់គ្រូផ្អែកលើផ្នត់គំនិតអវិជ្ជមានដែលបន្សល់ទុកតាំងពីដើមមក នឹងផ្អែកទៅលើកម្រិតចំណេះដឹងរបស់គ្រូជាពិសេសគ្រូមត្តេយ្យសិក្សាសហគមន៍ដែលមានការបណ្តុះបណ្តាលមិនទាន់គ្រប់គ្រាន់នៅឡើយ។ បញ្ហាដែលបានបន្សល់ទុកទាំងនោះមានដូចជា កុមារីធាប់ភ័យខ្លាចនៅពេលកុមារាស្រែកសម្លុតមិនសូវមានទំនុកចិត្តក្នុងការដឹកនាំក្រុម មិនហ៊ានហក់លោតខ្លាំងដូចកុមារា (ឡើងទីខ្ពស់ ឬលេងបាល់ទាត់។ល។) មិនហ៊ានជ្រើសរើសពណ៌ដែលខ្លួនចូលចិត្ត ត្រូវបានមនុស្សចាស់បង្គាក់មិនឱ្យហក់លោតច្រើនពេកទេ ព្រោះខ្លួនជាកូនស្រី មិនសូវក្លាហានក្នុងការនិយាយខ្លាចខុស ហើយត្រូវបានគ្រូឱ្យធ្វើតែការងារណាដែលកុមារីធ្លាប់ធ្វើទៅតាមទម្លាប់ពីដើមមក ដូចជាការរៀបចំថ្នាក់ ជូត ឬទុកដាក់សម្ភារ(មិនប្រើកុមារា)។ល។ចំណែកកុមារាមួយចំនួនក៏នៅមិនទាន់មានសមភាពដែរ ដូចជាកុមារា មានសកម្មភាពរពិស និងចូលចិត្តស្រែកសម្លុតដាក់កុមារី និងកុមារាខ្លះដណ្តើមល្បែងលេងពីកុមារី និងមិនអាចរើសយកអ្វីដែលជារបស់ចំណូលចិត្តរបស់កុមារី ពេលខ្លះកុមារាមិនអាចលេងល្បែងដែលកុមារីមានទម្លាប់លេង។

បើយើងគិតឱ្យបានល្អិតល្អន់ យើងឃើញថា ទាំងនេះគឺជាកត្តាសំខាន់ដែលយើងមិនត្រូវមើលរំលងឡើយ ព្រោះទម្លាប់នៃភាពមិនមានសមភាពនេះហើយដែលធ្វើឱ្យជះឥទ្ធិពលអវិជ្ជមានដល់សង្គមនៅពេលដែលកុមារទាំងនោះបានក្លាយទៅជាមនុស្សពេញវ័យ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ៣. គរុកោសល្យនៃសកម្មភាពបង្រៀននិងរៀនឆ្លើយតបសមភាពយេនឌ័ររវាងកុមារា និងកុមារី

គរុកោសល្យនៃសកម្មភាពរៀននិងបង្រៀន ឆ្លើយតបទៅនឹងសមភាពយេនឌ័រ សំដៅទៅលើសកម្មភាពដែលផ្ដោតសំខាន់ទៅលើតម្រូវការនៃការសិក្សាជាក់លាក់របស់កុមារី និងកុមារា។ ទាំងនេះតម្រូវឱ្យគ្រូនិងគណៈគ្រប់គ្រងសាលារៀន គឺជាអ្នកដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រនៅក្នុងដំណើរការនៃសកម្មភាពរៀននិងបង្រៀន។

គរុកោសល្យនៃសកម្មភាពបង្រៀនដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ នឹងត្រូវបានលើកកម្ពស់ឱ្យមានការឆ្លុះបញ្ចាំងអំពីជំនឿរបស់ពួកគាត់ផ្ទាល់ទៅលើតួនាទីយេនឌ័រ ដែលមានតាំងពីយូរណាស់មកហើយ។ ការអនុវត្តបន្តិចម្ដងៗជាបន្តបន្ទាប់ វានឹងជួយគ្រូក្នុងការផ្ដល់ឱកាសស្មើគ្នារវាងកុមារី និងកុមារាក្នុងការចូលរួមសកម្មភាពរៀនសូត្រនិងលេងល្បែងនៅមត្តេយ្យសិក្សាមិនចំពោះតែកុមារី ឬកុមារានោះទេ។ បន្ថែមពីលើនេះទៅទៀត គរុកោសល្យនៃសកម្មភាពរៀននិងបង្រៀនឱ្យឆ្លើយតបទៅនឹងសមភាពយេនឌ័រនឹងបង្ហាញផ្លូវគ្រូក្នុងការជួយឱ្យសកម្មភាពដោយស្មើភាពគ្នារវាងកុមារី និងកុមារា។

*ហេតុអ្វីបានជាត្រូវមានគរុកោសល្យនៃការអប់រំរបស់គ្រូ ឱ្យឆ្លើយតបទៅនឹងសមភាពយេនឌ័ររវាងកុមារានិងកុមារី?*

គរុកោសល្យនៃការអប់រំកុមារ ដែលតម្រូវឱ្យមានការឆ្លើយតបទៅនឹងសមភាពរវាងកុមារា និងកុមារី គឺត្រូវតែមានទំនាក់ទំនងនៅក្នុងដំណើរការរៀននិងបង្រៀន សកម្មភាពក្នុងនិងក្រៅថ្នាក់រៀនដែលមានតួនាទីសំខាន់ ដើម្បីកំណត់ឱ្យកុមារទទួលបាននូវការបន្តចូលរួមនិងការអនុវត្តសមត្ថភាពរៀននៅក្នុងថ្នាក់រៀន។ ក្នុងនាមជាគ្រូមត្តេយ្យសិក្សា អ្នកអាចជួយកុមារឱ្យមានទំនាក់ទំនងដោយសមភាពរវាងកុមារា និងកុមារី ក្នុងលក្ខណៈជាវិជ្ជមានដោយទទួលបាននូវឱកាសរៀនសូត្រ និងអភិវឌ្ឍន៍ស្មើគ្នា។

## ៤- គោលបំណងនៃឯកសារ

ឯកសារនេះ រៀបចំឡើងដើម្បីជាជំនួយបន្ថែមដល់គ្រូមត្តេយ្យសិក្សា ធ្វើឱ្យកាន់តែប្រសើរឡើងនូវ៖

(១). ការរៀបចំផែនការបង្រៀន

(២). ការបង្រៀន និងបរិស្ថានសិក្សា

(៣). ការរៀបចំកន្លែងអង្គុយ ក្នុងពេលរៀន

(៤). ការលេងក្នុងនិងក្រៅថ្នាក់

(៥). ការប្រើភាសាក្នុងការប្រាស្រ័យទាក់ទងជាមួយកុមារពេលដឹកនាំសកម្មភាពរៀននិងបង្រៀន

(៦).ការធ្វើការទំនាក់ទំនងជាមួយឪពុកម្ដាយ ឬអ្នកអាណាព្យាបាល។

## ៥. ខ្លឹមសារសំខាន់ៗ

**ខ្លឹមសារសំខាន់ៗដែលត្រូវយកចិត្តទុកដាក់**




### ក. ការរៀបចំផែនការបង្រៀន

គ្រូត្រូវមានផែនករបង្រៀនដែលបានរៀបចំជាស្រេចនូវសម្ភារបង្រៀន សម្រាប់មេរៀននីមួយៗ ឆ្លើយតបទៅនឹងតម្រូវការនិងលទ្ធផលសិក្សារបស់កុមារ។ គ្រូគួរត្រៀមនិងគិតទៅដល់ចំណុចមួយចំនួនដូចខាងក្រោម៖

- តើត្រូវបង្រៀនដូចម្តេច ដើម្បីតម្រូវទៅនឹងចំនួនកុមារដែលមាននៅក្នុងថ្នាក់?
- រៀបចំបរិស្ថានថ្នាក់រៀន គិតបញ្ចូលរបៀបអង្គុយរបស់កុមារ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- តើកុមារត្រូវការប្រើសម្ភារអ្វីខ្លះ?
- តើត្រូវនិយាយយ៉ាងដូចម្តេច ដើម្បីធ្វើការទំនាក់ទំនងជាមួយកុមារ ឱ្យមានលក្ខណៈរីករាយ និងស្មើភាព?
- តើត្រូវធ្វើអ្វីខ្លះដើម្បីឱ្យមានការទំនាក់ទំនងជាមួយឪពុកម្តាយឬអណាព្យាបាលកុមារក្នុងការជួយយកចិត្តទុកដាក់ជាមួយកូនស្មើៗគ្នានៅផ្ទះបន្ថែមទៀត?

### គន្លឹះសំខាន់ៗក្នុងពេលរៀបចំផែនការ បង្រៀន

- *ធានាថាកុមាររីករាយ និងចូលចិត្តសកម្មភាពដែលអ្នករៀបចំ ចៀសវាងការ ផ្តោតតែទៅលើកុមារី ឬ កុមារា។*
- *គ្រូអាចនិយាយចែករំលែក នូវបទពិសោធន៍ជាក់ស្តែងរបស់អ្នក ដែលកំពុងតែ ប្រឈមនឹងទទួលខុសត្រូវ ឧទាហរណ៍ពេលខ្លះប្តីរបស់អ្នកគ្រូ ដាំស្ល) បោកគក់ខោអាវ លាងចាន។ល។*
- *នៅក្នុងមេរៀនអំពីមុខរបរ គ្រូគួរនិយាយពិភាក្សាអំពីការទទួលខុសត្រូវរបស់ មុខជំនាញនីមួយៗ ដែល បុរស និងស្ត្រីក៏អាចធ្វើបានដូចគ្នា រួមទាំង។*
- *ចៀសវាងការសន្និដ្ឋានក្នុងកំឡុងការសន្ទនាដូចជា( ឪពុកដែល មិនចេះដាំស្លគឺជាឪពុកមិនល្អ) ជាដើម។*
- *នៅពេលដែលអ្នកធ្វើផែនការចូរអ្នកចាំថាអ្នកចង់ឱ្យកុមារទទួលស្គាល់និងយល់អំពីកុមារីនិងកុមារា ស្ត្រីនិងបុរស។*

## ខ-ការបង្រៀន និងបរិយាកាសសិក្សា

- **ការបង្រៀន៖** នៅក្នុងមេរៀនមួយ គ្រូបង្កឱកាសសម្រាប់កុមារដើម្បីធ្វើការប្រាស្រ័យទាក់ទងជាមួយមិត្តរបស់ពួកគេពីម្នាក់ទៅម្នាក់ទៀត ប្រើប្រាស់វិធីសាស្ត្រធ្វើការងារជាក្រុមដែលអាចលើកទឹកចិត្តកុមារទាំងអស់ឱ្យមានឱកាសបានការចូលរួមមតិយោបល់ ការសហការគ្នាក្នុងការធ្វើការងារ ហើយនៅពេលដែលកុមារបានធ្វើការងារជាមួយដៃគូពួកគេ នឹងបានអភិវឌ្ឍន៍បំណិនក្នុងការនិយាយប្រាស្រ័យទាក់ទងគ្នាយ៉ាងមានប្រសិទ្ធភាព ធ្វើឱ្យពួកគេមានទំនុកចិត្តចំពោះខ្លួនគេផ្ទាល់ និងមានភាពស្និទ្ធស្នាលជាមួយកុមារផ្ទុយភេទក្នុងការប្រាស្រ័យទាក់ទងទៀតផង។ បំណិនសង្គមទាំងនោះគឺយើងពិតជាត្រូវការប្រើប្រាស់ក្នុងជីវិតនៅពេលដែលពួកគេក្លាយជាមនុស្សធំ នៅពេលដែលពួកគេនឹងត្រូវធ្វើការទំនាក់ទំនងគ្នាក្នុងការងារដែលមានបុរស និងស្រីធ្វើការជាមួយគ្នា។
- **បរិយាកាសសិក្សា៖** សកម្មភាពនៃការបង្រៀននិងការរៀនអាចធ្វើឡើងនៅក្នុងនិងក្រៅថ្នាក់។ ការឆ្លើយតបបែបសមភាពរវាងកុមារីនិងកុមារាក្នុងសកម្មភាពរៀននិងបង្រៀនអាចកំណត់បានតាមរយៈការរៀបចំកន្លែងធ្វើសកម្មភាពឬកន្លែងអង្គុយរៀនរបស់កុមារ ការរៀបចំគ្រប់គ្រងថ្នាក់

រៀន ការរៀបចំការងារជាក្រុមរបស់កុមារ ការរៀបចំសកម្មភាពរៀនក្នុងនិងក្រៅថ្នាក់ដោយរៀបចំ សកម្មភាព រៀនតាមរយៈការលេងរបស់កុមារ )Learning Through Play )។



## គ. ការរៀបចំកន្លែងអង្គុយ ក្នុងពេលធ្វើសកម្មភាពរៀន

- បែងចែកកុមារជាក្រុមការងារ ដែលក្នុងក្រុមនីមួយៗ មានកុមារី និងកុមារា លាយគ្នាដើម្បីឱ្យពួក គេបានចូលរួមធ្វើការងារ ឬលេងជាក្រុមដែលមានចម្រុះភេទ។
- ផ្លាស់ប្ដូរក្រុមជាប្រចាំ ដើម្បីឱ្យកុមារបានចូលរួម និងបានផ្សារភ្ជាប់ទំនាក់ទំនងរវាងគ្នានិងគ្នា ជាមួយមិត្ត និងទំនាក់ទំនងបន្តពីម្នាក់ទៅម្នាក់ទៀតនៅក្នុងថ្នាក់រៀន។
- រៀបកុមារឱ្យអង្គុយជារាងរង្វង់ ដោយឆ្លាស់គ្នារវាងកុមារីនិងកុមារាដើម្បីឱ្យពួកគាត់បានធ្វើការរួមគ្នា ចូលរួមបានគ្រប់គ្នា ស្មើភាពគ្នា និងមានការទំនាក់ទំនងគ្នារវាងភេទផ្សេងគ្នា។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ឃ. ការលេងក្លូន និងត្រៅថ្នាក់

ការរៀនតាមរយៈការលេង(Learning Through Play) គឺជាមធ្យោបាយដ៏សំខាន់ណាស់ និងមានប្រសិទ្ធភាពបំផុតជាពិសេសគឺចំពោះកុមារវ័យមត្តេយ្យសិក្សា។ សម្ភារល្បែង និងការប្រាស្រ័យទាក់ ទងគ្នាក្នុងការលេងជាមួយដៃគូ នឹងជួយឱ្យកុមារបានលេងទាំងអស់គ្នា និងដោះស្រាយបញ្ហាក្នុងការលេងរួមគ្នា។ ការលេងគឺនាំឱ្យកុមារបានរៀនហើយកុមារអាចលេងជាមួយកុមារដ៏ទៃដែលមានក្រុមអាយុចម្រុះ និងភេទផ្សេងគ្នា។ យ៉ាងណាក៏ដោយក៏កុមារានិងកុមារីច្រើនតែចូលចិត្តលេងអ្វីផ្សេងពីគ្នា ដែលជាហេតុផលធ្វើឱ្យពួកគាត់យល់ថាកុមារីនិងកុមារា គឺមានភាពខុសគ្នាឆ្ងាយមិនអាចធ្វើអ្វីដូចគ្នាបានទេ។ កុមារាចូលចិត្តលេងអ្វីដែលរពឹសជាង ប្រឡឹមជាង រហ័សរហួនជាង ត្រូវការទីកន្លែងទូលាយ ដូចជា កុមារាចូលចិត្តលេងបាល់ទាត់ នៅពេលដែលកុមារីចូលចិត្តលេងល្បែងដែលងាយៗយឺតៗ ដូចជា លេងធ្នឹះគ្រាប់គ្រួសជាដើម។ កំណត់សម្គាល់ទាំងអស់ខាងលើនេះ នឹងមានការជះឥទ្ធិពលដល់ការគិត និងលទ្ធផលរបស់កុមារ។





- អ្នកត្រូវចងចាំថាកុមារី និងកុមារាមានរាងកាយមាំមួន និងត្រូវការធ្វើចលនាដូចគ្នារហូតដល់ពេលដែលពួកគេពេញវ័យ ប៉ុន្តែកុមារី ច្រើនតែអាចបង្ហាញពីអត្តចរិតទំនាក់ទំនងសង្គមបានប្រសើរជាង។
- លើកទឹកចិត្តកុមារលេងល្បែងជាក្រុម ដែលមានសមាសភាពកុមារីលាយចម្រុះជាមួយកុមារា ក្នុងការលេង ឬធ្វើការងារជាក្រុម។
- ល្បែងមួយចំនួនមានការលេង ដោយកុមារា ឬក៏កុមារី តែប៉ុណ្ណោះ ពួកគាត់មិនដែលលេងចូលគ្នាទេ ឧទាហរណ៍ បាល់ លេងកូនក្រមុំ លេងល្បែងសំណង់ និងលេងលោតអន្ទាក់។ល។ ដូច្នេះគ្រូត្រូវលើកទឹកចិត្តនិងរៀបចំសកម្មភាពបង្រៀនអំពីរបៀបលេងដល់កុមារ ឱ្យពួកគាត់អាចលេងជាមួយគ្នាបាន។
- លើកសរសើរ កុមារី កុមារាដែលមានការផ្លាស់ប្តូរបាននូវទម្លាប់លេងជាមួយគ្នា និងចេះផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមក។





## ខ. ការប្រាស្រ័យទាក់ទង និងការប្រើប្រាស់ការនិយាយជាមួយកុមារ

ការប្រាស្រ័យទាក់ទងរវាងគ្រូ និងសិស្ស គឺជាកត្តាដ៏សំខាន់បំផុតដែលត្រូវប្រើជាមួយកុមារក្នុងថ្នាក់រៀន ព្រោះវាត្រូវតែជាភាសាដែលឆ្លើយតបទៅនឹងសមភាពយេនឌ័រ ។ ការនិយាយស្តី ដែលមានលក្ខណៈឆ្លើយតបទៅនឹងសមភាពយេនឌ័រដែលវាអាចធ្វើឱ្យកុមារមានអារម្មណ៍ថា ត្រូវទទួលបានការគោរព និងឱ្យតម្លៃ ដូចជាការលើកទឹកចិត្តកុមារដែលនឹងធ្វើឱ្យការរៀនសូត្របានប្រសើរឡើង បន្ថែមពីនេះទៀត បានបង្កបរិយាកាសល្អក្នុងការសិក្សាដែលកុមារអាចបញ្ចេញគំនិតខ្លួនឯងដោយសេរី ក្រោមការសម្របសម្រួលពីសំណាក់គ្រូមត្តេយ្យសិក្សា។

ការរៀនដែលមានការផ្តល់តម្លៃឱ្យកុមារ ធ្វើឱ្យកុមារមានទំនុកចិត្ត មានសេចក្តីក្លាហាន និងមានអារម្មណ៍ត្រូវបានលើកទឹកចិត្ត មានការយកចិត្តទុកដាក់ ដែលនាំឱ្យលទ្ធផលនៃការសិក្សារបស់ពួកគេកាន់តែប្រសើរឡើង។ ផ្ទុយទៅវិញ ការនិយាយឬប្រើភាសាមិនល្អ និងកាយវិការដែលមិនសមរម្យ ដូចជាកាយវិការ ទឹកមុខ ប្រើភ្នែកសម្លក់ បែបគំរាមកំហែង ទៅលើកុមារីឬកុមារា អាចធ្វើឱ្យកុមារចម្លងតាមនូវទស្សនៈអវិជ្ជមានចំពោះសមភាពយេនឌ័រ និងជាសារដែលកុមារនឹងរៀនតាមរយៈការប្រាស្រ័យទាក់ទងពីមនុស្សម្នាក់ទៅម្នាក់ទៀតផងដែរ។

## ច. ការប្រាស្រ័យទាក់ទងរវាងគ្រូ និងឪពុកម្តាយ

ជារឿយៗ ឪពុកម្តាយនិងអ្នកមើលថែកុមារ មិនបានដឹងថាពួកគាត់ បន្តការបង្ហាញនូវអត្តចរិត និងជំនឿអំពីតួនាទីខុសគ្នារវាងបុរសនិងស្ត្រីនោះទេ ហើយកុមារាភាគច្រើនថែទាំនិងចិញ្ចឹមខុសគ្នាពីកុមារី។ ជាទូទៅកុមារីត្រូវបានរៀបចំឱ្យស្លៀកពាក់ទៅតាមពណ៌ដូចជាពណ៌ផ្កាឈូកពណ៌ស្វាយ ហើយសម្ភារលេងទៀតសោតមានដូចជា កូនក្រមុំ តុក្កតា គឺសម្រាប់កុមារីលេង រីឯបាល់ ឬកូនឡាន សម្រាប់តែកុមារាលេង។ កូនស្រីត្រូវបានបង្រៀនឱ្យស្តាប់បង្គាប់សុភាពរាបសា កុមារាត្រូវបានបង្រៀនឱ្យក្លាហានរឹងមាំ ជួនកាលកុមារី ត្រូវបានការពារម៉ត់ចត់ជាងកុមារា។ ទន្ទឹមនឹងនេះដែរ កុមារាត្រូវបានបង្រៀនមិនឱ្យយំ ព្រោះជាសញ្ញាបង្ហាញថា ទន់ខ្សោយ។ ឪពុកម្តាយ ក៏បានបង្ហាញនូវទស្សនៈលម្អៀងមួយចំនួន ដូចជា ស្ត្រី ត្រូវធ្វើការងារផ្ទះ ដូចជាបោសសម្អាតផ្ទះ បោកគក់ខោអាវ ធ្វើម្ហូបជាដើម។ ចំណែកបុរស ធ្វើការងារក្រៅផ្ទះ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដើម្បីដោះស្រាយបញ្ហា ផ្គត់គំនិតអវិជ្ជមាន អំពីសមភាពយេនឌ័រ នៅក្នុងគ្រួសារ និងសហគមន៍របស់កុមារ អ្នកត្រូវធ្វើការជិតស្និទ្ធជាមួយសហគមន៍ ។

### ចំណុចដែលត្រូវយកចិត្តទុកដាក់បន្ថែម ដើម្បីចូលរួមចំណែក លើកកម្ពស់សមភាព រវាងកុមារា និងកុមារី ចំពោះការប្រាស្រ័យទាក់ទង រវាងគ្រូ និងឪពុកម្ដាយ

- *នៅពេលដែលកុមារបង្ហាញអំពីចរិតរើសអើង ត្រូវ ព្យាយាមទទួលព័ត៌មានបន្ថែមអំពីស្ថានភាព និងហេតុផលដែលនាំឱ្យកុមារមានចរិតបែប នេះ។*
- *ព្យាយាមរកពេលសន្ទនាជាលក្ខណៈឯកជន ជាមួយឪពុកម្ដាយ ឬអាណាព្យាបាលកុមារដើម្បី ពិភាក្សារកឱកាសចំណេញស្មើគ្នានិងគោរពការ ជួយរបស់ពួកគាត់។*
- *ត្រូវចងចាំថា ការគោរពគ្នាទៅវិញទៅមកគឺជា*



## ៦. ការវាស់វែងនិងវាយតម្លៃការប្រឡួលរបស់កុមារ

- ការវាយតម្លៃការរីកចម្រើនរបស់កុមារនឹងប្រើប្រាស់សម្រាប់គ្រូ ឪពុកម្ដាយ និងគ្រួសាររបស់កុមារ នូវព័ត៌មានសំខាន់ៗ មួយចំនួន អំពីការរីកចម្រើនរបស់កុមារ។
- ព័ត៌មានសំខាន់ៗបានមកពីការវាយតម្លៃ ក៏ត្រូវបានប្រើប្រាស់ ផងដែរសម្រាប់ប្រសិទ្ធភាពនៃសកម្មភាពបង្រៀននិងរៀន ដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលសិក្សារបស់កុមារ។
- នៅពេលធ្វើការវាយតម្លៃ អ្នកនឹងត្រូវមានមោទនភាព ព្រោះអ្នកដឹងថា អ្វីដែលអ្នកកំពុងធ្វើគឺត្រឹមត្រូវដូចដែលមានគ្រោងទុក។
- ការសង្កេតរបស់អ្នកទៅលើកុមារី និងកុមារានឹងជួយអ្នកឱ្យវាយតម្លៃអំពី ការប្រាស្រ័យទាក់ទងក្នុងសមភាពយេនឌ័រ។
- ប្រើប្រាស់ព័ត៌មាន ដែលអ្នកបានប្រមូល ដើម្បីជួយកុមារឱ្យប្រសើរឡើងនូវ អត្តចរិត អាកប្បកិរិយា តម្លៃ និងការសិក្សារៀនសូត្រ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews





## គន្លឹះសំខាន់ៗ

- វិធីដែលល្អបំផុតក្នុងការវាយតម្លៃកុមារគឺ "ការសង្កេត"។ តាមរយៈការសង្កេត អ្នកនឹងបានដឹងថា តើមានផ្នត់គំនិតអ្វីខ្លះដែលរារាំងនៅក្នុងថ្នាក់ដែលជាឧបសគ្គក្នុងការសិក្សារបស់កុមារ។
- លើកទឹកចិត្តកុមារ ឱ្យលេងល្បែងណាដែលជាធម្មតាលេងដោយភេទផ្ទុយបាន ដូចជា )បាល់ បាញ់កៅស៊ូកង លោតអន្ទាក់ កូនក្រមុំ។ល។
- អ្នកអាចសួរសំណួរទៅកុមារម្នាក់ៗ អ្នកនឹងបានដឹងអំពី ការយល់ដឹង ផ្នត់គំនិត និងការអនុវត្ត របស់កុមារជុំវិញ រឿងរ៉ាវនៃផ្នត់គំនិតយេនឌ័រ។
- នៅពេលអ្នកធ្វើការសង្កេត អ្នកគួរផ្ដោតទៅលើ ការបញ្ចេញមតិ ការធ្វើកាយវិការ ការច្រៀង រាំ និងគូររូបរបស់កុមារ។ល។

## ឧទាហរណ៍មួយអំពីឧបករណ៍សម្រាប់ធ្វើការសង្កេតៈ

*គំរូឧទាហរណ៍នេះ គឺមានប្រយោជន៍សម្រាប់ធ្វើការសង្កេត អាកប្បកិរិយារបស់កុមារ។*
*បញ្ជាក់៖ អ្នកអាចកែសម្រួលទៅតាមតម្រូវការជាក់ស្តែងនៃថ្នាក់រៀនរបស់អ្នក។*

| ឈ្មោះ របស់កុមារ | ចំណុចដែលធ្វើបាន | យោបល់បន្ថែម |
|---|---|---|
| *ការប្រាស្រ័យទាក់ទងជាមួយដៃគូ* | ✓ | *ជាមួយអ្នកណា ?* |
| *ការប្រាស្រ័យទាក់ទងជាមួយដៃគូដែលជាភេទ ផ្ទុយគ្នា* | ✓ | *ជាមួយអ្នកណា ?* |
| *មិនមានការខុសគ្នានៅពេលធ្វើការទំនាកទំនង ពេលនិយាយទៅកាន់ដៃគូជាភេទផ្ទុយគ្នា* | ✓ | *ធ្វើការអធិប្បាយ* |
| *លេងនៅក្បែរកុមារដែលមានភេទផ្ទុយ* | ✓ | *ជាមួយអ្នកណា ?* |
| *ចូលរួមលេងជាមួយដៃគូដែលជាភេទផ្ទុយ* | × | *លេងជាមួយអ្នកណា ?* |
| *ចូលរួមលេងជាមួយសម្ភាររៀន* | × | *សម្ភារអ្វីខ្លះ ?* |
| *ចូលរួមលេងជាមួយសម្ភារ ដែលមិនមានផ្នត់គំនិត យេនឌ័រ* | ✓ | *លេងដូចម្តេច ?* |
| *រូបដែលកុមារបានគូរ រួចមាន រូបកុមារា និងរូបកុមារី* | ✓ | *ធ្វើការអធិប្បាយ* |
| *បាននិទានរឿងប្រាប់អំពី សាច់រឿងដែលមានតួអង្គទាំងពីរភេទ* | ✓ | *ធ្វើការអធិប្បាយ* |

## យេនឌ័រ និងការសិក្សាភាសាខ្មែរ

ដើម្បីឆ្លើយតបសមភាពយេនឌ័រនៅក្នុងមុខវិជ្ជាភាសាខ្មែរ គ្រូមត្តេយ្យសិក្សា ត្រូវយកចិត្តទុកដាក់៖

- ដឹកនាំកុមារទាំងពីរភេទ ចូលរួមសកម្មភាពនៃមុខវិជ្ជាភាសាខ្មែរដោយផ្តល់បរិយាកាសរីករាយ ពន្យល់អំពីអត្ថប្រយោជន៍នៃការលេងល្បែងសិក្សាលើមុខវិជ្ជាភាសាខ្មែរ ដើម្បីតម្រង់ទិសត្រៀមអាន ត្រៀមសរសេរ ការហាត់ស្តាប់សូរអក្សរ និងការនិយាយពាក្យឱ្យបានច្បាស់លាស់។
- ត្រូវសង្កេត និងលើកទឹកចិត្តកុមារ ឱ្យសកម្មដូចគ្នាក្នុងគ្រប់ប្រភេទសម្មភាព ដោយរំលឹកពីប្រយោជន៍នៃការរៀនភាសាខ្មែរសម្រាប់ពួកគេ។
- ផ្តល់ឪកាសឱ្យកុមារី និងកុមារាបានសូត្រកំណាព្យ និទានរឿង ច្រៀងរាំ និងធ្វើកាយវិការឱ្យបានស្ទាត់ដូចគ្នា ជាពិសេសឱ្យកុមារាអាចធ្វើបានល្អដូចដែលកុមារីអាចធ្វើបាន។
- សរសើរលើកទឹកចិត្តកុមារី និងកុមារា នៅពេលដែលពួកគេ អាចច្រៀង រាំ  សូត្រកំណាព្យ និងនិទានរឿងបានល្អដូចគ្នា។
- ផ្តល់ឪកាសឱ្យកុមារបានច្រៀង ឬសូត្រកំណាព្យឆ្លើយឆ្លងគ្នារវាងកុមារី និងកុមារា។
- លើកទឹកចិត្តកុមារី និងកុមារាដែល ធ្វើកិច្ចការមិនទាន់បានល្អឱ្យប្រឹងប្រែងបន្តទៀត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## គន្ថនិទ្ទេស


១. ភាសាខ្មែរសម្រាប់បណ្តុះបណ្តាលគ្រូមត្តេយ្យ (នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ឆ្នាំ ២០១៣)

២. បណ្ណាល័យនិងសៀវភៅសម្រាប់កុមារ (..ឆ្នាំ២០០៧)

៣. ឯកសារណែនាំស្តីពីការនិទានរឿងសម្រាប់កុមារតូច (អង្គការសន្តិស្ម័គ្រចិត្ត ឆ្នាំ២០១៩)

៤. វិធីសាស្ត្រ និងលំនាំគ្រប់មុខវិជ្ជាសម្រាប់មត្តេយ្យសិក្សារដ្ឋ (នាយកដ្ឋានអប់រំកុមារតូច..)

៥. សៀវភៅជំនួយគ្រូមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា(នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ២០១៩)

៦. សៀវភៅណែនាំសម្រាប់គ្រូមត្តេយ្យសិក្សាស្តីអំពីសម្ភារជំនួយបន្ថែមលើមុខវិជ្ជាភាសាខ្មែរ (..ឆ្នាំ ២០១៩)

៧. កម្មវិធីសិក្សាគោល

៨. ក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស (ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៦)

៩. កម្មវិធីសិក្សាលម្អិតសម្រាប់មត្តេយ្យសិក្សារដ្ឋ (នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ២០១៨)

១០. វចនានុក្រមខ្មែរ (ជ.ណ ជោតញ្ញាណោ ឆ្នាំ១៩៦៧)

១១. Language and Literacy Guide book (Ministry of Education Republic of Singapore 2013)

១២. ឯកសារធនធានអភិវឌ្ឍកុមារតូច (នាយកដ្ឋានអប់រំកុមារតូច កុម្ភៈ ឆ្នាំ២០១០)

១៣. សិក្សាចិត្តសាស្ត្រសង្គមនៅមត្តេយ្យសិក្សា(នាយកដ្ឋានអប់រំកុមារតូច ឆ្នាំ២០២០)

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ឧបត្ថម្ភការបោះពុម្ព

PLAN INTERNATIONAL